ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការបញ្ចប់នៃករណី០០១ជាការក្រើនរំឭកដល់ករណីបន្ទាប់
- ទីបញ្ចប់នៃសមមិត្ត ឌុច

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤៦ ខែកុម្ភៈ ឆ្នាំ២០១២

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៤៦ ខែកុម្ភៈ ឆ្នាំ២០១២

## មាតិកា

◆ការបញ្ចប់នៃករណី០០១ជាការត្រើនរំឭកដល់ករណីបន្ទាប់.....................១

**ផ្នែកឯកសារ**

◆យុទ្ធនារីពេទ្យ ១៧មេសាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ .................២

◆អង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តន្ទាទោស ..............................៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ឌុច ជាប់ពន្ធនាគារអស់មួយជីវិត .............................................១០

◆សាលដីកាចុងក្រោយក្នុងសំណុំរឿង ឌុច.............................១២

◆យុត្តិធម៌សម្រាប់អ្នកទោសលេខ៥៧០ .....................................១៨

◆រូបថតមួយសន្លឹកនៅមន្ទីរស-២១នៅដក់ជាប់ក្នុងចិត្តខ្ញុំ ................២០

◆ការផ្តល់សក្ខីកម្មរយៈពេលបីថ្ងៃរបស់លោក ឆាំង យុ ..................២៣

**ផ្នែកច្បាប់**

◆សហខក្រិដ្ឋកម្មរួមលក្ខណៈលាតសន្ធឹងនិងការទទួល .......................២៨

**វេទិកាពិភាក្សាសាធារណៈ**

◆ការពិនិត្យមើលសាឡើងវិញលើការបរចា ..................................៣៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ទីបញ្ចប់នៃសមមិត្ត ឌុច .......................................................៣៧

◆អ្វីដែលខ្ញុំចង់បានគឺយុត្តិធម៌សម្រាប់កូនខ្ញុំ ....................................៤៣

◆ខ្ញុំនៅតែចងចាំបងប្រុស សៀង គីមឡេង.................................៤៦

◆តើមានរឿងអ្វីពិតប្រាកដកើតឡើងចំពោះខ្ញុំ? .............................៤៨

◆ខ្ញុំសុំឲ្យមានបូជនីយដ្ឋានសម្រាប់ព្រលឹងរបស់បងខ្ញុំ.........................៥១

◆យុត្តិធម៌ដែលបានបាត់បង់ ....................................................៥២

◆ម្តាយដែលជាវីរៈនារីរបស់ខ្ញុំ ...................................................៥៣

◆ខ្ញុំចង់ដឹងថា ឌុច មានអារម្មណ៍បែបណា បើសិនជាគាត់មានកូន..........៥៧

◆បងប្រុសខ្ញុំដែលបាត់ខ្លួន .......................................................៥៨

◆យុត្តិធម៌ជូនលោកពុក .........................................................៥៩

◆ឪពុករបស់ខ្ញុំ និងការប្រកាសសាលដីការបស់ ............................៦០



ប៊ូ ម៉េង អតីតអ្នកទោសមន្ទីរស-២១ នៅគេហដ្ឋានថ្មរបស់គាត់

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** គាត លក្ខិណា, រ៉េនដល ឌីហ្វាល់កូ, ហ៊ុយ សេងហ៊ុល, ស៊ីវ ហេឌី, លឹម ជ័យទ័ត្ត, ស៊ីរី សាវីណា, ចេម ក្រឹងហ្គល, ម៉ាន សូត, ហ៊ឹម មុំ, លី ហ៊ា, កែ សាម៉ូត, ខៀវ នាភ, ហាវ សោភា, ម៉ែន ឡាយ, រូន ស្រីណុប **អ្នកនិពន្ធនិងស្រាវជ្រាវ :** សោម ប៊ុនថន, ស៊ិន សុធីតា, ទាវ សារៈមុនិន្ទ **អ្នកបកប្រែ :** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ :** ស៊ឹម សុភ័ក្រ Email: dccam@online.com.kh, Homepage: www.dccam.org

# ការបញ្ចប់នៃករណី០០១ជាការក្រើនរំឭកដល់ករណីបន្ទាប់

ជនរងគ្រោះនៃរបបខ្មែរក្រហមភាគច្រើនមានចិត្តត្រេកអរ នៅពេលដែលសាលាឧទ្ធរណ៍សម្រេចកាត់ទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ស្របក្នុងពេលជាមួយគ្នានោះដែរ ជនរងគ្រោះទាំងនោះនៅតែចង់ដឹងថាតើជនជាប់ចោទទាំងបីរូបទៀតគឺ នួន ជា, អៀង សារី និង ខៀវ សំផន អាចនឹងទទួលបានការកាត់ទោសចប់ចុងចប់ដើមដូច ឌុច ដែរឬទេ? តើករណី ០០២ នឹងត្រូវចំណាយពេលយូរប៉ុណ្ណា បើជនជាប់ចោទក្នុងករណីនេះមិនសូវជាសហការពេញលេញជាមួយនិងអង្គជំនុំជម្រះផង ហើយម្យ៉ាងទៀតជនជាប់ចោទទាំងបីមានវ័យកាន់តែចាស់ផងនោះ?

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច គឺជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានមន្ទីរស-២១ដែលបានគ្រប់គ្រងមន្ទីរនេះយ៉ាងតឹងរ៉ឹង ហើយដែលបានធ្វើឲ្យអ្នកទោសប្រមាណជា ១២.២៧២នាក់បានបាត់បង់ជីវិត ។ តុលាការខ្មែរក្រហមបានរកឃើញថា ឌុច បានប្រព្រឹត្តិបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។

អតីតអ្នកទោស និងសាច់ញាត្តិរបស់អ្នកដែលធ្លាប់ជាប់នៅមន្ទីរស-២១ អបអរនិងពេញចិត្តនៅពេលដែល ឌុច ត្រូវបានសម្រេចឲ្យជាប់ទោសអស់មួយជីវិតនេះ ។ នេត ផល្លី ដែលមានបងប្រុសជាប់ឃុំនិងស្លាប់នៅមន្ទីរស-២១ បានអះអាងថា “នេះជាយុត្តិធម៌មួយសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ហើយការដាក់ទោសនេះគឺជារឿងសមហេតុសមផល” ។ ចំណែកឯ ចាន់ គ្រួច បានអះអាងថា ការកាត់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត “គឺជាសេចក្តីសម្រេចដ៏ត្រឹមត្រូវបំផុត ។ ខ្ញុំលែងគុំគួននិង ឌុច ទៀតហើយ” ។ ឌុច ទទួលទោសអតិបរមាក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ មិនខុសពី ផល្លី និង គ្រួច ទេ ប្រជាជនកម្ពុជាដែលធ្លាប់រងគ្រោះក្នុងរបបខ្មែរក្រហមភាគច្រើនពេញចិត្តដែល ឌុច ត្រូវជាប់ឃុំអស់មួយជីវិត ។ នៅថ្ងៃទទួលសាលក្រមនាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឌុច ស្លៀកសម្លៀកបំពាក់ខោជើងវែង ពាក់អាវពណ៌ស និងអាវធំពាក់ពីក្រៅពណ៌ពងក្រសារ ព្រមទាំងកាន់គម្ពីគ្រីស្តសាសនាមួយក្បាល ។ ថ្ងៃនោះគឺជាថ្ងៃបញ្ចប់នៃករណី០០១ ។

ឥឡូវនេះគឺជាពេលដែលត្រូវនិយាយពីសំណុំរឿង០០២ ។ ដំណើរការសំណុំរឿង០០២ឲ្យបានលឿន គឺជាក្តីប្រាថ្នាចង់បានដ៏ធំបំផុតរបស់អ្នកធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ដោយសារតែជនជាប់ចោទទាំងបីឋិតក្នុងវ័យ៨០ឆ្នាំថ្វាយទៅហើយ ហើយលើសពីនេះទៅទៀត ជនជាប់ចោទទាំងបីនាក់ក៏មិនបានចូលរួមដំណើរការសវនាការឲ្យពេញលេញដែរ ដោយសារតែបញ្ហាសុខភាព ។ ជនជាប់ចោទ នួន ជា និង អៀង សារី មិនអាចអង្គុយក្នុងបន្ទប់សវនាការឲ្យបានមួយព្រឹក ឬមួយល្ងាចពេញដើម្បីតាមដានដំណើរការសវនាការទេ ហើយ នួន ជា ក៏មិនបានឆ្លើយការពិតនូវអ្វីដែលខ្លួនធ្លាប់និយាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមមួយចំនួនត្អូញត្អែញថា ជនជាប់ចោទអាចទទួលបាននូវការពិនិត្យនិងព្យាបាលសុខភាពបានគ្រប់ពេលវេលាដែលខុសពីជនរងគ្រោះប្រជាជនកម្ពុជាភាគច្រើនទូទាំងប្រទេសដែលមិនមានលទ្ធភាពទទួលការព្យាបាលបែបនេះឡើយ ។

ទោះបីជាយ៉ាងនេះក៏ដោយ ប្រជាជនកម្ពុជាចង់ឲ្យសាលាក្តីខ្មែរក្រហមដំណើរការកាត់ទោសសំណុំរឿង០០២ ឲ្យបានលឿនបំផុត និងដំណើរការចប់សព្វគ្រប់ដូចករណីសំណុំរឿង០០១ដែរ ព្រមទាំងចង់ឃើញជនជាប់ចោទទទួលទោសឲ្យសមទៅនិងអ្វីដែលខ្លួនបានប្រព្រឹត្តិក្នុងនាមជាអ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។ ពេលនេះជនជាប់ចោទមិនអាចអង្គុយលើសពីមួយព្រឹកឬមួយល្ងាចបានទេ ដូច្នេះការអូសបន្លាយក្នុងការកាត់ទោសអាចនឹងធ្វើឲ្យដំណើការសវនការមានភាពយឺតយ៉ាវកាន់តែច្រើនឡើង ។ ផល្លី និង គ្រួច ព្រមទាំងជនរងគ្រោះដទៃទៀតចង់ឃើញភាពយុត្តិធម៌ក្នុងសំណុំរឿង០០២ ដូចអ្វីដែលគាត់ត្រូវបានផ្តល់ជូនដូចសំណុំរឿង០០១ដែរ ។ បើសិនសំណុំរឿង០០២មិនបានដំណើរការចប់សព្វគ្រប់ទេ នោះជនរងគ្រោះនឹងមិនអាចទទួលបានយុត្តិធម៌ជារៀងរហូត ។

**ញាណ សុជាតិ**

# យុទ្ធនារីពេទ្យ ១៧មេសា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*អត្ថបទសង្ខេបចេញពីចម្លើយសារភាព **D21233***

ពេញ សុភាព មានឈ្មោះបដិវត្តន៍ ឡៃ អាយុ២២ឆ្នាំ ពេលដែលគាត់ត្រូវបានចាប់ខ្លួន ។ មុនពេលចាប់ខ្លួន សុភាព មាននាទីជានារីពេទ្យផ្នែកវះកាត់ឆ្អឹងនៅមន្ទីរពេទ្យ១៧មេសា (បច្ចុប្បន្ន មន្ទីរពេទ្យរុស្ស៊ី) ។ នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ សុភាព បានរៀបរាប់ថា នៅពេលគាត់ដែលមានអាយុ១២ឆ្នាំ គាត់រៀនបានត្រឹមថ្នាក់ទី១០ ហើយពេលនោះ គាត់ក៏ឈប់រៀន ដើម្បីជួយធ្វើស្រែឪពុកម្តាយ ។ កាលនោះមានសាច់ញាត្តិខាងម្តាយពីរនាក់គឺ សេង និង សិត តែងតែមកលេងផ្ទះរបស់ សុភាព ជាញឹកញាប់ ។ ពេលនោះ សេង ចុះឡើងផ្ទះរបស់ សុភាព ជាញឹកញាប់ ហើយក្រោយមក សេង និង សុភាព បានជ្រុលខ្លួនប្រាណជាមួយគ្នាដោយមិនឲ្យឪពុកម្តាយដឹងឡើយ ។

ក្រោយមក នៅខែមិថុនា ឆ្នាំ១៩៧០ សេង បានបញ្ចូល សុភាព ជា សេ.អ៊ី.អា ។ បីខែក្រោយមក ម្តាយ សុភាព បានយកកូនចៅទាំងអស់ទៅនៅភូមិផ្សេងទៀត ។ ពេលនោះ សុភាព មានភាពជិតស្និតជាមួយ សឿន ដែលជាកងការពាររបស់ឪពុកជាខ្លាំង ហើយមិនយូរប៉ុន្មាន សឿន និង សុភាព ជ្រុលជ្រួសខ្លួនប្រាណទៀត ។ បន្ទាប់មក ឪពុករបស់ សុភាព ដែលជា សេ.អ៊ី.អា បង្កប់ខ្លួនក្នុងតំបន់រំដោះបានខទ្មសនាមឲ្យ សុភាព ទាក់ទងខ្សែជាមួយ គាត អតីតគ្រូបង្រៀននៅភ្នំពេញ ។ រំលងបានកន្លះខែ គាត់បានហៅ សុភាព ទៅប្រជុំដោយក្នុងនោះមាន ថន, ម៉ៅ, ង៉ែត ហើយគាត់បានខទ្មសនាមឈ្មោះទាំងអស់ឲ្យ សុភាព ស្គាល់ដើម្បីរួមគ្នាធ្វើសកម្មភាព ។ សុភាព ត្រូវបានចាត់តាំងឲ្យធ្វើជាកម្មាភិបាលនៅមន្ទីរសិល្បៈភូមិភាគនិរតី ។

សកម្មភាព សុភាព នៅមន្ទីរសិល្បៈគឺត្រូវបំផុសឲ្យមានការទាក់ទងឲ្យមានការដឹកជញ្ជូនសម្ភារពីកន្លែងមួយទៅកន្លែងមួយទៀត និងលើកទឹកចិត្តឲ្យបុរសនិងស្ត្រីស្រឡាញ់គ្នា ។ ពេលនោះ សុភាព បានប្រព្រឹត្តិខុសសីលធម៌ជាមួយកម្មាភិបាលម្នាក់ឈ្មោះ ម៉ៅ ។ កិច្ចការបន្ទាប់ទៀតរបស់ សុភាព គឺត្រូវកែប្រែខ្លឹមសារសិល្បៈចម្រៀង និងបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាជនតាមភូមិ ។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៧២ សុភាព ត្រូវបានចាត់តាំងឲ្យមកធ្វើការនៅមន្ទីរសិល្បៈភូមិភាគពិសេសវិញ ហើយក្រោយមក ឪពុករបស់ សុភាព បានណែនាំឲ្យ សុភាព ស្គាល់ខ្សែ សេ.អ៊ី.អា របស់គាត់ទៀតគឺ សុទ្ធ, ឡុង និង ដា ។ ពេលនោះដែរ សុភាព បានខិតខំកសាងកម្លាំងបន្ថែមទៀតដូចជា រឿន, រៀម, ឃឹម និង យ៉ាន ហើយ សុភាព បានខទ្មសនាមមិត្តថ្មីទាំងនេះឲ្យចូល សេ.អ៊ី.អា ។

នៅខែមករា ឆ្នាំ១៩៧៣ ពេលក្រុម សុភាព ចុះទៅដល់សម្តែងសិល្បៈក្នុងភូមិចេកតំបន់២៥ សុភាព បានជួបជាមួយឪពុក ។ ឪពុករបស់ សុភាព បានណែនាំគាត់ឲ្យទាក់ទងជាមួយ សេ.អ៊ី.អា ម្នាក់ទៀតឈ្មោះ ជ័យ ។ ពេលនោះដែរ សុភាព បានជួបជាមួយជាមួយ ស្រៀង ដែលជាអតីតគ្រូបង្រៀននៅកោះធំ ហើយ ស្រៀង គឺជាអ្នកធ្លាប់ចុះឡើងទិញសម្ភារពីស្រុកវៀតណាម ។

ថ្ងៃបន្ទាប់ ស្រៀង បានហៅបក្ខពួក សុភាព ទៅចូលរួមប្រជុំ ដើម្បីនិយាយពីផែនការនិងសកម្មភាពដែលត្រូវធ្វើ ។ ពេលជួបជុំគ្នា ស្រៀង បានណែនាំឲ្យ សុភាព និង ខ្សែសេ.អ៊ី.អា ទាំងអស់សហការគ្នាដើម្បីធ្វើសកម្មភាព ។ សុភាព បានសសេរថា «ស្រៀង បានបន្តទៀតថា យើងទាំងអស់គ្នាត្រូវតែមានផែនការកែខ្លឹមសារសិល្បៈទាំងខ្លឹមសារចម្រៀងទាំងរូបភាពឲ្យបម្រើសកម្មភាពសេ.អ៊ី.អា» ។

រំលងបានមួយខែក្រោយមក ស្រៀង បានទៅជួបជាមួយបក្ខពួកផ្សេងទៀតដើម្បីពិភាក្សា រឿងផែនការ ។ ថ្ងៃបន្ទាប់ ស្រៀង បានហៅបក្ខពួក សុភាព ទៅផ្សព្វផ្សាយពីផែនការថ្មីដោយត្រូវកម្ទេចក្បាលម៉ាស៊ីនដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ រំលងបានប្រាំថ្ងៃក្រោយមក បក្ខពួករបស់ សុភាព បានធ្វើសកម្មភាពនៅក្នុងក្រុមសិល្បៈដោយធ្វើឲ្យមានភាពច្របូកច្របល់ ។

ដប់ថ្ងៃក្រោយមក ស្រៀង នាំបក្ខពួក សុភាព ឲ្យស្គាល់ខ្សែរយៈរបស់គាត់ផ្សេងទៀតគឺ សឿន, ហេង, ស្រេង, ម៉ៅ, និងសំណាង ។ ស្រៀង បានខទ្មេសនាមឈ្មោះទាំងប្រាំនាក់នេះឲ្យ សុភាព ស្គាល់រួច សុភាព បាននិយាយបំផុសគាត់ឲ្យធ្វើសកម្មភាពក្នុងភូមិដូចជា ១) កសាងកម្លាំង និងអូសទាញកម្លាំងឲ្យបានច្រើន ២) បំផុសថាកុម្មុយនីស្តមានភាពចាស់គម្រិល ហើយថាអាមេរិកជាមហាអំណាចនឹងទម្លាក់បេ-៥២ឲ្យខ្ទេចកម្លាំងកុម្មុយនីស្តនេះ និង៣) បំផុសប្រជាជនឲ្យមានទំទាស់រវាងគ្នានិងគ្នា និងបង្កភាពច្របូកច្របល់ ។

នៅខែមីនា ឆ្នាំ១៩៧៤ ឪពុករបស់ សុភាព បានហៅ សុភាព ទៅធ្វើការនៅមន្ទីរពេទ្យ២៨ ។ នៅមន្ទីរពេទ្យ សុភាព បានស្គាល់បុរសម្នាក់ឈ្មោះ ជាតិ ដែលបានខទ្មេសនាមនារីម្នាក់ដែលជាខ្សែរយៈរបស់គាត់ឲ្យ សុភាព ស្គាល់គឺឈ្មោះ វើង ។ ក្រោយមកជាតិ ឲ្យ សុភាពសរសេរសំបុត្រមួយយកទៅឲ្យ ខុន ជាអតីតគ្រូបង្រៀននៅភ្នំពេញ បច្ចុប្បន្ននៅសាលាបច្ចេកទេស ដើម្បីសុំជួប ។ រំលងបានពីរថ្ងៃ ខុន បានហៅ សុភាព ទៅប្រជុំដោយក្នុងនោះមាន យន, រីម, វើង ដោយគាត់បានលើកពីផែនការប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាដូចជា១) ត្រូវបំផុសអូសទាញកម្លាំងឲ្យបានច្រើន២) បំផុសប្រជាជនតាមរយៈអ្នកស្គាល់ឲ្យប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាដោយធ្វើគ្រប់សកម្មភាពទាំងអស់ និង៣) បំផុសប្រជាជនឲ្យសម្លាប់យោធាបដិវត្តន៍ដោយបង្កប់ថ្នាំពុលក្នុងបាយ ។ ក្រោយពីឯកភាពគ្នា យន បាននាំ សុភាព ទៅជួបនារីម្នាក់ឈ្មោះ ងួន ។ បន្ទាប់មក ងួន បានដាក់ផែនការឲ្យអនុវត្ត ១) ប្រឆាំងនឹងការចាត់តាំងសហករណ៍ ។២) ត្រូវបំផុសឲ្យប្រជាជនធ្វើការសកម្មភាព ដាក់ថ្នាំពុលក្នុងបាយស្ទុកបញ្ជូនទៅសមរភូមិ និង៣) បំផុសឲ្យប្រជាជន ប្រមូលស្រូវ អង្ករ ជ្រូក មាន់ ដឹកយកទៅលក់នៅផ្សារខត្តុង្គ ។ ក្រោយពីណែនាំរួចយន បានបន្តថា «បើមានការអីឲ្យទៅទាក់ទងគាត់នៅមន្ទីរពេទ្យ» ។ ក្រោយមក បក្ខពួក សុភាព នៅក្នុងមន្ទីរពេទ្យបានរួមគ្នាធ្វើសកម្មភាពកសាងកម្លាំង និងធ្វើសកម្មភាពនៅក្នុងមន្ទីរពេទ្យដោយដាក់សម្បកស្វែងក្នុងថ្នាំគ្រុនចាញ់លាយប្រេងកាតក្នុងសេរ៉ូម និងបន្ទំដាក់ថ្នាំពុល ។

នៅខែមករា ឆ្នាំ១៩៧៦ នៅក្នុងផ្នែកវះកាត់ក្រោយពី សឿន, វន និង សុភាព បំផុសជាបន្តបន្ទាប់មក សុភាព ក្តាប់បានចំណុចខ្សោយដើម្បីកសាងកម្លាំង ។ បន្ទាប់មក សុភាព បាននាំមិត្ត យន និង ណាវ ទៅរុះរើសម្ភារនៅតាមផ្ទះឲ្យច្របូកច្របល់និងយកមកប្រើប្រាស់ផ្ទាល់ខ្លួន ។ បន្ទាប់ពីនោះ សុភាព បានបំផុសឲ្យដើរលួចសម្ភារ ធ្វើឲ្យសឺរ៉ាំង ម្ជុល និងប្រដាប់វាស់កំដៅខូច ។

ពីខែឧសភាដល់ខែកក្កដា ឆ្នាំ១៩៧៦ នៅក្នុងផ្នែកវះកាត់កាន់តែច្របូកច្របល់ សុភាព និង សារ៉ាន់ បានបំផុសឲ្យមានទំនាស់ជាប់ធ្វើឲ្យពេលប្រជុំដោះស្រាយមិនចេះចប់ ហើយរបស់ប្រើប្រាស់ដូចជា សឺរ៉ាំង និងឆ្នាំងចំហុយក៏ធ្វើឲ្យខូចដែរ ។ ចូលដល់ខែកញ្ញា និងតុលា សុភាព បានជួបប្រជុំជាមួយក្រុមសេ.អ៊ី.អា ដើម្បីធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ។

នៅខែមករា ឆ្នាំ១៩៧៧ សុភាព និងបក្ខពួកនៅតាមផ្នែកផ្សេងៗទៅប្រជុំជាមួយបុរសម្នាក់ឈ្មោះ សី ដើម្បីរាយការណ៍ ។ រំលងបានបីថ្ងៃ សឿន និង វន បានហៅបក្ខពួក សុភាព នៅកន្លែងវះកាត់មកប្រជុំ មាន សយ, ណៃ, យន, សីម, ណាវ រួចខទ្មេសនាម គួយ, ចន និង រី ឲ្យស្គាល់ ។ បន្ទាប់មក សឿន បានប្រាប់ថាយើងត្រូវអនុវត្តតាមផែនការចាស់ថែមទៀតពិសេសតាមមុខព្រួញនីមួយៗ ។ ក្រោយពីប្រជុំរួច បក្ខពួក សុភាព បានបំផុសឲ្យមានទំនាស់ជាប់រវាងកម្មាភិបាលពេទ្យ ។ ក្រៅពីនោះ សុភាព និង លីម បាននិយាយពីចំណុចខ្សោយអ្នកជំងឺមកសម្រាកពេទ្យឲ្យមានទំនាស់គ្នាធ្វើឲ្យពេលប្រជុំដោះស្រាយតែពីរឿងទំនាស់នេះ ។

នៅខែឧសភា ឆ្នាំ១៩៧៧ វន បានហៅបក្ខពួក សុភាព នៅផ្នែកវះកាត់ទៅប្រជុំមានយន, រី, ចន, គួយ, ណាវ, សយ, និង លីម ដោយ វន និយាយថា សី បានខទ្មេសនាម នី ជាអតីតគ្រូបង្រៀននៅភ្នំពេញឲ្យស្គាល់ ហើយប្រកាសថា សី បានចាត់តាំងកម្លាំង បឿន, សឿន, សយ, ម៉ៅ ដើម្បីធ្វើសកម្មភាពដើរគោះទ្វារនិងអុកឡុកនៅតាមផ្ទះពេទ្យពេលយប់ៗ ។ បន្ទាប់មក សឿន មានមតិថា ផ្សព្វផ្សាយផែនការដែលទទួលពី សី ត្រូវអូសទាញកសាងកម្លាំងឲ្យច្រើនថែមទៀតនិងបំផុសឲ្យដើរអុកឡុកនៅតាមផ្ទះពេទ្យពេលយប់ដើម្បីឲ្យច្របូកច្របល់នៅក្នុងមន្ទីរពេទ្យ ។ ក្រោយមក សី បានឲ្យ បឿន យកទង់ជាតិសូវៀតទៅដោតនៅមុខមន្ទីរពេទ្យ ហើយរាយការណ៍ទៅ សី ដើម្បីបង្អើលក្នុងមន្ទីរពេទ្យ

ឲ្យច្របូកច្របល់ ។ ក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ដោយសារបក្ខពួក សុភាព ធ្វើសកម្មភាពអុកឡុកនៅក្នុងមន្ទីរពេទ្យខ្លាំងពេក បក្សមានវិធានការតាមដានចាប់ ម៉ៅ និង បឿន ក្រោយមកទៀតចាប់ សី និង យន ដែលក្នុងរយៈពេលនោះបក្សពួក សុភាព ទាំងអស់មិនសូវហ៊ានធ្វើសកម្មភាពដូចពីមុនទេ ។

ក្រោយពី សី ត្រូវបានចាប់ខ្លួន ធុក មានភារៈដឹកនាំខ្សែ សេ.អ៊ី.អា នៅពេទ្យព-១៧ ។ ពេលយប់មួយ សុភាព ក៏បានជួបនឹងឪពុក ហើយឪពុកគាត់បានណែនាំថាត្រូវយកផែនការកម្ទេចបដិវត្តន៍ទៅប្រាប់ ធុក នៅមន្ទីរពេទ្យ ។ ស្អែកឡើង សុភាព ត្រឡប់មកមន្ទីរពេទ្យវិញ ។ រំលងបានមួយថ្ងៃ សុភាព បានទៅជួប ធុក ហើយប្រាប់អំពីផែនការ ។ ដល់ពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ១៩៧៨ ធុក បានហៅបក្ខពួក សុភាព ទៅប្រជុំ ហើយមានមតិថា សព្វថ្ងៃនេះកម្លាំងយើងនៅសល់តិចណាស់ព្រោះបក្សកុម្មុយនីស្តកម្ពុជាតាមដានចាប់ពួកយើងជាបន្តបន្ទាប់ ។ មកដល់ពេលនេះ យើងបានប្រជុំចាត់តាំងបក្ខពួកឲ្យធ្វើសកម្មភាពនៅក្នុងមន្ទីរពេទ្យបន្តទៀតព្រោះសភាពការណ៍ឥឡូវយួនចាប់ផ្ដើមធ្វើសង្គ្រាមវាយចូលកម្ពុជាចាប់ពីខែនេះហើយ ។ ដូច្នេះបក្ខពួករបស់ សុភាព ត្រូវកម្ទេចកម្លាំងកុម្មុយនីស្តពីខាងក្នុងដោយអនុវត្តតាមផែនការ សេ.អ៊ី.អា ដូចជា ១) កសាងកម្លាំងនិងអូសទាញកម្លាំងពីបក្សកុម្មុយនីស្តកម្ពុជាឲ្យច្រើនថែមទៀត ។ ២) ត្រូវអនុវត្តតាមផែនការយកកម្ពុជាទៅបញ្ចូលក្នុងសហព័ន្ធឥណ្ឌូចិនពីខាងក្នុងដើម្បីសហការវាយលុកកម្ពុជា ។ ៣) ត្រូវធ្វើសកម្មភាពវាយកម្ទេចកម្លាំងកុម្មុយនីស្ត ។ ពេលនោះ សភាពការណ៍នៅពេទ្យព-១៧ មានអ្នករបួសចូលច្រើននៅផ្នែកវះកាត់ ហើយ វន និង សុភាព បានបំផុសនៅក្នុងផ្នែកវះកាត់ថា ឥឡូវយួនចូលដីកម្ពុជាកាន់តែជ្រៅហើយ ។ សុភាព និងបក្ខពួកធ្វើយ៉ាងណាដើម្បីឲ្យមន្ទីរពេទ្យជ្រួលច្របល់លែងជឿលើកម្លាំងកងទ័ពដែលនៅការពារខាងមុខ ។ ពេលនោះ សឿន និង សារឿន បានធ្វើសកម្មភាពដើរអុកឡុកនៅពេលយប់ៗរហូតដល់ខែមីនា សឿន និង វន, សារឿន និង ចំរើន ត្រូវបក្សតាមដានចាប់ ។ នៅខែមេសា ឆ្នាំ១៩៧៨ បក្ខពួក សុភាព ត្រូវផ្លាស់ទៅពេទ្យ៦មករាដែលមាន គី, រុំ និង នី ជាខ្សែរយៈទាក់ទងជាមួយ ធុក ដដែល ។ តែសកម្មភាពរបស់ សុភាព នៅមន្ទីរពេទ្យព-១៧នៅតែបន្តជាប់ ។ ក្រោយមក នៅខែឧសភា សុភាព បានទៅជួបឪពុកនៅផ្ទះម្ដាយម្ដងទៀត ហើយពេលនោះ ឪពុករបស់ សុភាព បានណែនាំថា "កូនឯងទៅវិញត្រូវប្រាប់ ធុក ថាត្រូវកសាងកម្លាំងបក្ខពួកនៅក្នុងពេទ្យព-១៧នេះឲ្យធ្វើសកម្មភាពថែមទៀតដើម្បីឲ្យក្នុងមន្ទីរច្របូកច្របល់ពេលយួនវាយលុកចូលភ្នំពេញហើយចាំពុកបញ្ជូនបក្ខពួករបស់ពុកឲ្យទៅធ្វើសកម្មភាពថែមទៀត" ។ នៅខែមិថុនា ឪពុករបស់ សុភាព បានឧទ្ទេសនាម ឈ្មោះ ថេន ឲ្យមកភ្ជាប់ខ្សែជាមួយ ធុក នៅពេទ្យព-១៧ដោយកាលនោះឪពុករបស់ សុភាព ។

នៅខែសីហា ឆ្នាំ១៩៧៨ សុភាព ទៅលេងយាយ ។ ពេលនោះ ឪពុករបស់ សុភាព សួរថាសព្វថ្ងៃ ធុក បានដឹកនាំឲ្យធ្វើសកម្មភាពអ្វីខ្លះ? សុភាព បានលើកផែនការនៅព-១៧ប្រាប់ថាបានបំផុសដើម្បីអូសទាញកម្លាំងនិងកសាងកម្លាំងបំផ្លាញគ្រប់មុខព្រួញ ជាពិសេសនៅកន្លែងវះកាត់បានកម្ទេចកម្លាំងកុម្មុយនីស្តអស់ជាច្រើន ។ បន្ទាប់មក ឪពុក សុភាព បានប្រាប់ថា "យួនចាប់ផ្ដើមមានផែនការវាយចូលកម្ពុជាក្នុងខែនេះម្ដងទៀតដើម្បីរំលំរដ្ឋាភិបាល ដូច្នេះកូនឯងត្រូវបំផុសឲ្យមន្ទីរពេទ្យច្របូកច្របល់ខ្លាំងថែមទៀត ក្នុងពេលយួនកំពុងវាយសម្រុកចូលកម្ពុជា" ។ រំលងបានមួយសប្ដាហ៍ ធុក បានហៅបក្ខពួក សុភាព ទៅប្រជុំរួចនិយាយថាយួនចាប់ផ្ដើមវាយចូលកម្ពុជាដើម្បីរំលំរដ្ឋាភិបាលកម្ពុជា ហើយយើងត្រូវអនុវត្តផែនការដូចតទៅ១) ចាត់តាំងកម្លាំងបក្ខពួកយើងនៅគ្រប់ផ្នែកថែមទៀត ២) បំផុសឲ្យបំផ្លាញសម្ភារពេទ្យថ្នាំពេទ្យណាដែលសំខាន់ៗនៅក្នុងមន្ទីរពេទ្យចោលដើម្បីដល់រដូវប្រាំងកុម្មុយនីស្តខ្វះថ្នាំប្រើ ។ ៣) ត្រូវបំផុសឲ្យចាក់ថ្នាំប្រឡំនិងសម្លាប់អ្នកជំងឺឲ្យបាន១០០ភាគរយទៀតដើម្បីកម្ទេចកម្លាំងកុម្មុយនីស្ត ។ ក្រោយពីប្រជុំរួច សុភាព បានធ្វើសកម្មភាពនៅផ្នែកវះកាត់បំផ្លាញសម្ភារសំខាន់ៗដែលទិញមកពីបរទេស ។

នៅខែកញ្ញា ឆ្នាំ១៩៧៨ សុភាព និង លីម បានបំផ្លាញថ្នាំពេទ្យដោយប្រើខ្ទះខ្ទាយសម្បូរបែបប្រឆាំងនឹងមាត៌ាសន្ទុំសំបែ ។ ក្រោយមក គ្រួសារ សុភាព បានណែនាំថា ត្រូវខំបំផុសឲ្យធ្វើសកម្មភាពខ្លាំងថែមទៀតដើម្បីធ្វើឲ្យកុម្មុយនីស្តកម្ពុជាចាញ់ស្មារតីមិនរួច ។ នៅកន្លែងវះកាត់ឆ្អឹង អង្គការទើបមានសម្ភារ និងថ្នាំពេទ្យល្អៗ

ជាច្រើនពេលនោះ បក្ខពួក សុភាព បានបំផុសថា ថ្នាំពេទ្យមកច្រើនយើងសប្បាយប្រើប្រាស់ណាស់ត្រូវការប្រើថ្នាំមួយមុខណាក៏បានដែរ ។ ក្លួយ កាន់ឃ្លាំងថ្នាំនៅជាន់ទីពីរបានបំផ្លាញថ្នាំអំពូលចោលជាច្រើន ។ ចំណែក សុភាព បានទៅជួប រើន នៅផ្នែកជាន់ផ្ទាល់ដី ហើយនិយាយប្រាប់ថា ត្រូវលាក់ថ្នាំពេទ្យមួយចំនួនទុកផង ហើយថ្នាំណាលាក់មិនបានត្រូវបំផ្លាញចោល ។ សុភាព បានទៅពេទ្យ៦មករា ជាមួយ លីម ហើយសួរ នី និង ភី ថា សព្វថ្ងៃពូមានផែនការអ្វីខ្លះ? នី ឆ្លើយថា កំពុងរៀបចំឯកសារពេទ្យសម្រាប់រៀនទូទាំងប្រទេសដោយរៀបចំឲ្យផ្ទុយនឹងទ្រឹស្តីក្នុងការព្យាបាលជំងឺ និងប្រើថ្នាំដើម្បីឲ្យពេទ្យមករៀន ហើយទៅវិញធ្វើខុស ។

នៅពាក់កណ្តាលខែតុលា នៅផ្នែកផ្ទាល់ដី រើន បានបំផុសឲ្យបក្ខពួកធ្វើឲ្យឆេះអាល់កុលមួយធុងចំនួនប្រាំលីត្រ និងឆេះឃ្លាំងថ្នាំផ្នែកផ្ទាល់ដីនៅពេលយប់ ។ សុភាព និង លីម នៅពេលវះកាត់បានធ្វើឲ្យអ្នកជំងឺពលី ដោយធ្វើឲ្យចេញឈាមច្រើន ហើយឃាត់មិនឈ្នះ និងមួយចំនួនទៀតក្រោយពីវះកាត់ហើយ ដោះស្រាយមិនបានត្រឹមត្រូវ ។ បន្ទាប់មក សុភាព បានទៅជួបនឹងម្តាយ ដោយម្តាយ សុភាព និយាយប្រាប់ថា នៅក្នុងមន្ទីរពេទ្យម៉ែសព្វថ្ងៃបានបំផុសឲ្យធ្វើសកម្មភាពនៅតាមមុខព្រួញចាត់តាំងឲ្យសម្លាប់កម្មករនៅតាមរោងចក្រដែលមកសម្រាកពេទ្យ ហើយត្រៀមសម្ភារដូចជាថ្នាំពេទ្យ អង្ករ សម្រាប់ដឹកចេញក្នុងរដូវប្រាំងនេះ ។

ឪពុក សុភាព បានហៅ សុភាព ទៅជួបនៅក្នុងបន្ទប់មួយនៅខាងក្រោមផ្ទះ អន ដោយមានកងការពារឪពុក សុភាព ម្នាក់ឈ្មោះ អាន និងកងការពារ អន ម្នាក់ទៀតឈ្មោះ ភឿន ។ ឪពុក សុភាព បានប្រាប់អំពីផែនការត្រៀមនៅក្នុងរដូវប្រាំងថា កូនឯងត្រូវត្រៀមទទួលជ័យជម្នះ យួនពិតជាវាយឈ្នះសម្រេចផែនការយកកម្ពុជាទៅបញ្ចូលក្នុងសហព័ន្ធឥណ្ឌូចិននៅក្នុងរដូវប្រាំងនេះហើយ ព្រោះយួនសព្វថ្ងៃមានជំនួយពីសូវៀតជាច្រើន ដូចជាកាំភ្លើងធ្លោងធុនធំ រថក្រោះជាច្រើនគ្រឿង និងយន្តហោះជាច្រើនទៀតសម្រាប់ទម្លាក់នៅកម្ពុជាឲ្យចំក្បាលម៉ាស៊ីនដឹកនាំរបស់កុម្មុយនីស្តនៅភ្នំពេញដើម្បីរំលំរដ្ឋាភិបាលកម្ពុជា ។ ១) ទៅវិញត្រូវបំផុសថាក្នុងរដូវប្រាំងយួនវាយខ្លាំងណាស់ មានត្រៀមទាំងយន្តហោះគ្រាប់បែកមកទម្លាក់នៅកម្ពុជា ។ ២) ពេលអ្នករបួសចូលច្រើនត្រូវបំផុសឲ្យសម្លាប់អ្នកជំងឺ ។ ៣) ពេលយួនវាយខ្លាំងត្រូវកម្ទេចក្បាលម៉ាស៊ីនដឹកនាំកុម្មុយនីស្តនៅក្នុងព-១៧តូចធំទាំងអស់តាមរយៈដាក់ថ្នាំបំពុលក្នុងទឹក ។ ឯថ្នាំចាំពុកឲ្យលើកក្រោយ ពុកបានផ្ញើទុកនៅម្តាយកូនឯងហើយ ។

ចំណែក អន សព្វថ្ងៃ បានបំផុសនៅតាមរោងចក្រហូបបបរប្តូហូបបាយលាយចេក ពោតដំឡូង ។ អន បានកាត់អង្ករនៅតាមរោងចក្រពាក់កណ្តាលទុកក្នុងមួយខែដើម្បីដល់រដូវប្រាំងដឹកចេញទៅឲ្យយួនទាំងថ្នាំពេទ្យ និងអង្ករ ។ បន្ទាប់មក អន បាន ប្រាប់ សុភាព ថា ពូក៏មានរៀបចំផែនការនៅតាមរោងចក្រ ដើម្បីធ្វើឲ្យស្ទះដល់ការងារក្នុងមន្ទីរពេទ្យនៅពេលរដូវប្រាំងនេះ ។ ១) ឲ្យ វ៉ុន ប្រធានរោងចក្រគ-៥ ដកម៉ាស៊ីនសម្រាប់ផលិត ២) សម្ភារពេទ្យដែលសំខាន់ដូចជា ស្បៃ បង់រុំរបួស សំឡី ជាដើមត្រូវឈប់ផលិតសិន ។ បន្ទាប់មក ឪពុក សុភាព និង អន បានបង្ហាញ សុភាព ឲ្យមើលផែនទីភូមិសាស្ត្រដែលត្រូវបើកផ្លូវឲ្យយួនចូលនៅក្នុងរដូវប្រាំងដោយគាត់បង្ហាញថាខាងបូព៌ាត្រូវយួនសំដៅចូលស្វាយរៀង និងតាមដងទន្លេមេគង្គចូលមកទន្លេបួនមុខចូលភ្នំពេញ និងផ្លូវខាងភាគនិរតី ។ ក្រោយពីត្រឡប់មកវិញ សុភាព បានបំផុសសកម្មភាពជាបន្តបន្ទាប់រហូតដល់ថ្ងៃអង្គការចាប់ខ្លួនតែម្តង ។

ចម្លើយសារភាពនេះធ្វើនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៨ មានហត្ថលេខា ឡៃ និងស្នាមផ្តិតមេដៃ និងអ្នកសួរចម្លើយឈ្មោះ នារី សាន់ ម៉ុត ។

**គាត លក្ខិណា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

*មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) តាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត ជារៀងរាល់ថ្ងៃ វេលាម៉ោង ៧:០០-៧:៣០ព្រឹក និង ៧:០០-៧:៣០ល្ងាច ។*

*សូមអរគុណ!*

# អង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត

*អត្ថបទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

*ថ្ងៃនេះ (៣ កុម្ភៈ ឆ្នាំ២០១២) អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត ជាទោសអតិបរិមាដែលមានចែងក្នុងច្បាប់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។*

*ដោយបានទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធចោលការផ្តន្ទាទោសដាក់ពន្ធនាគារ៣៥ឆ្នាំរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ហើយមតិភាគច្រើនលើសលប់របស់អង្គជំនុះជម្រះតុលាការកំពូលបានបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសងសំណងចំពោះការរំលោភលើសិទ្ធិរបស់ កាំង ហ្គេកអ៊ាវ ដោយសារការឃុំខ្លួនខុសនីតិវិធីច្បាប់ដោយតុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលបណ្តឹងសាទុក្ខរបស់ កាំង ហ្គេកអ៊ាវ ដែលបានលើកឡើងថា ខ្លួនមិនស្ថិតនៅក្នុងយុត្តាធិការលើរូបបុគ្គលរបស់តុលាការទេ ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ចំពោះបញ្ហាតើជនជាប់ចោទគឺជាមេដឹកនាំជាន់ខ្ពស់មួយរូប ឬជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចផ្តាច់មុខផ្នែកគោលការណ៍ណែនាំរបស់សហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញាដែលជាអ្នកទទួលខុសត្រូវ ។*

*អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់មិនសមហេតុផលចំពោះស្ថានសម្រាលទោស និងមិនបានផ្តល់ទម្ងន់ឲ្យគ្រប់គ្រាន់ចំពោះស្ថានទម្ងន់ទោសនៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ទោសនៅក្នុងការសម្រេចផ្តន្ទាទោសនោះទេ ។ ពាក់ព័ន្ធនឹងកត្តាស្ថានទម្ងន់ទោស អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជនជាប់ចោទមានតួនាទីជាមេដឹកនាំធំជាងគេនៅមន្ទីរស-២១ ហើយជនជាប់ចោទបានបំពានតួនាទីរបស់ខ្លួន ដោយបានបង្ហាត់បង្រៀនបញ្ញា និងគ្រប់គ្រងទៅលើបុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកទោសដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្ហាញ “ការខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឲ្យមន្ទីរ ស-២១ ដំណើរការទៅបានយ៉ាងរលូន” ដែលជា “ទីកន្លែងសម្លាប់មនុស្សដ៏ធំដោយមានការរៀបចំ” ។*

*អង្គជំនុំជម្រះបានកត់សម្គាល់ថា ចំនួនមនុស្សស្លាប់ដ៏ច្រើនដែល កាំង ហ្គេកអ៊ាវ ជាអ្នកទទួលខុសត្រូវនោះជា (អប្បបរមា ១២.២៧២នាក់) ព្រមទាំងរយៈពេលដ៏វែងនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត (ជាងបីឆ្នាំ) គឺពិតជាធ្វើឲ្យសំណុំរឿងនេះជាសំណុំរឿងមួយដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុតនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ការពិតដែលថាជនជាប់ចោទមិនមែនជាជនកំពូលនៃខ្សែបណ្តាញបញ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនអាចធ្វើជាយុត្តិកម្មក្នុងការកាត់បន្ថយទោសនោះបានទេ ហើយថាមិនមានវិធានណាមួយដែលចែងអំពីកម្រិតនៃការផ្តន្ទាទោសខ្ពស់បំផុតចំពោះចារីដែលត្រូវបានចាត់ទុកជាជនកំពូលនៃខ្សែបណ្តាញបញ្ជានោះទេ ។*

*សំឡេងភាគច្រើនលើសលប់ (ជំទាស់ដោយចៅក្រម ក្លូណូវៀកកា មីឡាត* (Klonowiecka-Milart) *និងចៅក្រម យ៉ាយ៉ាស៊ីងហេ* (Jayasinghe)*) យល់ឃើញទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការអន្តរជាតិឲ្យមានខ្លឹមសារថាការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទគប្បីត្រូវទទួលបានការទូទាត់ពី អ.វ.ត.ក ទោះបីជាមិនមែនជាការរំលោភបំពានរបស់ អ.វ.ត.ក និងទោះបីជាមិនមានការរំលោភលើកិច្ចដំណើរការនីតិវិធីក៏ដោយ ។ អង្គជំនុំជម្រះសាលាដំបូង*

គួរតែបានបដិសេធសុំសំណងរបស់ជនដាប់ចោទរួចទៅហើយ ដោយសារតែការពុំមានស្ថានភាពទាំងពីរនេះ ។

ចៅក្រម ក្លូណូវៀកកា មីឡាត និង ចៅក្រម យ៉ាយ៉ាស៊ីងហេ យល់ឃើញថា ការផ្តល់សំណងគឺជាការទទួលខុសត្រូវរបស់ អ.វ.ត.ក ហើយថាការផ្តល់ឲ្យ កាំង ហ្គេកអ៊ាវ នូវសំណងដោយការកាត់បន្ថយទោសពីការដាក់ពន្ធនាគារអស់មួយជីវិតមកនៅត្រឹមការដាក់ពន្ធនាគារមានកំណត់រយៈពេលត្រឹម៣០ឆ្នាំគឺជាការសមស្រប ។

អង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ព្រមតាមបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមួយផ្នែកដែលបានស្នើសុំឲ្យសម្រេចអំពីពិរុទ្ធភាពពីបទល្មើសច្រើនអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ នៅក្នុងសម្អាងហេតុរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ដោយបានដាក់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាក់លាក់ទៅក្នុងឧក្រិដ្ឋកម្មនៃការធ្វើទុកបុកម្នេញជំនួសឲ្យការសម្រេចអំពីពិរុទ្ធភាពរបស់ កាំង ហ្គេកអ៊ាវ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ដែលតុលាការបានរកឃើញថាគាត់ជាអ្នកទទួលខុសត្រូវ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់ការសម្រេចអំពីពិរុទ្ធភាពបន្ថែមទៀតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ និងបានបញ្ចូលការសម្រេចអំពីពិរុទ្ធភាពបន្ថែមទៀតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ព្រមទាំងអំពើអមនុស្សធម៌ផ្សេងទៀត ។

អង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ព្រមតាមបណ្តឹងសាទុក្ខដែលធ្វើឡើងដោយអ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០នាក់ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលនៅក្នុងសាលក្រម ។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះបានបង្ហាញភស្តុតាងបន្ថែមនៅក្នុងពាក្យសុំរបស់ខ្លួននៅពេលប្តឹងសាទុក្ខ ហេតុដូច្នេះហើយពួកគាត់ត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ។

អង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ពួកគាត់សុំសំណងសមូហភាព និងសំណងផ្លូវចិត្តផងដែរ ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចចងក្រងនិងចុះផ្សាយនៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក នូវរាល់សេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់ការទទួលខុសត្រូវដែលបានធ្វើឡើងដោយ កាំង ហ្គេកអ៊ាវ នៅក្នុងអំឡុងពេលដំណើរការសវនាការរួមទាំងនៅដំណាក់កាលប្តឹងសាទុក្ខផងដែរ ។ រាល់សំណើសុំទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតទាំងអស់ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធចោលដោយសារតែសំណើសុំទាមទារទាំងនោះនឹងមិនអាចបង្ខំឲ្យអនុវត្តបានឬដើម្បីអនុវត្តន៍សំណើសុំទាមទារទាំងនោះបាន ពួកគាត់នឹងត្រូវការជាចាំបាច់នូវធនធានហិរញ្ញវត្ថុរបស់ កាំង ហ្គេកអ៊ាវ ដែលជាជនក្រីក្រ ឬតម្រូវឲ្យមានការបង្គាប់ទៅរដ្ឋកម្ពុជា ។


ឌុច នៅថ្ងៃប្រកាសសាលដីកាបណ្តឹងឧទ្ធរណ៍ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)

# អ្នកចូលរួមថ្ងៃប្រកាសសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង



ប្រាក់ ខន អតីតអ្នកសួរចម្លើយនៅមន្ទីរស-២១



ឧបនាយករដ្ឋមន្ត្រី សុខ អាន ព្រមទាំងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ជាច្រើ



ដើមបណ្តឹងរដ្ឋប្បវេណីតម្រង់ជួរចូលរួមស្តាប់សាលដីកា ឌុច



សិស្ស និស្សិតចូលរួមសវនាការ



ព្រះសង្ឃឈរតម្រង់ជួរចូលរួមសវនាការ

# ០០១ របស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២


ថ្មីនរូបចូលរួមស្តាប់សាលដីកា ឌុច


ប្រជាពលរដ្ឋជួបជុំគ្នាមុនការប្រកាសសាលក្រម ឌុច




ដើមបណ្តឹងរដ្ឋប្បវេណី

# ឌុច ជាប់ពន្ធនាគារអស់មួយជីវិត

នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសសាលដីកាលើសំណុំរឿង០០១ករណីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១ អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលគឺជាការឆ្លើយតបទៅនឹងពាក្យបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ ឌុច និងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។ ពាក្យបណ្តឹងសាទុក្ខដែលបានប្តឹងស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលពិនិត្យលើបញ្ហាយុត្តាធិការបុគ្គល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការប្រកាសទោស ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។

បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដែលបានដាក់ជូនទៅអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ បានសំអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ស្ថានទម្ងន់គ្រប់គ្រាន់ក្នុងការផ្តន្ទាទោសលើជនជាប់ចោទនិងបានផ្តល់ស្ថានសម្រាលទោសហួសហេតុ ។ ឌុច គួរតែត្រូវផ្តន្ទាទោសបន្ថែមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការដាក់ឲ្យទៅជាទាសករ ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការសម្លាប់រង្គាល និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ ។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ មេធាវីការពារក្តីឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងគោលបំណងចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលលើកលែងការចោទប្រកាន់ទៅលើកូនក្តីរបស់ខ្លួនដោយអះអាងថា ឌុច មិនបានស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០៩ ទេ ។ រីឯដើមបណ្តឹងរដ្ឋប្បវេណីបីក្រុមក្នុងចំណោមបួនក្រុមបានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានច្រានចោលសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន និងស្នើសុំឲ្យមានការផ្តល់នូវសំណងផ្លូវចិត្តនិងសំណងសមូហភាពដែលមានលក្ខណៈសមរម្យទៅតាមការចង់បានរបស់ជនរងគ្រោះ ។

អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចផ្តន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ក៏ប៉ុន្តែទោសនេះត្រូវបានកាត់បន្ថយរយៈពេលប្រាំឆ្នាំជាការទូទាត់ចំពោះការឃុំឃាំងជនជាប់ចោទដោយខុសនីតិវិធីច្បាប់ដោយតុលាការយោធា និងរយៈពេល១១ឆ្នាំ ដែល ឌុច ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងពន្ធនាគាររបស់តុលាការយោធា និងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សាលដីការបស់អង្គជនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកពាក្យបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដោយបដិសេធសេចក្តីសម្រេចនៅក្នុងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០របស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំដោយមតិភាគច្រើនលើសលប់ ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានបដិសេធចោលនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការដំបូងដែលបានផ្តល់សំណងចំពោះការរំលោភសិទ្ធិរបស់ ឌុច ដោយសារការឃុំខ្លួនខុសនីតិវិធីច្បាប់ ដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ។ ពាក្យបណ្តឹងសាទុក្ខរបស់ ឌុច ដែលលើកឡើងថាខ្លួនមិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថាការកំណត់ថាជនជាប់ចោទ ឌុច ជាមេដឹកនាំជាន់ខ្ពស់ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺជាសមត្ថកិច្ចផ្តាច់មុខរបស់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតនិងបានបដិសេធទាំងស្រុងទៅលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ឌុច ទាក់ទងនឹងយុត្តាធិការលើរូបបុគ្គល ។ ពាក់ព័ន្ធនឹងសេចក្តីសម្រេចឲ្យមានស្ថានសម្រាលទោសរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើរូប ឌុច អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលដោយសម្អាងថាអង្គជំនុំជម្រះសាលាដំបូងបានផ្តល់នូវការសម្រាលទោសទៅដល់ជនជាប់ចោទ ឌុច ដោយមិនសមហេតុផលនិងបានខកខានក្នុងការបន្ថែមនូវទម្ងន់ទោសឲ្យបានគ្រប់គ្រាន់ចំពោះអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែល ឌុច បានប្រព្រឹត្តនៅអំឡុងពេលដែលខ្លួនមានតួនាទីធំជាងគេនៅមន្ទីរស-២១ ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបន្ថែមទម្ងន់ទោសចំពោះ ឌុច ឲ្យដល់កម្រិតអតិបរមានៃទោសគឺដើម្បីដាក់ទោសឲ្យសមទៅនឹងឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្តនិងដើម្បីធ្វើឲ្យរាងចាល ។ ឌុច ដែលមាននាទីជាប្រធានមន្ទីរសន្តិសុខស-២១បានបំពានតួនាទីរបស់ខ្លួនដោយបានបង្ហាត់បង្រៀន បញ្ជា និងគ្រប់គ្រងទៅលើបុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកទោសដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យដោយបានបង្ហាញពីការខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឲ្យមន្ទីរស-២១ដំណើរការទៅបានយ៉ាងរលូន ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការប្រកាសដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំដោយអង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លុះបញ្ចាំងឲ្យបានសមរម្យទៅនឹងឧក្រិដ្ឋកម្ម និងស្ថានភាពបុគ្គលរបស់ កាំង ហ្គេកអ៊ាវ ឡើយ ។

អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថាមានកំហុសអង្គច្បាប់ដែលបានស្រូបបញ្ចូលនូវបទឧក្រិដ្ឋកម្មមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងបទល្មើសធ្វើទុកបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយជំនួសវិញដោយការសម្រេចដាក់ពិរុទ្ធភាពលើ ឌុច ពីបទឧក្រិដ្ឋកម្មមូលដ្ឋាននីមួយៗទាំងអស់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានរកឃើញថាជាការទទួលខុសត្រូវរបស់ ឌុច ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់ការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងសម្រេចដាក់ពិរុទ្ធភាពបន្ថែមទៀតពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) ធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ទាក់ទងនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណីចំនួនដប់រូប ក្នុងចំណោម២២រូបដែលធ្លាប់ត្រូវបានច្រានចោលនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដោយអង្គជំនុំជម្រះសាលាដំបូង ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងដប់រូបដែលទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលរួមមាន ១) លី ហ៊ បោ អ៊ា ហ៊ ២) ហ៊ឹម មុំ ៣) ឆាយ កន ៤) ហុង សាវ៉ាត ៥) ភោគ ខន ៦) ម៉ែន សុធា ៧) ឈឹម ស៊ីថា ៨) ណាំ ម៉ុន ៩) វ៉ែតឆាល យុស៊ូ និង១០) ជែម ជីហ្ស៊ី ។ រីឯពាក្យបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសំណើទាមទារសំណងផ្លូវចិត្តនិងសមូហភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចចងក្រងនិងផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវរាល់សេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់ការទទួលខុសត្រូវដែលធ្វើឡើងដោយ ឌុច នៅអំឡុងពេលដំណើរការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង និងនៅអង្គជំនុំជម្រះតុលាការកំពូល ។ ចំណែកឯសំណើសុំទាមទារសំណងផ្សេងទៀតត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធចោលដោយសារតែសំណើទាំងអស់នោះមិនអាចអនុវត្តបាននិងទាមទារឲ្យមានការចំណាយធនធានហិរញ្ញវត្ថុរបស់ ឌុច ដែលមិនមានលទ្ធភាពអាចចេញសងបាន ហើយសំណើមួយចំនួនក៏ជាការបន្ទាប់ចំពោះរដ្ឋរបស់កម្ពុជា ។

សាលដីការបស់អង្គជនុំជម្រះតុលាការកំពូលនឹងក្លាយទៅជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយសម្រាប់ប្រទេសកម្ពុជា ហើយក៏ជាសេចក្តីសម្រេចចុងក្រោយលើកដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលសម្រេចពីជោគវាសនារបស់អ្នកទទួលខុសត្រូវមួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ **លីម ច័យផល្គុ**

# សាលដីកាចុងក្រោយក្នុងសំណុំរឿង ឌុច : យុត្តិធម៌ និង មនុស្សជាតិ

*អំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅប្រទេសកម្ពុជាបានកន្លងទៅជាងសាមសិបឆ្នាំមកហើយ និងបណ្តាលឲ្យមនុស្សប្រមាណពីរលាននាក់ស្លាប់បាត់បង់ជីវិតដោយការសម្លាប់ ការបង្អត់អាហារ និងការធ្វើការងារហួសកម្លាំង ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ប្រជាជនកម្ពុជាបានរងគ្រោះទាំងផ្លូវកាយនិងផ្លូវចិត្តពីរបបប្រល័យពូជសាសន៍នេះ ។ ប្រជាជនទាំងឡាយដែលមានសមាជិកគ្រួសារស្លាប់បាត់បង់ជីវិតនិងអ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហមបានរង់ចាំនូវវិធានការយុត្តិធម៌មួយដើម្បីជួយឲ្យគាត់បានសះស្បើយ និងផ្សះផ្សាពីអតីតកាល ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអាណត្តិរបស់ខ្លួនក្នុងការស្វែងរកការពិតនិងផ្តល់យុត្តិធម៌ទៅដល់ប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាដែលរួចរស់ជីវិតពីរបបខ្មែរក្រហមរួមទាំងអ្នកទាំងឡាយដែលធ្លាប់បានបម្រើខ្មែរក្រហមបានព្យាយាមស្វែងយល់ពីរឿងរ៉ាវទាំងឡាយដែលបានកើតឡើងចំពោះខ្លួននិងគ្រួសាររបស់ខ្លួន ។ ប្រជាជនជាច្រើនខំប្រឹងប្រែងពង្រឹងកម្លាំងស្តារតម្លៃជាមនុស្សនិងស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរដែលបានបាត់បង់ទៅក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ។ ខណៈដែលជនរងគ្រោះបានរង់ចាំជាយូរ ដើម្បីទទួលបានយុត្តិធម៌ អតីតកម្មាភិបាលខ្មែរក្រហមក៏បានខិតខំប្រឹងប្រែងដើម្បីទទួលស្គាល់នូវកំហុសរួមមួយព្រមទាំងជួយប៉ះប៉ូវនូវអ្វីដែលបានបាត់បង់ ។*

## *យុត្តិធម៌ ៖ ការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស*

*ក្នុងរយៈពេលជាងបីទសវត្សរ៍កន្លងមក យុត្តិធម៌សម្រាប់អ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហមត្រូវបានពន្យារពេលដែលនេះបានធ្វើឲ្យប្រជាជនរស់នៅក្នុងអតីតកាលដ៏គួរឲ្យឈឺចាប់ខ្លោចផ្សា ។ ស្រដៀងគ្នានេះដែរ អតីតកម្មាភិបាលខ្មែរក្រហមដែលនៅរស់រានមានជីវិតក៏មានរឿងប្រហែលគ្នានេះដែរ ។ អតីតកាលបានតាមលងបន្លាចអ្នកទាំងនោះក្នុងរបៀបខុសៗគ្នា ។ នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ក្នុងឋានៈជាមនុស្សជាតិ ជនរងគ្រោះទទួលរងនូវអំពើអមនុស្សធម៌ក្រៃលែង ។ ជនរងគ្រោះត្រូវបានធ្វើឲ្យអាប់ឱននូវសេចក្តីថ្លៃថ្នូរជាមនុស្សនិងទទួលរងនូវការប្រមាថបន្ទាបបន្ថោកជាទម្ងន់ ។ នៅក្នុងសង្គមមួយដែលនីតិរដ្ឋត្រូវបានអនុវត្ត ការការពារនិងការលើកកម្ពស់សេចក្តីថ្លៃថ្នូរនិងភាពជាមនុស្សគឺជាមូលដ្ឋានសំខាន់ឆ្ពោះទៅរកការកសាងមនុស្សជាតិ ។ ពាក្យ “មនុស្សជាតិ” ត្រូវបានប្រើប្រាស់ដើម្បីទទួលស្គាល់នូវតម្លៃនៃភាពជាមនុស្ស ។ នៅក្នុងរបបខ្មែរក្រហមនៅមានទិដ្ឋភាពខុសៗគ្នាជាច្រើនដែលបង្ហាញពីកេរ្តិ៍តំណែលនៃអំពើអនុស្សធម៌របស់មនុស្ស ។ ការបង្ខំឲ្យធ្វើការជាទម្ងន់ ការកាប់សម្លាប់ ការធ្វើទារុណកម្ម និងទិដ្ឋភាពដ៏គួរឲ្យភ័យខ្លាចដទៃទៀតត្រូវបានអនុវត្តដោយបង្ខំទៅលើប្រជាជនកម្ពុជា ។*

*ឧទាហរណ៍ជាក់ស្តែង អំពើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅគុកទួលស្លែង (មន្ទីរស-២១) ស្តែងចេញនូវការប្រព្រឹត្តអំពើអមនុស្សធម៌ជាក់ច្បាស់ចំពោះជនរងគ្រោះដែលអំពើទាំងអស់នោះរួមមាន ការចាប់ចង ការឃុំឃាំង និងការសម្លាប់នៅទីនោះ ។ ចរិតលក្ខណៈដ៏គួរឲ្យភ័យខ្លាចបំផុតរបស់មន្ទីរស-២១ប្រហែលជាដំណើរការលម្អិតនៃការរៀបចំសម្លាប់ដែលប្រព្រឹត្តទៅនៅទីនោះ ។ អ្នកជាប់ឃុំឃាំងត្រូវបានបញ្ជូនទៅទួលស្លែង ថតរូប និងធ្វើការសួរចម្លើយដើម្បីឲ្យអ្នកទាំងនោះធ្វើការសារភាពមុនពេលយកទៅសម្លាប់ ។ រូបថតជនរងគ្រោះទាំងនេះត្រូវបានដាក់តាំងនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃនេះ ។ ទឹកមុខជនរងគ្រោះដែលពោរពេញទៅដោយភាពភ័យខ្លាចបានធ្វើឲ្យមនុស្សមានអារម្មណ៍រន្ធត់លាយឡំជាមួយនឹងកំហឹងដែលអាចធ្វើឲ្យដក់ជាប់នូវរូបភាពរបស់អ្នកស្លាប់រាប់រយនាក់នៅក្នុងចិត្តអ្នកទស្សនា ។ គួរឲ្យរន្ធត់ជាងនោះទៅទៀតនោះគឺថាយើងដឹងថារូបថតទាំងនេះគ្រាន់តែតំណាងឲ្យចំណែកមួយភាគតូចនៃជីវិតទាំងអស់ដែលបាន*

បាត់បង់ទៅដោយសារតែមនោគមវិជ្ជាដ៏ជ្រុលហួសហេតុមួយប៉ុណ្ណោះ ។ អំពើអមនុស្សធម៌និងសាហាវឃោរឃៅដែលបានប្រព្រឹត្តនៅមន្ទីរស-២១ រួមមាន ការបញ្ចូលនូវវិធីសាស្ត្រធ្វើទារុណកម្មប្លែកៗគ្នាជាច្រើន ដូចជា ការឆក់ខ្សែភ្លើង ការដកក្រចក ការវាយនឹងដំបង និងការចាប់អ្នកជាប់ឃុំឃាំងជ្រមុជទឹក ។ ដូចដែលបានរៀបរាប់នៅក្នុងអត្ថបទមួយរបស់ទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីជនរងគ្រោះនៃមន្ទីរស-២១ ជុំ មុី មានប្រសាសន៍ថា នៅពេលដែលគាត់បានបញ្ជូនមកដល់បរិវេណមន្ទីរឃុំឃាំង គាត់ត្រូវខ្មែរក្រហមចងភ្នែក ដាក់ខ្នោះហើយបញ្ជូនទៅបន្ទប់ឃុំឃាំងដែលមានតែធុងផ្ទុកទឹកនោមនិងលាមកតែប៉ុណ្ណោះដែលជាទ្រព្យសម្បត្តិរបស់គាត់ ។ ជុំ មុី ត្រូវបានធ្វើទារុណកម្មដើម្បីដកស្រង់នូវចម្លើយសារភាពហើយ ពេលខ្លះគាត់ត្រូវតែប្រឌិតសាច់រឿងដើម្បីកុំឲ្យអ្នកសួរចម្លើយធ្វើទារុណកម្មមកលើគាត់ខ្លាំងពេក ។ ការចងចាំរបស់ ជុំ មុី ចំពោះអំពើអមនុស្សធម៌ដែលបានប្រព្រឹត្តមកលើរូបគាត់ធ្វើឲ្យគាត់យំនិងមានអារម្មណ៍សោកសៅ ។ វ៉ាន់ណាត ក៏ជាជនរងគ្រោះចេញពីមន្ទីរស-២១ ហើយបានទទួលមរណភាពថ្មីៗនេះមុនពេលដែលគាត់បានទទួលនូវយុត្តិធម៌ ។ វ៉ាន់ណាត បានគូររូបគំនូរដែលបង្ហាញពីទិដ្ឋភាពដ៏គួរឲ្យភ័យខ្លាចនៅកន្លែងធ្វើទារុណកម្មនៅក្នុងមន្ទីរស-២១ ។ រូបគំនូររបស់គាត់បម្រើជាភស្តុតាងបង្ហាញពីអំពើអមនុស្សធម៌នានាដែលបានប្រព្រឹត្តឡើងក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។


ជុំ ម៉ាញ អតីតអ្នកទោសនៅមន្ទីរស-២១

ទោះបីជាយន្តការច្បាប់ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើសាហាវយង់ឃ្នងទៅកាត់ទោសយ៉ាងណាក៏ដោយ ក៏មេដឹកនាំខ្មែរក្រហមទាំងនេះមិនទាន់ទទួលស្គាល់នូវការពិតដែលកំពុងប្រមូលផ្តុំឡើងនៅតុលាការខ្មែរក្រហមនៅឡើយទេ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងអស់នេះមានបំណងធ្វើព្រងើយកន្តើយមិនយកចិត្តទុកដាក់ទៅលើភាពជាមនុស្សរបស់ប្រជាជនកម្ពុជា ។ មេដឹកនាំខ្មែរក្រហម ទាំងអស់នេះផ្តោតជាសំខាន់ទៅលើមនោគមវិជ្ជានិងគោលនយោបាយរបស់ខ្លួនដោយមិនបានពិនិត្យមើលទៅលើប្រជាជនខ្លួនឯងដែលគួរតែទទួលបាននូវការយកចិត្តទុកដាក់ក្នុងនាមជាមនុស្សជាតិ ។ មេដឹកនាំខ្មែរក្រហមទាំងនោះបានជម្រុះចោលនូវសភាពថ្លៃថ្នូររបស់មនុស្សចេញពីជនរងគ្រោះក្នុងគោលបំណងងាយស្រួលក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន ។ ក្នុងការអនុវត្តនូវនីតិរដ្ឋសព្វថ្ងៃនេះ សិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារយ៉ាងពេញលេញរីឯការសន្មតថាមិនមានទោសមុនពេលដែលជនណាម្នាក់មិនទាន់ទទួលការកាត់ទោសត្រូវបានអនុវត្តទាំងស្រុង ។ រឿងដែលគួរឲ្យចាប់អារម្មណ៍នោះគឺថាមេដឹកនាំទាំងនេះបានទាមទារសុំឲ្យមានការការពារសិទ្ធិទាំងអស់នេះ ។ ទោះបីជាយ៉ាងនេះក៏ដោយ មេដឹកនាំខ្មែរក្រហមទាំងនេះភ្លេចថាសិទ្ធិមនុស្សជាមូលដ្ឋានបែបនេះមិនត្រូវបានអនុវត្តឡើយចំពោះជនរងគ្រោះនៃរបបរបស់ខ្លួន ។ ភាពផ្ទុយគ្នានេះរឹតតែបានបង្ហាញយ៉ាងជាក់ស្តែងនៅពេលដែលតុលាការរកឃើញថាអំពើឧក្រិដ្ឋកម្មដែលមេដឹកនាំទាំងនោះបានកំពុងកាត់ទោសពិតជាបានកើតឡើងនៅក្នុងរបបខ្មែរក្រហមមែន ។

សព្វថ្ងៃនេះ ការនាំយកមេដឹកនាំខ្មែរក្រហមដែលបង្កឲ្យមានការបន្ថោកតម្លៃជាមនុស្សរបស់ប្រជាជនរាប់លាននាក់ដែល

បានស្លាប់បាត់បង់ជីវិតទៅនិងអ្នកដែលរស់រានមានជីវិតពិតជាមានសារសំខាន់ណាស់ ។ សំខាន់ជាងនេះទៅទៀតនោះ ការទទួលបានយុត្តិធម៌ជាលើកដំបូងតាមរយៈការកាត់ទោសមេដឹកនាំដ៏សាហាវឃោរឃៅរបស់មន្ទីរស-២១ ។ នៅក្នុងការប្រកាសសាលដីកាចុងក្រោយនៃអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២នេះ ឌុច ត្រូវបានកាត់ទោសឲ្យជាប់គុកមួយជីវិត ។ ជាលើកដំបូងបង្អស់ក្នុងកំណត់ត្រាប្រវត្តិសាស្ត្រខ្មែរ ឧក្រិដ្ឋជនដែលទទួលខុសត្រូវចំពោះអំពើសាហាវព្រៃផ្សៃនៅមន្ទីរឃុំឃាំងនិងសួរចម្លើយត្រូវបានកាត់ទោសឲ្យជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។


អ្នកចូលរួមក្នុងថ្ងៃប្រកាសសាលដីកា ឌុច

ប៉ុន្តែគួរឲ្យសោកស្តាយ យុត្តិធម៌ប្រហែលជាមកយឺតពេលពេកសម្រាប់ជនរងគ្រោះមួយចំនួន ។ ការកាត់ទោស ឌុច ប្រហែលជានឹងត្រូវបានស្វាគមន៍ដោយប្រជាជនកម្ពុជាមួយចំនួនជាពិសេសអ្នកដែលរួចរស់ជីវិតពីមន្ទីរស-២១ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏មានការជជែកដេញដោលថាតើសាលដីកាចុងក្រោយនេះអាចធ្វើឲ្យជនរងគ្រោះទទួលបាននូវយុត្តិធម៌បានកម្រិតណា ហើយជាលទ្ធផលតើសេចក្តីសម្រេចនេះអាចជួយស្តារសេចក្តីថ្លៃថ្នូរជាមនុស្សឲ្យត្រឡប់មកវិញបានកម្រិតណាដែរ ក្នុងខណៈពេលដែលជនរងគ្រោះធ្លាប់ត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ វ៉ាន់ ណាត ដែលជាជនរងគ្រោះម្នាក់ពីមន្ទីរស-២១ដែលបានស្លាប់ទៅមុនពេលទទួលបាននូវយុត្តិធម៌គឺជាឧទាហរណ៍មួយនៃយុត្តិធម៌ដែលទទួលបានយឺតពេល ។ នៅឆ្នាំ២០០៩ វ៉ាន់ ណាត បានឡើងផ្តល់សក្ខីកម្មប្រឆាំងនឹង ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញ ។ សក្ខីកម្មរបស់គាត់នៅតុលាការបានបង្ហាញទៅពិភពលោកថា ការពិតនិងយុត្តិធម៌ពិតជាមានសារសំខាន់ខ្លាំងណាស់ ។ វ៉ាន់ ណាត ត្រូវបានដកស្រង់ពាក្យសម្តីចេញពីសក្ខីកម្មរបស់គាត់យ៉ាងដូច្នេះថា "ខ្ញុំសង្ឃឹមថានៅចុងបញ្ចប់នៃការកាត់ក្តីនេះ យុត្តិធម៌នឹងមានរូបរាងច្បាស់ដែលមនុស្សគ្រប់គ្នាអាចមើលឃើញ" ។ អតីតអ្នកជាប់ឃុំនៅមន្ទីរស-២១ ដូចជា វ៉ាន់ ណាត, ប៊ូ ម៉េង និង ជុំ ម៉ី ទទួលបាននូវការធ្វើបាបស្មើរតែដូចជាសត្វធាតុ ។ វ៉ាន់ ណាត មានប្រសាសន៍ថា "...យើងហូបអាហារជាប់នឹងសាកសពមនុស្ស ហើយយើងក៏មិនខ្វល់ដែរព្រោះពេលនោះយើងមានសភាពដូចជាសត្វធាតុទៅហើយ ។ ខ្ញុំបាត់បង់អស់នូវសេចក្តីថ្លៃថ្នូរជាមនុស្ស" ។ នៅខែកញ្ញា ឆ្នាំ២០១១នេះ វ៉ាន់ ណាត បានចាកចេញពីពិភពលោកនេះទៅរហូតដោយមិនបានដឹងថា ឌុច នឹងត្រូវកាត់ទោសចុងក្រោយឲ្យជាប់ទោសប៉ុន្មានឆ្នាំទេ ។ ក្នុងករណីនេះ យុត្តិធម៌ប្រហែលជាមិនមានរូបរាងច្បាស់ឲ្យមនុស្សគ្រប់រូបឃើញនោះទេ ។ ដូចដែល ប៊ូ ម៉េង ដែលជាជនរងគ្រោះពីមន្ទីរស-២១ ហើយដែលប្រពន្ធរបស់គាត់បានស្លាប់នោះនៅទីនោះបានកត់សម្គាល់ថា ៖ "ខ្ញុំមានអារម្មណ៍ស្តាយក្រោយចំពោះការបាត់បង់ វ៉ាន់ ណាត ។ គាត់ស្លាប់ទៅដោយមិនដឹងថាយុត្តិធម៌បានធ្វើឡើងសម្រាប់គាត់រួចហើយ" ។

ហេតុនេះ យុត្តិធម៌គឺជាវិធានការមួយដែលមិនអាចខ្វះបានចំពោះជនរងគ្រោះ ។ នៅពេលដែលជនរងគ្រោះទទួលបានយុត្តិធម៌ គាត់ប្រហែលជាអាចទុកការចងចាំដ៏គួរឲ្យឈឺចាប់នៅខាងក្រោយ ហើយធ្វើដំណើរឈានទៅមុខ ។ ទោះជាយ៉ាងនេះក៏ដោយ ពាក្យថា

យុត្តិធម៌មានការលំបាកក្នុងការផ្តល់និយមន័យឲ្យតែមួយ ដោយសារតែពាក្យនេះមានន័យខុសៗគ្នាចំពោះមនុស្សខុសគ្នា ។ ចំពោះ វ៉ាន់ ណាត ព្រលឹងរបស់គាត់ប្រហែលជាអាចស្ងប់សុខក្នុងសុគតិភព ដោយបានឃើញឧក្រិដ្ឋជនត្រូវបាននាំយកទៅកាត់ទោស ។ ចំណែកឯ សេក សាយ ដែលជាកូនស្រីរបស់ជនរងគ្រោះនៃមន្ទីរ ស-២១ឈ្មោះ ចាន់ គីមស្រ៊ុន ប្រហែលជាមិនឃើញថាសាលដីកានេះអាចជាសំណងចំពោះជីវិតឪពុកម្តាយនិងប្អូនប្រុសរបស់គាត់នោះទេ ។ សាលដីកានេះអាចជួយឲ្យគាត់បានយល់ពីការពិតខ្លះអំពីអំពើទាំងឡាយដែលបានកើតមានឡើងនៅមន្ទីរស-២១ និងជួយឲ្យគាត់បានឃើញអតីតប្រធានគុកនេះបានមកទទួលខុសត្រូវចំពោះមុខប្រជាជនកម្ពុជា ។ ហេតុនេះ ការបារម្ភ របស់ ប៊ូ ម៉េង ចំពោះភាពយឺតយ៉ាវនៃយុត្តិធម៌នេះពិតជាបើកនូវសំណួរមួយថាតើជនរងគ្រោះទទួលបាននូវយុត្តិធម៌បានកម្រិតណាឬក៏ថាជនរងគ្រោះទទួលបានយុត្តិធម៌ដែរឬទេ ។

## សាលដីកា ៖ កំហុសជាបុគ្គល

បន្ថែមទៅលើឧបសគ្គនៃការបង្កើតតុលាការឧក្រិដ្ឋកម្មក្រោយពីអំពើសាហាវឃោរឃៅបានកើតឡើង ប្រជាជនកម្ពុជាដែលបានរួចរស់ជីវិតត្រូវជួបនឹងឧបសគ្គដែលទាក់ទងទៅនឹងការទទួលខុសត្រូវជាបុគ្គលទៅលើសកម្មភាពទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ចំណុចមួយថាតើការទទួលខុសត្រូវជាបុគ្គលមានភាពចាំបាច់ចំពោះដំណើរធូរស្បើយឬការកាត់បន្ថយពីអារម្មណ៍ថាមានកំហុសចំពោះកម្មាភិបាលថ្នាក់ក្រោមខ្មែរក្រហមដែរឬយ៉ាងណានៅតែជាប្រធានបទមួយក្នុងការពិភាក្សា ។ ជាក់ស្តែង សាលដីការកឃើញថា ឌុច ពិតជាមានទោសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១និងអំពើរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ។ មិនត្រឹមតែសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះទេដែលត្រូវបានជម្រុះចោលនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម ភាពជាមនុស្សរបស់កម្មាភិបាលថ្នាក់ក្រោមរបស់ខ្មែរក្រហមក៏លែងមានតទៅទៀតដែរ ដោយសារតែអំពើដែលកម្មាភិបាលទាំងនោះប្រព្រឹត្តផ្ទាល់ក្នុងពេលដែលខ្លួនធ្វើការគ្រប់គ្រងក្នុងរបបខ្មែរក្រហម ។ នៅមានលក្ខណៈមិនច្បាស់មួយទៀតថា តើការរកឃើញថា ឌុច ជាប់ពិរុទ្ធអាចជួយបន្ធូរបន្ថយនូវអារម្មណ៍ថាមានកំហុសរបស់កម្មាភិបាលខ្មែរក្រហមទាំងនោះឬក៏កម្មាភិបាលទាំងនោះគួរតែទទួលខុសត្រូវខាងសីលធម៌ប្រសិនបើមិនតាមរយៈច្បាប់ចំពោះការឈឺចាប់របស់ជនរងគ្រោះឬយ៉ាងណា ។

ប្រាក់ ខន ជាអតីតកម្មាភិបាលនៅមន្ទីរស-២១ទទួលបន្ទុកក្នុងការសួរចម្លើយអ្នកជាប់ឃុំឃាំងបាននិយាយថា «ខ្ញុំនៅមានអារម្មណ៍ថាខ្មាស់អៀនចំពោះអំពើដែលខ្ញុំប្រព្រឹត្តនៅជំនាន់នោះទោះបីជា ឌុច ត្រូវបានរកឃើញថាមានទោសហើយក៏ដោយ ។ ការសម្រេចទោសនេះជួយឲ្យខ្ញុំធូរអារម្មណ៍បានមួយកម្រិតហើយក៏ជួយកាត់បន្ថយអារម្មណ៍ថាមានកំហុសរបស់ខ្ញុំ ដែលតែងតែតាមលងខ្ញុំជានិច្ចបានខ្លះតែខ្ញុំនៅតែមានអារម្មណ៍ថា អៀនខ្មាស់ចំពោះការពាក់ព័ន្ធរបស់ខ្ញុំនៅមន្ទីរស-២១ដែរ» ។ ប្រាក់ ខន ចង់បោះបង់ចោលរឿងពីអតីតកាលដើម្បីឈានទៅរកការបំភ្លេចភាពអាម៉ាស់នេះ ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ ខន នៅឲ្យតម្លៃទៅលើសារៈសំខាន់នៃការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនជាមួយនឹងក្មេងជំនាន់ក្រោយ ព្រោះការចែករំលែកនេះអាចជួយឲ្យក្មេងៗ «រៀនសូត្រពីមេរៀននេះ» ។

ស្រដៀងគ្នានេះដែរ សោម ម៉េត ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១ បានពន្យល់ពីស្ថានភាពដែលគាត់ត្រូវបានបង្ខំឲ្យធ្វើទៅតាមបញ្ជា ។ សោម ម៉េត បានរៀបរាប់ពីភាពភ័យខ្លាចដែលគាត់ជួបប្រទះពេលដែលគាត់ធ្វើជាកងការពារនៅក្នុងគុក ។ សោម ម៉េត និយាយថា «ខ្ញុំមានអារម្មណ៍ថាខុសក្នុងខ្ញុំធ្លាប់ពាក់ព័ន្ធនៅនិងរួមចំណែកនៅក្នុងអំពើសាហាវឃោរឃៅនេះ ។ ក្រោយពី ឌុច ត្រូវបានរកឃើញថា ជាប់ទោស ខ្ញុំមានអារម្មណ៍ធូរស្រាលហើយអារម្មណ៍ដែលខុសនោះត្រូវបានកាត់បន្ថយមួយផ្នែក» ។ សោម ម៉េត បានបន្តពន្យល់ថា អ្នកជិតខាងរបស់គាត់បានចាប់ផ្តើមយល់ពីបទពិសោធន៍របស់គាត់ដែលគាត់ធ្លាប់ធ្វើការជាមួយខ្មែរក្រហម ។ សោម ម៉េត បន្ថែមថា អ្នកជិតខាងរបស់គាត់ថែមទាំង «លើកទឹកចិត្តឲ្យខ្ញុំផ្តល់សក្ខីកម្មទៅឲ្យតុលាការអំពីបទពិសោធន៍និងអ្វីដែលខ្ញុំបានដឹងពីពេលដែលធ្វើការនៅមន្ទីរស-២១ទៀតផង» ។ ហ៊ឹម ហ៊ុយ ដែលជាអ្នកដឹកអ្នកទោសទៅសម្លាប់នៅវាលពិឃាតជើងឯកនិងជាអនុប្រធានក្រុមអ្នកយាមមន្ទីរស-២១ បាន

សារភាពថា គាត់ធ្លាប់បានសម្លាប់មនុស្សប្រាំនាក់ដោយវាយនឹងព្រនង់ដែក ។ ហ៊ឹម ហ៊ុយ បានរៀបរាប់នៅក្នុងបទសម្ភាសន៍ក្រោយពេលតាមដានការប្រកាសសាលដីកាថា គាត់មានការពេញចិត្តចំពោះការសម្រេចសាលដីកាចុងក្រោយនេះ ដោយសារសាលដីកានេះអាចផ្តល់យុត្តិធម៌ដល់ខ្លួនគាត់ផ្ទាល់និងប្រជាជនកម្ពុជាទូទៅ ។ តម្លៃជាមនុស្សរបស់គាត់ត្រូវបានបាត់បង់ដោយមូលហេតុថាគាត់បានពាក់ព័ន្ធនឹងការសម្លាប់ ។ គាត់ត្រូវទទួលរងនូវការសង្ស័យនិងការស្អប់ពីអ្នកភូមិរបស់គាត់ ។ ដំណើរការតុលាការនេះបានជួយពន្យល់ការពិតនិងស្ថានភាពដែលកម្មាភិបាលថ្នាក់ក្រោមជួបប្រទះ ។ ហ៊ឹម ហ៊ុយ មានយោបល់ថា «ខ្ញុំគិតថាការសម្រេចនេះនឹងមានឥទ្ធិពលជាវិជ្ជមានចំពោះខ្ញុំនិងកម្មាភិបាលថ្នាក់ក្រោមដទៃទៀត ។ សាលដីកានេះនឹងជួយនាំយកសេចក្តីថ្លៃថ្នូរជាមនុស្សត្រឡប់មកវិញ» ។

បន្ថែមលើសារៈសំខាន់នៃការស្វែងយល់ពីការពិតអំពីអ្វីដែលនាំទៅដល់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា និងអ្នកដែលទទួលខុសត្រូវជនរងគ្រោះ ត្រូវការឲ្យកម្មាភិបាលថ្នាក់ក្រោមទទួលការខុសត្រូវតាមផ្លូវស្មារតី និងសីលធម៌ខ្លះទៅតាមអ្វីដែលអាចធ្វើបាន ។ ក្រៅពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ជនរងគ្រោះចង់ឃើញកម្មាភិបាលថ្នាក់ក្រោមទទួលខុសត្រូវខ្លះដូចជាការទទួលស្គាល់នូវការពិតផ្សេងៗ ការបង្ហាញពីឥរិយាបថត្រឹមត្រូវទៅកាន់មនុស្សទូទៅ ការជួយសហគមន៍ និងការចូលរួមក្នុងកម្មវិធីបុណ្យផ្សេងៗ ។

គឹម ហួយ មានអាយុ៦០ឆ្នាំ មកពីខេត្តពោធិ៍សាត់បានបង្ហាញពីអារម្មណ៍គាត់ចំពោះកម្មាភិបាលថ្នាក់ក្រោមយ៉ាងដូច្នេះថា «ខ្ញុំមិនដែលគិតចង់សងសឹកទៅលើកម្មាភិបាលថ្នាក់ក្រោមទេ ដោយសារតែកម្មាភិបាលគ្រាន់តែធ្វើតាមបញ្ជាប៉ុណ្ណោះ ។ ខ្ញុំត្រេកអរដែលកម្មាភិបាលនោះនៅមានជីវិតដើម្បីបកស្រាយការពិតអំពីអ្វីដែបានកើតឡើងនៅទួលស្លែង» ។ គឹម ហួយ បានបញ្ចេញយោបល់ចំពោះអ្វីដែលកម្មាភិបាលថ្នាក់ក្រោមបាននិយាយ «អ្នកទាំងនោះមិនគួរមានអារម្មណ៍ខ្មាស់អៀនចំពោះអ្វីដែលគាត់ធ្វើទេ ។ ក្នុងស្ថានភាពបែបនោះ កម្មាភិបាលខ្មែរក្រហមភាគច្រើនគ្មានជម្រើសទេ តែត្រូវថ្នាក់លើបញ្ជាឲ្យធ្វើ ។ ខ្ញុំមិនដែលមានអារម្មណ៍ស្អប់អ្នកទាំងនោះទេ» ។ ពៅ ស៊ីនួន មកពីខេត្តពោធិ៍សាត់ដែរបានចែករំលែកនូវទស្សនៈស្រដៀងគ្នានេះដែរ ។ ពៅ ស៊ីនួន និយាយថា «ចំពោះអ្នកថ្នាក់ក្រោមនៅតាមមូលដ្ឋានទាំងនោះខ្ញុំបានអភ័យទោសឲ្យគាត់ហើយ ពីព្រោះគាត់បានទទួលស្គាល់ការពិត ហើយគាត់បានចូលរួមក្នុងការជួយសហគមន៍និងធ្វើបុណ្យទានជាមួយជនរងគ្រោះ ។ អ្នកទាំងនោះក៏បានចូលបុណ្យជួយវត្តអារាមនិងសហគមន៍ដែរ ។ គាត់ព្យាយាមសាងអំពើល្អ» ។

វាប្រហែលជារឿងមួយពិបាកសម្រាប់អ្នកដែលមានសមាជិកគ្រួសារស្លាប់នៅមន្ទីរស-២១ ឲ្យទទួលបាននូវសេចក្តីស្ងប់ក្នុងអារម្មណ៍ជាមួយនឹងរឿងអតីតកាល ។ នង ចាន់ផល ដែលជាក្មេងម្នាក់ដែលរួចរស់ជីវិតពីមន្ទីរស-២១ បានបាត់បង់ឪពុកម្តាយរបស់គាត់នៅមន្ទីរដ៏ឃោរឃៅនោះ ។ គាត់ត្រូវបានខ្មែរក្រហមបញ្ជូនទៅទីនោះជាមួយម្តាយរបស់គាត់ ។ កាលពីដំបូង



នង ចាន់ផល (រូបឈរ) និង ហ៊ឹម ហ៊ុយ ចូលរួមស្តាប់សាលដីកា ឌុច

នង ចាន់ផល ហាក់ដូចជាពិបាកនឹងប្រឈមមុខជាមួយអតីតកាលដ៏ឈឺចាប់ដែលបានកើតឡើងមកលើរូបគាត់និងក្រុមគ្រួសាររបស់គាត់ណាស់ ។ ពេលវេលានិងដំណើរការរបស់តុលាការបានជួយឲ្យរូបគាត់បានធូរស្រាលពីអតីតកាលដ៏ជូរចត់ទាំងនោះ ។ វាក៏បានជួយគាត់ឲ្យរកឃើញនូវការបញ្ចប់អំពីអតីតកាលដែរ ។ តាមរយៈយុត្តិធម៌ដែលទទួលបាន នង ចាន់ផល សង្ឃឹមថានឹងអាចធ្វើការផ្សះផ្សាជាមួយអតីតកាល ។ គាត់ក៏បានបញ្ជាក់ផងដែរទាក់ទងនឹងតួនាទីរបស់សាលដីកានៅក្នុងដំណើរការនៃការផ្សះផ្សាថា "ខ្ញុំគិតថាកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមក៏ជួបប្រទះនូវការលំបាកក្នុងការប្រឈមមុខជាមួយអតីតកាលដោយសារតែកម្មាភិបាលទាំងនោះបានរស់នៅជាមួយអតីតកាលអស់រយៈពេលជាងសាមសិបឆ្នាំមកហើយ ។ គាត់ពិតជាពិបាកក្នុងការចាកចេញឲ្យឆ្ងាយអំពីការចងចាំដ៏គួរឲ្យរន្ធត់ទាំងនោះ ។ ខ្ញុំគិតថាសាលដីកានេះនឹងជួយផ្តល់នូវតម្លៃជាមនុស្សដល់គាត់នៅពេលដែលសាធារណជនបានឃើញថាអំពើសាហាវឃោរឃៅដែលបានកើតឡើងនោះគឺត្រូវបានទទួលខុសត្រូវតាមផ្លូវច្បាប់ ដោយមេដឹកនាំខ្មែរក្រហមត្រូវបានតុលាការកាត់ទោសដើម្បីបង្ហាញការពិត ។ អ្នកជិតខាងរបស់កម្មាភិបាលថ្នាក់ក្រោមទាំងនេះនឹងបានយល់ពីគាត់ច្រើនជាងនេះ" ។ នង ចាន់ផល ក៏យល់ស្របផងដែរថា កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមគួរតែធ្វើអំពើល្អដើម្បីរំដោះខ្លួនឲ្យរួចផុតពីការឈឺចាប់ពីអតីតកាល និងដើម្បីឲ្យកូនៗរបស់ខ្លួនមានអារម្មណ៍ល្អចំពោះខ្លួន ។

ការស្វែងយល់ពីបទពិសោធន៍ជីវិតរបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមគឺជាជំហានដ៏ចាំបាច់មួយសម្រាប់ដំណើរការផ្សះផ្សា ។ ដំណើរការរបស់តុលាការបានចូលរួមចំណែកក្នុងការផ្តល់ឱកាសដល់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមបានចូលរួមចែករំលែកពីបទពិសោធន៍ផ្ទាល់ខ្លួននិងហេតុផលដែលអ្នកទាំងនោះសម្រេចចិត្តចូលរួមបដិវត្តន៍ខ្មែរក្រហម ។ តុលាការក៏បានផ្តល់ឱកាសដល់ជនរងគ្រោះឲ្យបានឃើញពីមុខមាត់នៃមេដឹកនាំខ្មែរក្រហមដែលបានដឹកនាំប្រទេសឲ្យធ្លាក់ទៅក្នុងអំពើប្រល័យពូជសាសន៍ ។ ចេញពីការសិក្សាស្វែងយល់ពីបទពិសោធន៍ផ្សេងៗគ្នារបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម និងពីដំណើរការរបស់តុលាការអ្នកដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហមហាក់ដូចជាបានយល់ស្របផងដែរថា វិធានការផ្នែកច្បាប់គឺជាវិធានការមួយក្នុងចំណោមវិធានការផ្សេងៗទៀតដែលសំខាន់នៅក្នុងដំណើរការជួយលុបលាងនិងផ្តល់តម្លៃដល់អ្នកដែលបានបាត់បង់តម្លៃនិងសេចក្តីថ្លៃថ្នូរដោយសារតែគោលនយោបាយរបស់ខ្មែរក្រហម ។

## សេចក្តីបញ្ចប់

កេរដំណែលដែលរបបខ្មែរក្រហមបានបន្សល់ទុកមកគឺជាស្លាកស្នាមដ៏ជ្រៅដ៏ធំមួយដែលបានបន្សល់ទុកនៅលើខ្លួនបុគ្គលគ្រប់រូបនិងបានជះឥទ្ធិពលអវិជ្ជមានទៅលើជីវិតរបស់អ្នកដែលបានរស់រានមានជីវិតក៏ដូចជាអតីតកម្មាភិបាលខ្មែរក្រហម ។ ទាំងអ្នកដែលរស់រានមានជីវិត និងអតីតកម្មាភិបាលខ្មែរក្រហមសុទ្ធតែសង្ឃឹមថាវិធានការតាមផ្លូវច្បាប់អាចជួយលុបបំបាត់"វប្បធម៌និទណ្ឌភាព" នៅកម្ពុជាដោយការនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតមកប្រឈមមុខនឹងយុត្តិធម៌ ។ សម្រាប់ជនរងគ្រោះការទទួលបានយុត្តិធម៌គឺមានសារៈសំខាន់ណាស់សម្រាប់ដំណើរការដ៏វែងឆ្ងាយក្នុងការបញ្ចប់និងការទទួលបានការផ្សះផ្សាជាមួយអតីតកាល ។ ប៉ុន្តែយុត្តិធម៌មិនមែនសម្រាប់តែជនរងគ្រោះប៉ុណ្ណោះទេ វាក៏សំខាន់ផងដែរសម្រាប់ការកសាង និងការពង្រឹងប្រទេសជាតិ ។ តាមរយៈយុត្តិធម៌អ្នកដែលនៅរស់រានមានជីវិតមួយចំនួនយល់ថាការឈឺចាប់របស់ខ្លួនត្រូវបានទទួលស្គាល់ហើយភាពថ្លៃថ្នូរជាមនុស្សរបស់ខ្លួនក៏ត្រូវបានផ្តល់តម្លៃ ។ ស្រដៀងគ្នានេះដែរ កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើសាហាវឃោរឃៅក៏មានអារម្មណ៍ថាការទទួលស្គាល់ការពិតនិងយុត្តិធម៌ដែលត្រូវបានផ្តល់ឲ្យតាមរយៈតុលាការព្រហ្មទណ្ឌគឺពិតជាសំខាន់សម្រាប់គាត់ក្នុងការធ្វើដំណើរឆ្ពោះទៅមុខដោយចេញពីអតីតកាលនិងផ្សារភ្ជាប់ខ្លួនរបស់អ្នកទាំងនោះទៅក្នុងសង្គមវិញ ។

បច្ចុប្បន្ននេះ សកម្មភាពរបស់អតីតកម្មាភិបាលគឺសំខាន់ណាស់ក្នុងការកសាងទំនុកចិត្តនៅក្នុងសហគមន៍របស់ខ្លួន ។ ការយល់ដឹងពីអតីតកាលគឺជាកត្តាចម្បងសម្រាប់ជនរងគ្រោះនិងអតីតកម្មាភិបាលថ្នាក់ក្រោមក្នុងការឲ្យតម្លៃគ្នាទៅវិញទៅមកក្នុងនាមជាមនុស្ស ។

**ស៊ុិ សាទីណា**

# យុត្តិធម៌សម្រាប់អតីតអ្នកទោសលេខ៥៧០

បន្ទាប់ពីធ្វើដំណើរអស់ប្រមាណជាពីរម៉ោងតាមផ្លូវថ្នល់កៅស៊ូនិងផ្លូវលោក់ពោរពេញដោយធូលីខ្លះៗ យើងបានទៅដល់ផ្ទះរបស់អតីតអ្នកទោសស-២១ដែលពាក់ស្លាកលេខ៥៧០ ។ អ្នកទោសនោះឈ្មោះ ប៊ូ ម៉េង ។ ផ្ទះរបស់គាត់ឋិតនៅភាគខាងត្បូងទីក្រុងភ្នំពេញចម្ងាយ៦០គីឡូម៉ែត្រតាមដងទន្លេបាសាក់ក្នុងស្រុកកោះធំ ខេត្តកណ្ដាល ។ ប៊ូ ម៉េង បានរស់នៅទីនេះចាប់តាំងពីឆ្នាំ១៩៧៩មក ។ ប្រពន្ធរបស់គាត់ឈ្មោះ ម៉ា យឿន ត្រូវបានបញ្ជូនទៅមន្ទីរស-២១ជាមួយនិងគាត់ដែរ តែគាត់មិនបានរស់រានមានជីវិតពីមន្ទីរនេះទេ ។ សព្វថ្ងៃ ប៊ូ ម៉េង រស់នៅជាមួយប្រពន្ធទីពីរដែលបានរៀបការក្នុងឆ្នាំ១៩៩០ ព្រមទាំងកូនចំនួនប្រាំនាក់ ។

ថ្ងៃដែលយើងទៅផ្ទះរបស់ ប៊ូ ម៉េង គឺជាឱកាសពិសេសមួយនៃពិធីឡើងគេហដ្ឋានថ្មីរបស់គាត់ ។ គាត់បានសន្សំប្រាក់អស់រយៈពេលជាច្រើនឆ្នាំដើម្បីផ្ទះមួយនេះ ហើយពិធីនេះគឺប្រារព្ធឡើងដើម្បីជាការស្វាគមន៍ដល់ផ្ទះថ្មីដែលមានកំពស់ពីរជាន់នេះ ។ ភ្ញៀវកិត្តិយសប្រមាណជាងពីររយនាក់ត្រូវបានអញ្ជើញចូលរួមក្នុងពិធី ក្នុងនោះម្នាក់គឺជាមិត្តរបស់គាត់ដែលធ្លាប់ជាប់នៅមន្ទីរស-២១ជាមួយគ្នាគឺ ជុំ ម៉ាញ ។ នៅថ្ងៃនោះ ប៊ូ ម៉េង ស្លៀកពាក់អាវធំពណ៌ខៀវចាស់មើលទៅប្រហាក់ប្រហែលនឹងឯកសណ្ឋានរបស់មេដឹកនាំខ្មែរក្រហមដែលពាក់ដើម្បីទទួលស្វាគមន៍ភ្ញៀវបរទេសដែលអញ្ជើញមកធ្វើទស្សនកិច្ចប្រទេសកម្ពុជាក្នុងរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ដូច្នោះដែរ ។ តែ ប៊ូ ម៉េង មិនបានស្លៀកសម្លៀកបំពាក់នេះដូចមេដឹកនាំខ្មែរក្រហមដើម្បីទទួលភ្ញៀវទេ ។ អ្វីដែលសំខាន់គឺថា ប៊ូ ម៉េង សប្បាយចិត្តដែលគាត់អាចមានថ្ងៃ ។ ប៊ូ ម៉េង បាននិយាយថា "ខ្ញុំជាជនរងគ្រោះសល់ពីស្លាប់ធ្លាប់ហូបបបររាវៗ ។ ខ្ញុំមានសំណាងដែលខ្ញុំនៅរស់រាន" ។ គាត់មានទឹកមុខសប្បាយរីករាយខុសធម្មតាក្នុងថ្ងៃនេះ ហើយគាត់ប្រហែលជាភ្លេចភាពឈឺចាប់កាលពីអតីតកាលពេលដែលគាត់ជាប់ឃុំឃាំងនៅមន្ទីរស-២១មួយរយៈ ។

ពេលខ្ញុំទៅដល់ផ្ទះរបស់គាត់ ប៊ូ ម៉េង បានមកទទួលស្វាគមន៍ដោយក្ដីញញឹមនិងរាក់ទាក់ ហើយចាប់ដៃខ្ញុំក៏ដូចជាភ្ញៀវដទៃទៀតដែលបានអញ្ជើញមកដល់គេហដ្ឋានថ្មីនេះដែរ ។ គាត់មានទឹកមុខសប្បាយរីករាយនិងគ្រេកអរហើយបានចាត់ទុកក្រុមរបស់យើងពិសេសជាងភ្ញៀវដទៃទៀត ។ ខ្ញុំបានប្រាប់គាត់ថា "ផ្ទះរបស់អ៊ំស្អាតណាស់" ហើយពេលនោះគាត់ក៏បានឆ្លើយតបមកវិញដែរថា "ខ្ញុំបានចំណាយពេលពីរឆ្នាំក្នុងការសាងសង់ផ្ទះនេះ ។ ខ្ញុំបានចាប់ផ្ដើមទិញសម្ភារៈបណ្ដើរៗជាមួយនឹងប្រាក់ដែលខ្ញុំបានសន្សំទុក" ។ ពេលនេះ ប៊ូ ម៉េង មានជីវភាពគួរសមហើយគេហដ្ឋានថ្មីរបស់គាត់មានភាពស្អាតជាងផ្ទះរបស់អ្នកភូមិភាគច្រើនដែលរស់នៅ



ប៊ូ ម៉េង

ក្នុងភូមិជាមួយគាត់ដែលភាគច្រើនប្រកបរបរដាំដំណាំនិងធ្វើស្រែ ។

ប្រពន្ធរបស់ ប៊ូ ម៉េង ឈ្មោះ ដួង ឈុនទី អាយុ៥០ឆ្នាំ ដែលស្លៀកសម្លៀកបំពាក់ដូចជាកូនក្រមុំក្នុងថ្ងៃអាពាហ៍ពិពាហ៍ជាមួយនិងគ្រឿងអលង្ការជាច្រើនដូចជាខ្សែកនិងចិញ្ចៀនមាសបានមកទទួលស្វាគមន៍ភ្ញៀវដោយក្ដីសប្បាយរីករាយដែលបានអញ្ជើញមកចូលរួមពិធីឡើងគេហដ្ឋានថ្មីនេះ ។

យ៉ាងណាមិញ ប៊ូ ម៉េង នៅតែនឹកឃើញអតីតកាលជារៀងរាល់ថ្ងៃ ហើយគាត់មានជំនឿថា ពេលនេះជាឱកាសដែលគាត់អាចបង្រៀនដល់ក្មេងជំនាន់ក្រោយអំពីអ្វីដែលកើតឡើងនៅក្នុងមន្ទីរស-២១នេះ ។ គាត់នៅតែមិនអាចបំភ្លេចប្រពន្ធទីមួយរបស់

គាត់ដែលត្រូវបានសម្លាប់ដោយខ្មែរក្រហមនៅមន្ទីរស-២១ឡើយ ។ រាល់ថ្ងៃប៊ូ ម៉េង បានមកកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែលជាអតីតមន្ទីរស-២១ ដើម្បីលក់សៀវភៅដែលមានចំណងជើងថា “ប៊ូ ម៉េង ៖ អ្នកទោសដែលរួចរស់រានមានជីវិតពីមន្ទីរស-២១” ដែលនិពន្ធដោយ ហ៊ុយ វណ្ណៈ បច្ចុប្បន្នជាមន្ត្រីកិច្ចការសាធារណៈរបស់សាលាក្តីខ្មែរក្រហម ហើយដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សៀវភៅនេះនិយាយពីជីវិតរបស់គាត់តាំងពីក្មេងរស់នៅតាមដងទន្លេមេគង្គរហូតមកដល់បច្ចុប្បន្ន ការស្វែងរកយុត្តិធម៌សម្រាប់ខ្លួន និងសង្គមនាពេលអនាគត ។

កើតនៅឆ្នាំ១៩៤១ក្នុងគ្រួសារកសិករមួយ ប៊ូ ម៉េង បានទៅនៅវត្តពេលដែលគាត់មានអាយុប្រាំឆ្នាំ ។ នៅទីនោះ


ប៊ូ ម៉េង ប្រពន្ធ និងកូន នៅក្នុងពិធីឡើងគេហដ្ឋានថ្មី




គាត់បានចាប់ផ្តើមមានចំណាប់អារម្មណ៍ខាងគូរគំនូរ ហើយជំនាញនេះហើយដែលបានជួយជីវិតគាត់កាលពីពេលគាត់ជាប់នៅមន្ទីរស-២១ចាប់ពីខែសីហា ឆ្នាំ១៩៧៧ ដល់ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ពេលដែលរបបខ្មែរក្រហមដួលរលំ ។ សព្វថ្ងៃ រូបគំនូរដែលរៀបរាប់ពីជីវិត និងទង្វើដែលខ្មែរក្រហមធ្វើមកលើរូបគាត់ត្រូវបានដាក់តាំងក្នុងបន្ទប់ទទួលភ្ញៀវនៃគេហដ្ឋានថ្មីនេះដែលគាត់អាចមើលឃើញរូបរាងនេះជារៀងរាល់ថ្ងៃ ។ ប៊ូ ម៉េង បាននិយាយថា “ខ្ញុំរស់នៅជាមួយនឹងអតីតកាល ហើយសព្វថ្ងៃនេះ ខ្ញុំកំពុងតែបង្រៀនពីប្រវត្តិសាស្ត្រដល់សាកលលោកទាំងមូល” ។

កាលពីថ្ងៃទី៣ ខែកុម្ភៈ អតីតប្រធានមន្ទីរស-២១ កាំងហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ការកាត់ទោសនេះបានធ្វើឲ្យ ប៊ូ ម៉េង និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀតរីករាយ ត្រេកអរដោយក្តីពេញចិត្តក្រៃលែង ។ ប៉ុន្តែ ជំហានថ្មីមួយទៀតសម្រាប់យុត្តិធម៌ដ៏ពេញលេញរបស់ ប៊ូ ម៉េង គឺការទទួលបានជីវភាពរស់នៅដ៏ប្រសើរមួយដែលជាតម្រូវការជាមូលដ្ឋានរបស់មនុស្សទូទៅសមនឹងទទួល ។ ប៊ូ ម៉េង ធ្លាប់រស់នៅដោយភាពលំបាកផ្នែកជីវភាពមុនពេលដែលសៀវភៅដែលរៀបរាប់ពីជីវិតរបស់គាត់ត្រូវបានបោះពុម្ពផ្សាយឡើង ។ ប៊ូ ម៉េង និយាយថា “ខ្ញុំមិនអាចរស់នៅដោយពឹងផ្អែកលើប្រាក់បៀវត្សរ៍រដ្ឋចំនួនដប់ម៉ឺនរៀលក្នុងមួយខែតែមួយមុខនោះបានទេ ។ ខ្ញុំត្រូវតែលក់សៀវភៅដែលនិយាយពីប្រវត្តិរបស់ខ្ញុំដើម្បីចិញ្ចឹមជីវិត” ។ បច្ចុប្បន្ននេះ ប៊ូ ម៉េង ប្រកបមុខរបរចិញ្ចឹមជីវភាពរស់នៅដោយសារសៀវភៅប្រវត្តិរូបរបស់គាត់នៅទីកន្លែងដែលគាត់បានទទួលរងនូវភាពឈឺចាប់បំផុតគឺសារមន្ទីរទួលស្លែង ។ ក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ ប៊ូ ម៉េង បានរកប្រាក់ប្រមាណបីម៉ឺនដុល្លារ តាមរយៈការលក់សៀវភៅនេះ ។ ប៊ូ ម៉េង បានពន្យល់ថា “ភ្ញៀវទេសចរខ្លះអាណិតខ្ញុំ ហើយជួយទិញសៀវភៅខ្ញុំ ។ ខ្ញុំមកសារមន្ទីរទួលស្លែងរាល់ថ្ងៃគ្មានលោះថ្ងៃណាឡើយ” ។ សៀវភៅមួយនេះបានជួយធ្វើឲ្យជីវភាពរស់នៅរបស់អតីតអ្នកទោសមន្ទីរស-២១រូបនេះមានភាពប្រសើរជាងមុន ។ នេះគឺជាយុត្តិធម៌ក្នុងភាពជាមនុស្ស ។

**ញាណ សុជាតិ**

# រូបថតមួយសន្លឹកនៅមន្ទីរស-២១នៅដក់ជាប់ក្នុងចិត្តខ្ញុំ

មគ្គុទ្ទេសក៏ទេសចរណ៍ម្នាក់បានប្រាប់ខ្ញុំនៅពេលដែលខ្ញុំមកលេងប្រទេសកម្ពុជាលើកដំបូងថា «ប្រសិនបើអ្នកចង់យល់ពីប្រវត្តិសាស្ត្ររបស់កម្ពុជាឲ្យបានច្បាស់អ្នកគួរតែទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯក» ។ ខ្ញុំបានទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងហើយមានអារម្មណ៍តក់ស្លុតនិងព្រឺខ្លាចដែលបានឃើញសោកនាដកម្មដែលបានកើតឡើងដូច្នេះ ។ រូបថតជនរងគ្រោះបានសម្លឹងមករកខ្ញុំ ហើយរូបថតទាំងនោះបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីទម្ងន់នៃឧក្រិដ្ឋកម្មទាំងនោះ ។ ពេលសម្លឹងមើលរូបថតទាំងនេះជាពិសេសគឺរូបថតស្ត្រីវ័យក្មេងម្នាក់ដែលមានក្រសែភ្នែកពោរពេញដោយទុក្ខសោកហាក់បីដូចជាចង់និយាយប្រាប់ខ្ញុំថា «សូមមើលមកខ្ញុំមក អ្នកអាចឃើញអ្វីដែលខ្មែរក្រហមបានធ្វើចំពោះខ្ញុំហើយ» ។ រូបថតនេះនៅដក់ជាប់ក្នុងចិត្តខ្ញុំជានិច្ច ។

នៅពេលដែលខ្ញុំបានទៅដល់ជើងឯកដំបូងខ្ញុំមានអារម្មណ៍ស្ងប់ស្ងាត់ ពីព្រោះមានតែភ្ញៀវទេសចរប៉ុន្មាននាក់តែប៉ុណ្ណោះ ហើយអ្វីៗគ្រប់យ៉ាងមានសភាពស្ងាត់ជ្រងំ ។ ក្រោយមក ខ្ញុំបានឃើញបូជនីយដ្ឋានរំឭកវិញ្ញាណក្ខន្ធធ្វើពីកញ្ចក់ដែលមានផ្ទុកលលាដ៍ក្បាលនិងសម្លៀកបំពាក់សេសសល់ជាច្រើនរបស់ជនរងគ្រោះ ។ រណ្តៅសាកសពដែលមានកំណត់ចំណាំរៀបរាប់ពីព្រឹត្តិការណ៍អាក្រក់ៗ និងសារមន្ទីរដ៏តូចមួយដែលនៅក្បែរនោះបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីព្រឹត្តិការណ៍ដ៏សាហាវឃោរឃៅដែលបានកើតឡើងនៅទីនោះ ។

ព្រឹត្តិការណ៍និយាយពីសង្គ្រាមនៅវៀតណាមនិងព្រឹត្តិការណ៍ដែលបណ្តាលឲ្យមានសោកនាដកម្មនេះត្រូវបានរាយការណ៍តាមប៉ុស្តិ៍ទូរទស្សន៍អាល្លឺម៉ង់ជាញឹកញាប់ ។ ជារៀងរាល់ថ្ងៃ ភាពព្រឺខ្លាចបានកើតមានឡើងដែលវិវត្តទៅជារបប ប៉ុល ពត ។ ចាប់ពីពេលនោះមក ខ្ញុំបានចាប់អារម្មណ៍លើប្រទេសកម្ពុជា ។ ខ្ញុំមិនគិតស្មានថា ខ្ញុំបានមកទស្សនាប្រទេសកម្ពុជាទេ ។ ឥឡូវនេះខ្ញុំទស្សនាបានប្រាំកន្លែងហើយ ។ នៅក្នុងអំឡុងដំណើរទស្សនកិច្ចលើកទីពីររបស់ខ្ញុំមកប្រទេសកម្ពុជា ខ្ញុំបានមកទស្សនាគុកទួលស្លែងម្តងទៀត ។ ខ្ញុំបានជម្នះភាពអៀនខ្មាសរបស់ខ្ញុំ ហើយបានថតរូបស្ត្រីវ័យក្មេងដែលមានក្រសែភ្នែកពោរពេញដោយទុក្ខសោកនោះ ។ ខ្ញុំបានគិតក្នុងចិត្តថា «តើស្ត្រីម្នាក់នេះអាចនៅរស់រានមានជីវិតដែរឬទេ» ។ យ៉ាងណាមិញ ខ្ញុំមិនគិតថាការស្វែងរកព័ត៌មានពីជនរងគ្រោះនេះអាចធ្វើទៅបានទេ ។


បងប្រុសទាំងពីររបស់អ្នកទោស អ៊ុច សាមិន

បន្ទាប់ពីដំណើរទស្សនកិច្ចកាលពីខែមករា ឆ្នាំ២០១១ ខ្ញុំចាប់ផ្តើមមានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីគុកទួលស្លែងដែលខ្ញុំបានទៅទស្សនាម្តងទៀតនោះ ដោយត្រឡប់មកកាន់ប្រទេសអាល្លឺម៉ង់វិញជាមួយនឹងសៀវភៅមួយក្បាលដែលមានចំណងជើងថា «កុមារនៃរបបវាលពិឃាត» ។ សៀវភៅនេះគឺជាការស្រាវជ្រាវ និងការចងក្រងឯកសាររបស់អ្នកសារព័ត៌មានជាតិអាល្លឺម៉ង់ដ៏ល្បីម្នាក់ឈ្មោះ អេរិច ហ្វូឡាថ (Erich Follath) ។ នៅពេលអានសៀវភៅនោះ ខ្ញុំបានមើលឃើញលទ្ធភាពដើម្បី

ស្វែងយល់ពីប្រវត្តិរបស់ស្ត្រីវ័យក្មេងក្នុងរូបថតនោះពីព្រោះអ្នកនិពន្ធបានរៀបរាប់ពីការពិភាក្សារបស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានៅឯទីក្រុងភ្នំពេញ ។ ខ្ញុំបានស្វែងរកព័ត៌មានតាមប្រព័ន្ធអ៊ិនធើណែត ហើយបានផ្ញើអ៊ីម៉ែលមួយនិយាយពីចំណាប់អារម្មណ៍របស់ខ្ញុំចំពោះរូបថតរបស់ស្ត្រីវ័យក្មេងមួយនោះទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្តល់នូវលេខសម្គាល់និងកាលបរិច្ឆេទរបស់រូបថតនោះ ។ ភ្លាមៗនោះលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានឆ្លើយតបមកវិញដោយសន្យាថានឹងជួយផ្តល់ព័ត៌មានពីស្ត្រីក្នុងរូបថតនោះ ។

ចម្លើយរបស់លោក ឆាំង យុ នៅថ្ងៃបន្ទាប់គឺថា ៈ

“ឈ្មោះរបស់ស្ត្រីនោះ គឺ អ៊ុច សាមិន ។ គាត់មានអាយុ ១៦ឆ្នាំនៅពេលដែលគាត់ត្រូវបានចាប់ខ្លួននិងនាំមកកាន់មន្ទីរឃុំឃាំងស-២១ ។ គាត់កើតនៅភូមិព្រៃខ្វត ឃុំសំរោងខាងត្បូង ស្រុកកំចាយមារ តំបន់២០ ។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែធ្នូឆ្នាំ១៩៧៨និងសម្លាប់នៅថ្ងៃទី១១ ខែធ្នូឆ្នាំ១៩៧៨ ។ លេខឯកសារគឺ (K០៧៥៧៩ប្រវត្តិរូប) និង (D២១៨៩៩បញ្ជីកម្ទេច) ។ ខ្ញុំសង្ឃឹមថា ស្ត្រីម្នាក់នេះមានសមាជិកគ្រួសារដែលនៅរស់ ហើយសង្ឃឹមថាលោកអាចទៅទស្សនាស្រុកកំណើតរបស់គាត់” ។ ពីខ្ញុំ ឆាំង យុ ។



ប្រវត្តិរូបរបស់ អ៊ុច សាមិន នៅមន្ទីរស-២១

ខ្ញុំមានអារម្មណ៍តក់ស្លុតនិងក្រៀមក្រំយ៉ាងខ្លាំង ។ ប៉ុន្តែឥឡូវនេះខ្ញុំមានឈ្មោះជនរងគ្រោះ និងអាស័យដ្ឋានរបស់ស្ត្រីនោះតាំងពីឆ្នាំ១៩៧៨មក ។ ហេតុដូច្នេះខ្ញុំក៏បានធ្វើការសម្រេចចិត្តយ៉ាងច្បាស់លាស់ថាខ្ញុំនឹងព្យាយាមស្វែងរកសមាជិកគ្រួសាររបស់គាត់ដែលនៅរស់ ។

ប៉ុន្តែទាំងប្រព័ន្ធអ៊ិនធើណែតនិងផែនទីមិនអាចធ្វើឲ្យខ្ញុំស្វែងរកទីកន្លែងនោះបានឡើយ ។ ខ្ញុំបានត្រឹមតែស្គាល់ឈ្មោះខេត្តព្រៃវែងតែប៉ុណ្ណោះ ។ តាមការស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំក៏បានឃើញរបាយការណ៍របស់អ្នកស្រីនាយក ប៊ុត សាម៉ាន នៃអង្គការសមាគមកុមារនិងជីវិត ។ អង្គការរបស់កម្ពុជាមួយនេះធ្វើការដើម្បីជួយបង្កើនជីវភាពរបស់ប្រជាជនក្រីក្រ មើលថែទាំកុមារនិងយុវជនឲ្យបានទទួលការអប់រំ ។ របាយការណ៍នោះបានរៀបរាប់ពីខេត្តព្រៃវែងថា “ជាខេត្តដែលមានប្រជាជនក្រីក្រជាងគេ” ។ ខ្ញុំក៏បានសុំឲ្យអ្នកស្រី សាម៉ាន ជួយហើយអ្នកស្រីក៏បានផ្ញើអ៊ីម៉ែលរៀបរាប់ពីបទពិសោធន៍ជូរចត់ក្នុងរបបខ្មែរក្រហម ។

លើសពីនេះ ខ្ញុំបានទាក់ទងជាមួយនឹងនារីកម្ពុជាម្នាក់ឈ្មោះ ឡេង លីនដា នៅទីក្រុងភ្នំពេញក្នុងអំឡុងពេលទស្សនកិច្ចរបស់ខ្ញុំនៅប្រទេសកម្ពុជាជាលើកដំបូង ។ លីនដា ធ្វើការនៅភោជនីយដ្ឋានមួយនៅលើផ្លូវស៊ីសុវត្ថិនៅទីក្រុងភ្នំពេញដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារដែលរស់នៅខេត្តពោធិ៍សាត់ ។ គាត់មានប្អូនប្រុសដែលកំពុងតែនៅរៀន ។ ក្រុមគ្រួសាររបស់គាត់ក៏ជួបការលំបាកច្រើនដែរ ។ ឪពុករបស់គាត់បានស្លាប់ដោយសារគ្រាប់មីន ចំណែកឯម្តាយរបស់គាត់រងគ្រោះដោយគ្រាប់កាំភ្លើង ហើយពិការជើង ។ លីនដា ក៏បានជួយស្វែងរកក្រុមគ្រួសាររបស់ អ៊ុច សាមិន នោះ ហើយក៏បានរកឃើញឃុំសំរោងក្នុងនៅលើផែនទី ។ ដូច្នេះយើងក៏បានដឹងថាគោលដៅណាដែលយើងត្រូវទៅតាមស្វែងរកក្រុមគ្រួសារនោះ ។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១ ខ្ញុំបានមកដល់ទីក្រុង

ភ្នំពេញ ។ លីនដា បានត្រៀមខ្លួនរួចជាស្រេចដោយមានផែនទី និងប្រវត្តិរូបរបស់ អ៊ុច សាមិន ហើយយើងក៏បានធ្វើដំណើរទៅខេត្តព្រៃវែង ។ ពេលនោះហើយដែលយើងចាប់ផ្តើមស្វែងរករបស់យើង ។ យើងមានសង្ឃឹមកាន់តែតិចៗទៅ ពីព្រោះពេលវេលាក៏កាន់តែខើច មានកន្លែងជាច្រើនដែលគ្មានឈ្មោះហើយគ្រួសារជាច្រើនបានផ្លាស់ប្តូរទីលំនៅដើម្បីប្រកបមុខរបរថ្មី ។ ទោះជាយ៉ាងណាក្តី យើងនៅតែតាមសួរនិងរក ។

យើងបានតាមសួរម្តងហើយម្តងទៀត ។ អ្នកបើកបរឡានរបស់យើងក៏មានការអត់ធ្មត់ល្អ ហើយបានចូលរួមយ៉ាងសកម្មក្នុងការស្វែងរកនេះដែរ ។ យើងបានបើកឡានទៅវិញទៅមក ប៉ុន្តែយើងនៅតែមិនឃើញតម្រុយអ្វីនៅឡើយ ។

ជាចុងក្រោយ យើងបានរកឃើញឃុំស្មោងខាងត្បូង ប៉ុន្តែឃុំដែលយើងចង់ទៅគឺឃុំសំរោង ។ យើងបានមកដល់ភូមិព្រៃខ្វត ព្រមទាំងបានជួបប្រជាជនក្នុងភូមិនិងបានបង្ហាញរូបថតរបស់ អ៊ុច សាមិន ។ ស្ត្រីម្នាក់បានចំណាំរូបថតនោះ ។ លីនដា បានងាកមើលមកខ្ញុំហើយលើកមេដៃដាក់ខ្ញុំ ។ លីនដា បានជួយឲ្យការស្វែងរកនេះបានសម្រេច ហើយយើងកំពុងតែស្ថិតនៅចំគោលដៅរបស់យើងតែម្តង ។ អ្នកភូមិកាន់តែច្រើនឡើងៗបានមកជួបជុំគ្នា ហើយមានអ្នកខ្លះចំណាំមុខ អ៊ុច សាមិន បាន ។ អ្នកទាំងនោះមានអារម្មណ៍រំភើបហើយបាននាំយើងទៅជួបក្រុមគ្រួសាររបស់ អ៊ុច សាមិន ។

ដំបូង យើងបានជួបនឹងប្អូនប្រុសរបស់ អ៊ុច សាមិន ។ ក្រោយមកយើងបានជួបនឹងបងប្រុសរបស់គាត់ដែលនៅចំណាំមុខប្អូនស្រីរបស់ខ្លួនបាន ។ គាត់បានសម្រក់ទឹកភ្នែកនៅពេលដែលបានឃើញរូបថតនោះ ។ យ៉ាងណាមិញ សមាជិកគ្រួសារនេះ ក៏បានមកជួបជុំគ្នាជាបន្តបន្ទាប់ ។ អ្នកគ្រប់គ្នាមានការភ្ញាក់ផ្អើលដោយស្ទើរតែមិនជឿថាហេតុការណ៍នេះបានកើតឡើង ។ មនុស្សចាស់ ក្មេង និង សាច់ញាតិបានមកជួបជុំគ្នា ។ សាច់ញាតិរបស់ អ៊ុច សាមិន បានប្រាប់យើងថាកាលនោះខ្មែរក្រហមបាននាំខ្លួនតែ អ៊ុច សាមិន ទៅប៉ុណ្ណោះ ចំណែកឯអ្នកដទៃផ្សេងទៀតត្រូវបានសម្លាប់ភ្លាមៗនៅក្នុងព្រៃ ។ គ្មាននរណាម្នាក់ដឹងថាមានអ្វីកើតឡើងចំពោះ អ៊ុច សាមិន ទេ ។ សព្វថ្ងៃនេះ ឪពុកម្តាយរបស់គាត់បានស្លាប់អស់ហើយ ដែលម្តាយស្លាប់នៅឆ្នាំ ២០០៦ ចំណែកឪពុកស្លាប់នៅឆ្នាំ២០០៧ ។ គ្មាននរណាម្នាក់ក្នុងគ្រួសារនេះស្គាល់គុកទួលស្លែងឬវាលពិឃាតជើងឯកឡើយ ។ ប៉ុន្តែក្រុមគ្រួសារ អ៊ុច សាមិន ចាប់អារម្មណ៍លើទីកន្លែងពីរនោះ ហើយចង់បានប្រវត្តិរូបរបស់ អ៊ុច សាមិន និងបញ្ជីកម្មុច ។ ជាអកុសល ខ្ញុំមិនសន្ទនាជាមួយនឹងក្រុមគ្រួសាររបស់ អ៊ុច សាមិន ទេពីព្រោះគ្មាននរណាម្នាក់អាចនិយាយភាសាអង់គ្លេសបាន ។ ប៉ុន្តែខ្ញុំបានផ្តល់ស៊ុមរូបថតរបស់ អ៊ុច សាមិន ដែលខ្ញុំបានរៀបចំយ៉ាងស្អាតមកពីប្រទេសអាល្លឺម៉ង់ ។ សមាជិកគ្រួសារស្ទើរតែទាំងអស់បានសម្លឹងមើលរូបថតនេះ ហើយអ្នកខ្លះបានស្ទាបមុខរបស់ អ៊ុច សាមិន លើរូបថតហាក់បីដូចជាចង់បានភាពស្និទ្ធស្នាល ។ យើងអាចដឹងពីសេចក្តីសប្បាយរីករាយនិងក្តីស្រឡាញ់របស់សមាជិកគ្រួសាររបស់ អ៊ុច សាមិន ដែលមានចំពោះយើងនិងការទទួលស្គាល់ការពិតនៃការបាត់បង់ អ៊ុច សាមិន ។

វាគឺពិតជាការដ៏ល្អបំផុតដែលយើងមិនបោះបង់ចោលក្តីសង្ឃឹម បើទោះបីជាក្តីសង្ឃឹមនោះមានតិចតួចយ៉ាងណាក្តី ។ អ្វីដែលយើងផ្តល់ឲ្យក្រុមគ្រួសារនេះគឺប្រាកដណាស់សេចក្តីសុខហើយ យើងក៏សុំសេចក្តីសុខដូចគ្នាដែរ ។ **រៀត កាល ហៀន**



ក្រុមគ្រួសាររបស់អ្នកទោស អ៊ុច សាមិន ជាមួយនឹង រៀត កាលហៀន

# ការផ្តល់សក្ខីកម្មរយៈពេលបីថ្ងៃរបស់ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

*កាលពីថ្ងៃទី០១ ទី០២ និងទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ នេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកោះអញ្ជើញមកបំភ្លឺក្នុងសវនាការទាក់ទងទៅនឹងការគ្រប់គ្រង និងការប្រមូលចងក្រងឯកសារដើម្បីផ្តល់សក្ខីកម្មស្តីពីយថាភាពនៃឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់មកកាន់អង្គជំនុំជម្រះក្នុងការប្រើប្រាស់ជាភ័ស្តុតាងក្នុងសំណុំរឿង០០២ដែលមានជនជាប់ចោទ អៀង សារី, ខៀវ សំផន និង នួន ជា ។*

## ថ្ងៃទីមួយ

### ការចោទសួរពីសំណាក់សហព្រះរាជអាជ្ញា

*នៅថ្ងៃទី០១ កុម្ភៈ ឆ្នាំ២០១២ នេះអង្គជំនុំជម្រះបានចាប់ផ្តើមបន្តសវនាការរបស់ខ្លួនដោយស្តាប់សក្ខីកម្មរបស់លោក ឆាំង យុ ចំពោះការពិភាក្សាលើការគ្រប់គ្រងឯកសារ ការចាត់ថ្នាក់ឯកសារ ការទទួល ការប្រគល់ឯកសារ និងការរៀបចំបញ្ជីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សវការនេះផ្តល់ឱកាសដំបូងទៅព្រះរាជអាជ្ញាក្នុងការតាំងសំណួរសួរទៅសាក្សី ។*

### ប្រវត្តិរូប និងការសិក្សា

*លោក ឆាំង យុ កើតនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៦១ នៅទួលគោករាជធានីភ្នំពេញ ហើយសព្វថ្ងៃជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យដាឡាសក្នុងរដ្ឋតិចសាស់ សហរដ្ឋអាមេរិច ។ អំឡុងពេលនោះ លោកបានធ្វើការនៅសាកលវិទ្យាល័យយែលលើការរៀបចំឯកសារផងដែរ ។ លោកចេះភាសាអង់គ្លេសដែលអាចប្រើការជាផ្លូវការបាន ភាសាបារាំងអាចនិយាយនិងស្តាប់បាន ព្រមទាំងភាសាថៃ និងឡាវអាចប្រើការបានតែមិនផ្លូវការ ។ លោកមិនបានរាប់បញ្ចូលនូវវគ្គសិក្សាខ្លីឬការចូលរួមប្រជុំសន្និបាតផ្សេងៗថា ជាជំនាញនោះទេ ។*

### មុនទៅដល់អាមេរិក

*លោកបានទៅនៅប្រទេសថៃក្នុងឋានៈជាជនភៀសខ្លួននៅក្នុងជំរំខាវអ៊ីដាង ។ នៅទីនោះលោកបានរៀនភាសាថៃ អង់គ្លេស ព្រមទាំងបានធ្វើការនៅអង្គការមនុស្សធម៌ដោយមាននាទីជាអ្នកវាយអង្គុលីលេខ ។ ការធ្វើការនេះគ្រាន់តែប្តូរនឹងអាហារប៉ុណ្ណោះ ។ នៅជំរំខាវអ៊ីដាង ជនភៀសខ្លួនមិនអាចទៅសហរដ្ឋអាមេរិកបានទេ លុះត្រាតែមានបងប្អូនមកធានា ។ លោកក៏បានបញ្ជាក់ថា លោកមានបងប្អូនធានាដែរ តែលោកមិនទៅ ដោយសារតែលោកចង់ទៅដោយខ្លួនឯង ។ លោកចង់ទៅសហរដ្ឋអាមេរិក*



លោក ឆាំង យុ ឈរនៅក្នុងការិយាល័យរបស់គាត់

ដោយសារតែពីមុនលោកមានសាច់ញាតិធ្វើការជាមួយរបបចាស់ (លន់នល់) ហើយមានភ្ញៀវបរទេសជាច្រើនតែងមកលេងផ្ទះរបស់គាត់ ហើយអ្នកទាំងនោះតែងតែនិយាយភាសាអង់គ្លេស ធ្វើឲ្យលោកមានចិត្តមួយចង់ចេះភាសាអង់គ្លេស ។ មួយរយៈក្រោយមក ប្រធានជំរឿនសួរលោកថាតើលោកចង់ទៅនៅរដ្ឋណា ព្រោះសហរដ្ឋអាមេរិចមានរដ្ឋច្រើនណាស់ ។ សំណួរនេះធ្វើឲ្យលោកនឹកឃើញដល់លោកស្រី ដេកគើលីន កេណ្ណឌី (Jacqueline Kennedy) ដែលជាភរិយារបស់អតីតប្រធានាធិបតី ចន កេណ្ណឌី ។ លោកស្រីដេកគើលីន កេណ្ណឌី បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៦៧ ដែលកាលនោះលោក ឆាំង យុ មានអាយុប្រាំមួយឆ្នាំ ។ ហើយលោកចាត់ទុកថា លោក កេណ្ណឌី ជាវីរៈបុរសក្នុងចិត្តលោកជានិច្ច ។ លោក ឆាំង យុ ក៏បានសួរទៅកាន់ប្រធានជំរឿនថា តើលោក កេណ្ណឌី ស្លាប់នៅទីណា? ប្រធានជំរឿនបានឆ្លើយថា លោក កេណ្ណឌី ស្លាប់នៅក្នុងក្រុងដាឡាស់ក្នុងរដ្ឋតិចសាស់ ដូច្នេះ លោក ឆាំង យុ ក៏សម្រេចចិត្តថាទៅនៅរដ្ឋតិចសាស ។ ដោយសារតែលោកជាជនរងគ្រោះមួយរូបក្នុងរបបខ្មែរក្រហមនោះ នៅក្នុងអំឡុងឆ្នាំ១៩៨៦-៨៧ លោកបានចូលរួមជាមួយយុទ្ធនាការប្រឆាំងនឹងការវិលត្រលប់មកកាន់អំណាចរបស់ខ្មែរក្រហមនៅប្រទេសកម្ពុជាវិញដោយពេលនោះលោកធ្វើជាអ្នកបកប្រែ ។

### មកដល់ភ្នំពេញដំបូង

លោក ឆាំង យុ បានត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ ១៩៩២ក្នុងឋានៈជាបុគ្គលិកអង្គការសហប្រជាជាតិដើម្បីរៀបចំការបោះឆ្នោតនៅខេត្តកំពង់ស្ពឺ ដោយទទួលខុសត្រូវបង្រៀនអ្នកបោះឆ្នោត ។ រហូតមកដល់ឆ្នាំ១៩៩៥ លោកបានធ្វើការជាមួយសាកលវិទ្យាល័យយែលក្នុងគម្រោងស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាដោយមានលោក ដេវីដ ហក ជាអ្នកគ្រប់គ្រងកម្មវិធីនេះ ។ ពីរឆ្នាំបន្ទាប់នៅឆ្នាំ១៩៩៧ បន្ទាប់ពីគម្រោងនៃការសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យយែលត្រូវបានបញ្ចប់នោះ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងដោយមានលោក ឆាំង យុ ជាប្រធាន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាស្ថាប័នសិក្សាស្រាវជ្រាវឯករាជ្យមួយដែលបានប្រមូលនិងចងក្រងឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហមធំបំផុតនៅប្រទេសកម្ពុជាក៏ដូចជានៅលើពិភពលោក ។

### គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

លោក ឆាំង យុ បានឲ្យដឹងថា ការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជាគឺមានគោលបំណងក្នុងការចងក្រងឯកសារខ្មែរក្រហមដើម្បីជាប្រវត្តិសាស្ត្រនិងដើម្បីជាការផ្សះផ្សាមួយ ។ ការផ្សះផ្សានេះទៀតសោតមានកម្មវិធីធំៗចំនួនបីគឺ ទីមួយ ចង់ឲ្យមានតុលាការដើម្បីស្វែងយុត្តិធម៌ និងការពិត, ទីពីរ ចង់ឲ្យសិស្សានុសិស្សចងចាំនិងរៀនសូត្រ និងទីបីចង់ឲ្យមានកន្លែងអចិន្ត្រៃយ៍មួយដើម្បីផ្តល់ជូនសាធារណជនមកធ្វើការសិក្សាស្រាវជ្រាវនិងជាការរួមចំណែកក្នុងការទប់ស្កាត់កុំឲ្យរបបនេះកើតមានឡើងម្តងទៀត ។



លោក ឆាំង យុ ចាប់ផ្តើមធ្វើកិច្ចការយុទ្ធនាការណ៍ប្រឆាំងរបបខ្មែរក្រហម ឆ្នាំ១៩៨៩

### ប្រភពនៃឯកសារ

លោក ឆាំង យុ បានបញ្ជាក់ទៅសវនាការថា រាល់ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាន គឺតាមរយៈបុគ្គលផ្ទាល់ ពីក្រសួងមហាផ្ទៃ, ការិយាល័យឃោសនាអប់រំមជ្ឈិម, ក្រសួងអប់រំយុវជននិងកីឡា, បណ្ណសារដ្ឋានជាតិ, គុកទួលស្លែង, ស្ថាប័នរដ្ឋនានា, តាមរយៈការសម្ភាសអ្នកស្រុកដែលរស់រានជីវិតពីរបបខ្មែរក្រហមនិងប្រទេសផ្សេងៗដែលបានផ្តល់ឯកសារទាំងនេះមក ។

លោក ឆាំង យុ បានឲ្យដឹងថា ឯកសារដែលប្រមូលបាន មានពីរប្រភេទគឺឯកសារប្រភេទជារូបថត

និងប្រភេទជាក្រដាស ។ ចំពោះឯកសារប្រវត្តិរូបដែលប្រមូលបានមកពីក្រសួងមហាផ្ទៃក៏មានពីរប្រភេទដែរគឺឯកសារប្រវត្តិរូបកម្មាភិបាលខ្មែរក្រហមនិងឯកសារប្រវត្តិរូបរបស់អ្នកទោសដែលចាប់យកមក ។ លោកបានបញ្ជាក់ទៀតថា រហូតមកដល់ពេលនេះ ឯកសារដែលមជ្ឈមណ្ឌលឯកសារទទួលបានដែលលោកចាត់ទុកថាជាឯកសារដើមកាលពីសម័យខ្មែរក្រហមនោះ មានប្រហែលមួយលានឯកសារសរុបទាំងក្នុង និងក្រៅប្រទេសដែលប្រមូលបាន ។

**វិធីសាស្ត្រក្នុងការពិនិត្យលើយថាភាពនៃឯកសារ**

ដើម្បីកំណត់យថាភាពនៃឯកសារ លោក ឆាំង យុ បានឲ្យដឹងថា យើងគួរផ្តោតទៅលើពណ៌, កាលបរិច្ឆេទ, អ្នកនិពន្ធ និងខ្លឹមសារនៃសាច់រឿង ព្រមទាំងការប្រើប្រាស់នូវពាក្យពេចន៍មួយចំនួន



លោក ឆាំង យុ កំពុងស្រាវជ្រាវរកមើលឯកសារខ្មែរក្រហមនៅខេត្តតាកែវ ឆ្នាំ១៩៩៥

នៅក្នុងឯកសារ ។ លោកក៏បានបញ្ជាក់ទៀតថា លោកអាចចាត់ទុកថាឯកសារទាំងនោះជាឯកសារដែលបានធ្វើឡើងយ៉ាងពិតប្រាកដនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺលោកពិនិត្យទៅលើកាលបរិច្ឆេទដែលបានសរសេរនៅលើឯកសារទាំងនោះ ។

**ថ្ងៃទីពីរ**

**ការសួរដេញដោលរបស់មេធាវី ខៀវ សំផន និង នួន ជា**

សវនាការថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ នេះ លោកប្រធានចៅក្រមបានផ្តល់នាទីទៅមេធាវីការពារក្តីរបស់ ខៀវ សំផន និង នួន ជា ធ្វើការតាំងសំណួរទៅកាន់សាក្សី ឆាំង យុ ។

**ទំនាក់ទំនងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

លោក ឆាំង យុ បានបញ្ជាក់ទៅមេធាវីការពារក្តីរបស់ ខៀវ សំផន ថារហូតមកដល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានកិច្ចព្រមព្រៀងណាមួយជាមួយតុលាការនេះទេ ដោយហេតុថាខាងមជ្ឈមណ្ឌលបានស្នើសុំឲ្យមានកិច្ចព្រមព្រៀងនេះតាំងពីឆ្នាំ២០០៥រហូតដល់ឆ្នាំ២០០៧តែមិនបានទទួលចម្លើយតបពីខាងការិយាល័យរដ្ឋបាលរបស់សាលាក្តីខ្មែរក្រហមនោះទេ ។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រាន់តែជាបណ្ណសារដ្ឋានមួយសម្រាប់សិស្សានុសិស្ស សាធារណជន និងអ្នកសិក្សាទាំងឡាយមកធ្វើការស្រាវជ្រាវប៉ុណ្ណោះ ។

**ការគ្រប់គ្រងនិងការកំណត់លើយថាភាពនៃឯកសារ**

លោក ឆាំង យុ បានបញ្ជាក់ថា រាល់ឯកសារដែលចម្លងចេញពីឯកសារដើមនោះ គឺបានធ្វើការចុះលេខសម្គាល់, អក្សរសម្គាល់ដើម្បីឲ្យដឹងថាឯកសារនោះជាប្រភេទឯកសារអ្វីនិងមានប្រភពមកពីណា ប៉ុន្តែចំពោះឯកសារដែលធ្វើការស្កេនចេញពីឯកសារដើម គឺមិនធ្វើការចុះលេខនោះទេ ។ ទាក់ទងនឹងឯកសារទាំងអស់ដែលយកចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោក ឆាំង យុ បានអាននិងពិនិត្យលើឯកសារប្រហែលមួយលាននោះ ព្រមទាំងបានចាត់ថ្នាក់លើឯកសារនីមួយៗផងដែរ ។ ឧទាហរណ៍ ឯកសារប្រវត្តិរូបដាក់មុំ, ឯកសារជារូបថតដាក់មុំជាដើម ។ លោកបានបន្តទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការជាមួយបណ្ណសារដ្ឋានជាតិដែលមានជំនាញក្នុងការពិនិត្យលើយថាភាពឬភាពពិតនៃឯកសារផងដែរ ។ ជាមួយគ្នានោះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានកម្រងសំណួរជារួម ដើម្បីសាកសួរទៅអ្នកដែលបានផ្តល់ឯកសារមកឲ្យដើម្បីបញ្ជាក់ពីប្រភពនៃឯកសារថាបានមកពីណានិងនរណាជាអ្នកផ្តល់ឯកសារទាំងនេះ ។ ចំពោះចំណាត់ការឯកសារវិញ លោក ឆាំង យុ បានបញ្ជាក់ថា ឯកសារទាំងអស់ចែកជាពីរលំដាប់ គឺឯកសារដើម និងឯកសារដែលយកពីកន្លែងផ្សេងៗទៀតមកប្រើប្រាស់ ។ ឆ្លើយតបទៅនឹងមេធាវីដែលសួរថាតើឯកសារដែលប្រមូលបានប្រហែលមួយលាននោះ មាន

ឯកសារណាដែរមិនមែនជាឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬទេ? លោក ឆាំង យុ បានឆ្លើយថា មានឯកសារតែមួយគត់ដែល មិនមានការទាក់ទងជាមួយនឹងរយៈពេលពីឆ្នាំ១៩៧៥ - ១៩៧៩ ព្រោះរឿងរ៉ាវនោះកើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដែលទាក់ទងនឹងការចាប់ជំរិតភ្ញៀវទេសចរណ៍បរទេសនៅភ្នំវល្លិ៍ខេត្តកំពត ។ លោក ឆាំង យុ ក៏បានបង្ហាញជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់មេធាវីការពារក្តី នួន ជា ឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលធ្វើការវាយតម្លៃលើឯកសារណាមួយថាជាឯកសារដាក់បន្ទុកនោះទេ ហើយរូបលោកផ្ទាល់ក៏មិនដែលធ្វើការវិភាគ ឬវាយតម្លៃលើឯកសារទាំងអស់ដើម្បីដាក់បន្ទុកនោះទេ ព្រោះលោកមិនមែនជាមេធាវី ឬអ្នកច្បាប់ លោកគ្រាន់តែអានបែបជាអត្ថបទប្រវត្តិសាស្ត្រប៉ុណ្ណោះ ។ ទាក់ទងនឹងសំណួរមេធាវីរបស់ នួន ជា សួរលោកថា តើលោកធ្លាប់មានការប្រជុំជាមួយតំណាងសហព្រះរាជអាជ្ញាមុននឹងបញ្ជូនលិខិតជាផ្លូវការក្នុងការស្នើសុំឯកសារបញ្ជូនទៅដល់មជ្ឈមណ្ឌលឯកសារឬទេ? លោក ឆាំង យុ បានឆ្លើយ និងបានបញ្ជាក់ទៅលោកមេធាវីយ៉ាងច្បាស់ថា មិនមានការប្រជុំជាមួយតំណាងសហព្រះរាជអាជ្ញា មុននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបញ្ជូនលិខិតស្នើសុំឯកសារជាផ្លូវការទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏មិនដែលស្នើ ឬក៏ប្រាប់ទៅខាងព្រះរាជអាជ្ញាថា ឯកសារណាគួរតែមើលក្នុងការជំនុំជម្រះនោះទេ គឺគ្មានទាល់តែសោះ និយាយរួម គឺមិនដែលពិភាក្សាលើឯកសារទេ លុះត្រាតែមានសំណើទើបចម្លងជូន ។

### ថ្ងៃទីបី

### ការសួរដេញដោលបន្តរបស់មេធាវី នួន ជា

ការសួរដេញដោលបន្តរបស់មេធាវី នួន ជា ចំពោះលោក ឆាំង យុ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២នេះ បានចោទសួរទៅលើប្រភពសៀវភៅខ្មៅ ។ លោក ឆាំង យុ បានឆ្លើយតបដោយសង្ខេបថា សៀវភៅខ្មៅនេះមានបីប្រភពគឺ ទី១) លោក ហ្គុនណា បឺយស្ត្រម ក្នុងប្រទេសស៊ុយអែដ ទី២) លោកស្រីសាស្ត្រាចារ្យ ឡូរ៉ា ស៊ាំម័រ ក្នុងប្រទេសអង់គ្លេស និង ទី៣) រូបលោកផ្ទាល់ ។ សៀវភៅខ្មៅដែលលោក ហ្គុនណា បឺយស្ត្រម និងលោកស្រី ឡូរ៉ា ស៊ាំម័រ មានគឺជាសៀវភៅដើមដែលសរសេរជាភាសាបារាំង បោះពុម្ពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកក៏បានបញ្ជាក់ទៀតថា សៀវភៅដែលលោកមេធាវីមានជាភាសាអង់គ្លេសនោះគ្រាន់តែជាសៀវភៅដែលបកប្រែប៉ុណ្ណោះ ។ ទាក់ទងនឹងទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ លោកមានទាំងឯកសារដើម និងថតចម្លង ប៉ុន្តែលោក ឆាំង យុ បានឲ្យដឹងថានៅរបបកម្ពុជាប្រជាធិបតេយ្យ មិនហៅថាទស្សនាវដ្តីនោះទេ គេហៅថាសៀវភៅទង់បដិវត្តន៍ សៀវភៅយុវជនយុវនារីបដិវត្តន៍ជាដើម ។ ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅឆ្នាំ១៩៧៩ លោកយល់ថាមានភាព



ក្រុមរបស់លោក ឆាំង យុ កំពុងតវ៉ាប្រឆាំងចលនាខ្មែរក្រហម នៅសាកលវិទ្យាល័យ

លម្អៀងផ្នែកនយោបាយ និងគុណវិបត្តិនៃតុលាការ ហើយឯកសារទាំងនោះទៀតសោតគឺមានលក្ខណៈមួយមិនគ្រប់គ្រាន់ ។ លោករំឭកទៀតថា ឯកសារមួយចំនួនត្រូវបានបំផ្លិចបំផ្លាញ, ឯកសារខ្លះត្រូវបានដុតបំផ្លាញចោលមុនសម័យខ្មែរក្រហមដួលរលំ, និងពីសំណាក់ភាគីផ្សេងៗទៀតនៅពេលនោះ ។ ទាក់ទងនឹងកិច្ចព្រមព្រៀងរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជាវិញ លោក ឆាំង យុ បញ្ជាក់ជាថ្មីម្តងទៀតទៅកាន់មេធាវីការពារក្តី នួន ជា ថាតាំងពីឆ្នាំ២០០៥

រហូតដល់ឆ្នាំ២០០៧ មិនមានការឆ្លើយតបណាមួយទាក់ទងនឹងសំណើឲ្យមានកិច្ចព្រមព្រៀងអំពីការធានាលើយថាភាពនៃឯកសារពីតុលាការសាលាក្តីខ្មែរក្រហមនោះទេ រហូតមកដល់ពេលនេះក៏មិនមានរបាយការណ៍ជាលាយលក្ខណ៍អក្សរណាមួយពីការិយាល័យរដ្ឋបាលនៃសាលាក្តីខ្មែរក្រហមនេះទេ ហើយលោកចាត់ទុកទង្វើនេះថាជាការមាក់ងាយមួយចំពោះឯកសារជាប្រវត្តិសាស្ត្រនេះ ។

ចំពោះការលើកឡើងរបស់មេធាវីអន្តរជាតិ នួន ជា ថាការកាប់សម្លាប់ទាំងឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជា



គិចសាស់ អេ&អឹម

អំពើរបស់កម្មាភិបាលថ្នាក់ក្រោមទេដែលបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ លោក ឆាំង យុ បានពន្យល់និងលើកជាការប្រៀបធៀបមួយថាក្នុងចំណោមមនុស្សបីពាន់នាក់ដែលមាននៅក្នុងប្រវត្តិរូបយើងបានធ្វើការសម្ភាសន៍ជាមួយអតីតយុទ្ធជនកម្មាភិបាលជាងមួយពាន់នាក់ គ្មាននរណាម្នាក់សារភាពឬប្រាប់ថាខ្លួនធ្លាប់សម្លាប់មនុស្សនោះទេ ។

ដោយឡែកលោក ឆាំង យុ ក៏បានសម្តែងនូវសុទិដ្ឋិនិយមថា ឯកសារចំពោះលោកគឺពិតជាមានតម្លៃខ្លាំងណាស់ដោយលោកបានប្រៀបធៀបថាឯកសារមួយសន្លឹកគឺមានតម្លៃស្មើនឹងថ្មប្រាសាទអង្គរវត្តមួយដុំអ៊ីចឹង ហើយលោកពិតជាមានការស្រែកឃ្លានណាស់ក្នុងការអានឯកសារ ព្រោះដូចជាការរើសគ្រាប់បាយមួយគ្រាប់ដែលប្រឡាក់ភក់យកមកហូបនៅក្នុងសម័យខ្មែរក្រហមដែរ ។ លោក ឆាំង យុ បានបដិសេធថា មិនមានឯកសារខ្មែរក្រហមក្លែងបន្លំនៅក្នុងមជ្ឈមណ្ឌលឯកសារទេ ជាក់ស្តែងដូចជា ឯកសារ កុយ ធួន (លេខាភូមិភាគឧត្តរ) មានកម្រាស់រហូតដល់ជិតមួយពាន់ទំព័រ ចំណែកការប្រើប្រាស់ពាក្យមួយចំនួននៅក្នុងសម័យនោះ ឧទាហរណ៍ដូចជា ពាក្យ "បដិច្ចសមុប្បាទ" គឺអ្នកមួយចំនួននៅសម័យនេះ ក៏ដូចជាអ្នកដែលបានចូលរួមក្នុងសវនាការនេះ អាចមិនយល់ផង ចុះបើឯកសារមានសរុបទាំងអស់មួយលានទំព័រ តើអ្នកក្លែងឯកសារត្រូវការពេលវេលាប៉ុន្មានឆ្នាំ? តើអ្នកអាចជឿបានទេក្នុងរយៈពេលដប់ឆ្នាំអ្នកនោះអាចក្លែងឯកសារបាន រហូតដល់មួយលានទំព័រដែលមានសាច់រឿងស្រាក់គ្នាបាននោះ ។ លោកយល់ថាប្រសិនបើអាចធ្វើទៅបានមែនម្នាក់នោះ គឺជាមនុស្សអស្ចារ្យបំផុតក្នុងពិភពលោក ។

លោកបានបញ្ជាក់យ៉ាងច្បាស់ថាប្រសិនបើមានការស្នើសុំពីតុលាការនោះ លោកនឹងប្រគល់ឯកដើមដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីផ្ទៀងផ្ទាត់ជាមួយឯកសារដែលមជ្ឈមណ្ឌល ប្រគល់ជូនតុលាការកន្លងមក ។

ទាក់ទងនឹងសំណួរដែលលោកមេធាវីជាតិការពារក្តី នួន ជា សួរថាតើមានជំនាញការរបស់វៀតណាមជួយធ្វើនិងប្រមូលឯកសារឬទេ? លោកឆ្លើយថា ក្រុមប្រមូលនិងធ្វើឯកសារនៅក្រសួងមហាផ្ទៃ គឺមានជំនាញការវៀតណាមម្នាក់ជាអ្នកគ្រប់គ្រងប៉ុន្តែរាល់ឯកសារទាំងអស់ដែលប្រមូលបានគឺខ្មែរផ្ទាល់ដែលជាអ្នកប្រមូលនិងរៀបចំឯកសារមិនមែនជំនាញការវៀតណាមជាអ្នកធ្វើទេ កាលពីសម័យរដ្ឋកម្ពុជា ។

លោកបន្តថា ទោះបីនៅក្រោយឆ្នាំ១៩៧៩ ប្រទេសកម្ពុជាជួបការលំបាក និងខ្វះខាតយ៉ាងណាក៏ដោយ ក៏ប្រជាជនខិតខំធ្វើការប្រមែមូលឯកសារ និងទាមទារឲ្យមានការបង្កើតតុលាការកាត់ទោសខ្មែរក្រហមនៅជំនាន់នោះដែរ ។

**ឆាង សារៈមុនិន្ទ និង សោម ប៊ុនថន**

# សហឧក្រិដ្ឋកម្មរួមលក្ខណៈលាតសន្ធឹង និងការទទួលខុសត្រូវលើអំពើប្រល័យពូជសាសន៍សម្រាប់សំណុំរឿង០០២

## ក) សេចក្តីផ្តើម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង «ដើម្បីនាំមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុត» មកកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មក្នុងស្រុក និងឧក្រិដ្ឋកម្មអន្តរជាតិដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជាចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ ខណៈពេលដែលសំណុំរឿង០០២ ដែលមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ចំនួនបួននាក់កំពុងតែប្រឈមមុខនឹងបទចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដ៏ជាក់លាក់ជាច្រើនដូចជាការធ្វើបុកទុក្ខម្នេញដែលជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ដែលនឹងដំណើរការនាពេលឆាប់ៗនេះ វាពិតជាមានសារសំខាន់ក្នុងការកំណត់ថាតើការទទួលខុសត្រូវប្រភេទណាដែលអាចឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីពិរុទ្ធដ៏មានសក្តានុពលភាពរបស់មេដឹកនាំខ្មែរក្រហមសម្រាប់អំពើសាហាវឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលគ្រប់គ្រងអំណាចរបស់ខ្លួន ។ ចាប់តាំងពីសង្រ្គាមលោកលើកទីពីរមក សហឧក្រិដ្ឋកម្មរួមត្រូវបានយកមកអនុវត្តដើម្បីចោទប្រកាន់មេដឹកនាំជាន់ខ្ពស់សម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិតាមរយៈការចូលរួមរបស់មេដឹកនាំទាំងនេះនៅក្នុងផែនការប្រព្រឹត្តឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ។

នៅខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហមបានចោទប្រកាន់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ពីបទឧក្រិដ្ឋកម្មអន្តរជាតិតាមគោលការណ៍សហឧក្រិដ្ឋកម្មរួម ។ បើទោះបីជាមានការអនុវត្តគោលការណ៍សហឧក្រិដ្ឋកម្មរួមក៏ដោយ ក៏គោលការណ៍នេះបានក្លាយជាប្រភពមួយនៃការរិះគន់ និងការជជែកដេញដោល ជាពិសេសគឺទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ ដែលស្គាល់ថាជាទម្រង់សហឧក្រិដ្ឋកម្មរួមលក្ខណៈលាតសន្ធឹង ។ ការរិះគន់នេះបង្កជាភាពតានតឹងនៅពេលដែលលទ្ធភាពធ្វើឲ្យមានការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍តាមរយៈទ្រឹស្តីសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីត្រូវបានលើកឡើង ។ អត្ថបទនេះនឹងផ្តល់ជាសេចក្តីសង្ខេបនៃការជជែកដេញដោល និងការវិភាគលើយុត្តិសាស្រ្តជាប់ពាក់ព័ន្ធខ្លះៗនឹងបញ្ហានេះ ។

### ១) ធាតុផ្សំ និងភាពប្រែប្រួលនៃគោលការណ៍សហឧក្រិដ្ឋកម្មរួម

អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបកស្រាយគោលការណ៍សហឧក្រិដ្ឋកម្មរួមនៅក្នុងមូលដ្ឋាននៃសាលក្រមកាត់ទោសជនជាប់ចោទ ទាឌិច ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធប្រានចោលថាជនជាប់ចោទ ទាឌិច មិនមែនជាឧក្រិដ្ឋជនសម្លាប់ជនជាតិមូស្លីមប៊ូស្នៀចំនួនប្រាំនាក់ ដោយសារតែគ្មានភ័ស្តុតាងអះអាងថាជនជាប់ចោទ ទាឌិច បានប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ដៃ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចផ្ទុយពីនេះ ដោយកំណត់ថាច្បាប់ទំនៀមទម្លាប់អន្តរជាតិមានចែងជាទម្រង់នៃការទទួលខុសត្រូវជាច្រើនដែលរកឃើញថាជនជាប់ចោទមានពិរុទ្ធភាពសម្រាប់ការចូលរួមនៅក្នុងបទឧក្រិដ្ឋកម្មរួម បើទោះបីជាមានបុគ្គលផ្សេងទៀតជាអ្នកប្រព្រឹត្តឧក្រិដ្ឋនោះដោយផ្ទាល់ក៏ដោយ ។ បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានចែងសហឧក្រិដ្ឋកម្មរួមជាបីទម្រង់ ។ ទម្រង់ទីមួយដែលហៅថាទ្រឹស្តីសហឧក្រិដ្ឋកម្មរួម «បែបមូលដ្ឋាន» ពាក់ព័ន្ធនឹងផែនការរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយ ។ សមាជិកនីមួយៗអាចមានតួនាទីដាច់ដោយឡែកពីគ្នានៅក្នុងការអនុវត្តផែនការឧក្រិដ្ឋកម្មរួមមួយ ប៉ុន្តែសមាជិក

ទាំងអស់ត្រូវតែមានចេតនារួមគ្នាមួយក្នុងការប្រព្រឹត្តផែនការខុក្រិដ្ឋកម្មរួមនោះ ។ ទម្រង់ទីពីរដែលហៅថាសហឧក្រិដ្ឋកម្មរួមបែប "ប្រព័ន្ធ" ដែលអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តីខ្មែរក្រហមនៅក្នុងសាលក្រមកាត់ទោស ឌុច គឺទាក់ទងនឹងផែនការរួមក្នុងការប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងដែលគាបសង្កត់ ឬរំលោភបំពានមានដូចជា មន្ទីរឃុំឃាំង និងជំរុំពលកម្មជាដើម ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួមលក្ខណៈលាតសន្ធឹងដែលជាប្រធានបទនៃអត្ថបទនេះអនុញ្ញាតឲ្យតុលាការធ្វើការកាត់ទោសជនជាប់ចោទឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលឋិតនៅខាងក្រៅផែនការរួមដែលជនជាប់ចោទបានយល់ស្របចូលរួម ប៉ុន្តែការអនុវត្តផែនការដើមនៃឧក្រិដ្ឋកម្មទាំងអស់នេះគឺជាផលវិបាកលក្ខណៈធម្មជាតិ និងអាចព្យាករណ៍ទុកជាមុន ។

### ១) ធាតុផ្សំសត្យានុម័ត

សហឧក្រិដ្ឋកម្មរួមទាំងបីទម្រង់នេះមានលក្ខន្តិកៈស្តីពីអំពើពិរុទ្ធស្រដៀងគ្នាដូចជា ៖ ១) ចាំបាច់ត្រូវមានចំនួនមនុស្សច្រើន ២) ការព្រមព្រៀងលើផែនការរួមមួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយ យោងតាមយុត្តិសាស្ត្ររបស់តុលាការកាត់ទោស និង៣) ការប្រព្រឹត្តដ៏សំខាន់ដោយជនជាប់ចោទនៅក្នុងការបន្តសម្រេចផែនការរួម ។ តុលាការទាំងអស់បានយល់យ៉ាងច្បាស់ថាទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវដែលឋិតនៅក្រោមការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយក៏មិនមែនជាឧក្រិដ្ឋកម្មដាច់ដោយឡែកពីគ្នាដែរ ប៉ុន្តែជា "មធ្យោបាយនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម" ។ ទម្រង់សហឧក្រិដ្ឋកម្មរួមទាំងអស់អនុញ្ញាតឲ្យមានការចោទប្រកាន់លើជនដែលមិនបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាបទឧក្រិដ្ឋ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយផ្ទាល់ដៃបាន ។ គោលការណ៍នេះមិនត្រឹមតែធ្វើឲ្យមានភាពងាយស្រួលសម្រាប់ព្រះរាជអាជ្ញាអន្តរជាតិក្នុងការធានាពីបទចោទប្រកាន់តែប៉ុណ្ណោះទេ ថែមទាំងឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងត្រឹមត្រូវពីលក្ខណៈនៃការប្រព្រឹត្តអំពើសាហាវឃោរឃៅជាក្រុម ។

### ២) ធាតុផ្សំអត្តនោម័ត

ទម្រង់នីមួយៗនៃសហឧក្រិដ្ឋកម្មរួមមានផ្ទុកនូវលក្ខន្តិកៈនៃចេតនាឧក្រិដ្ឋខុសគ្នាមួយ ។ សម្រាប់ទម្រង់ទីមួយ សមាជិកទាំងអស់នៃផែនការប្រព្រឹត្តឧក្រិដ្ឋកម្មរួមត្រូវតែមានចេតនារួមមួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានគ្រោងទុក ។ សម្រាប់ទម្រង់ទីពីរ ជនជាប់ចោទត្រូវតែដឹងយ៉ាងច្បាស់ពីការរំលោភបំពានជាលក្ខណៈប្រព័ន្ធដែលប្រព្រឹត្តឡើងក្នុងប្រព័ន្ធគ្រប់គ្រងមួយ ហើយបន្តប្រតិបត្តិប្រព័ន្ធនោះដោយដឹងយ៉ាងច្បាស់ពីអំពើរំលោភបំពាន ។ យ៉ាងណាមិញ សម្រាប់ទម្រង់ទីបី ជនជាប់ចោទត្រូវមានចេតនា ឧក្រិដ្ឋពីរដែលរួមមាន ៖ ១) ចេតនាចូលរួមនៅក្នុងផែនការរួម និង២) ការបានដឹងឮពីការប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមទៀតដែលកំពុងតែត្រូវបានប្រព្រឹត្តដើម្បីសម្រេចបាននូវផែនការដើម ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី ទាដិច បានបកស្រាយថា "ទម្រង់សហឧក្រិដ្ឋកម្មរួមទីបីគឺផ្តោតទៅលើស្ថានភាពសតិអារម្មណ៍ដែលជនជាប់ចោទបានដឹងថាសកម្មភាពរបស់ក្រុមខ្លួនអាចនឹងបណ្តាលឲ្យមានផលប៉ះពាល់មួយ បើទោះបីជាជនជាប់ចោទមិនមានចេតនាបង្កជាផលប៉ះពាល់មួយនោះក៏ដោយ ក៏ជនជាប់ចោទបានសម្រេចទទួលយកហានិភ័យនោះដដែល ដើម្បីប្រព្រឹត្តសកម្មភាពរបស់ក្រុម" ។ អង្គជំនុំជម្រះបានហៅស្ថានភាពសតិអារម្មណ៍នេះថាជាការមិនរារាំងហានិយភ័យ ។

### ក) សហឧក្រិដ្ឋកម្មរួម និងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មាត្រា២៩នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំណត់យ៉ាងជាក់លាក់ពីទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលឋិតនៅក្នុងវិសាលភាពនៃយុត្តាធិការរបស់តុលាការដោយចែងថា "រាល់ជនសង្ស័យទាំងឡាយណាដែលបានរៀបចំផែនការញុះញង់ បញ្ជា ជួយ និងជំរុញ ឬប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងនៅក្នុង (លក្ខន្តិកៈ) ត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះដោយផ្ទាល់ខ្លួន" ។ មាត្រា២៩ក៏មានចែងពីការទទួលខុសត្រូវរបស់មេដឹកនាំផងដែរ ។ យោងតាមមាត្រា៤នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍រួមបញ្ចូលទាំងទម្រង់នៃការទទួលខុសត្រូវបន្ថែមទៀតដែលមានជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ដូចជា ៖ ការមានគោលបំណង ការសមគំនិត និងការចូលរួម ។ បើទោះបីជាមាត្រាទាំងពីរនេះមិនបកស្រាយពីទ្រឹស្តី

សហឧក្រិដ្ឋកម្មរួម អង្គបុរេជំនុំជម្រះរបស់សាលាក្តីខ្មែរក្រហមបានសម្រេចថា ស្របតាមការណែនាំរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់មួយនៃ "ការប្រព្រឹត្ត" ដែលមានចែងនៅក្នុងយុត្តាធិការរបស់តុលាការ ។ យ៉ាងណាមិញ បើទោះបីជាអង្គបុរេជំនុំជម្រះសម្រេចថាការទទួលខុសត្រូវទម្រង់សហឧក្រិដ្ឋកម្មរួមគឺជាទូទៅមានជាប់ពាក់ព័ន្ធនឹងច្បាប់របស់សាលាក្តីខ្មែរក្រហមក៏ដោយ ក៏អង្គជំនុំជម្រះបានបដិសេធច្រានចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដោយសម្រេចថា ទម្រង់សហឧក្រិដ្ឋកម្មទី៣គឺមិនមានជាប់ពាក់ព័ន្ធនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥ឡើយ ។ ដូច្នេះ ទម្រង់សហឧក្រិដ្ឋកម្មទី៣នេះមិនមាននៅក្នុងគោលការណ៍ការកាត់ទោសរបស់សាលាក្តីខ្មែរក្រហមឡើយ ។ នៅក្នុងសាលក្រម ឌុច អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថាសហឧក្រិដ្ឋកម្មរួមគឺជាទម្រង់មួយនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រា២៩នៃច្បាប់របស់សាលាក្តីខ្មែរក្រហម និងដែលថាការទទួលខុសត្រូវលើទម្រង់សហឧក្រិដ្ឋកម្មរួមជាទូទៅគឺឋិតនៅក្នុងវិសាលភាពនៃយុត្តាធិការរបស់តុលាការ ហើយក៏បានចោទប្រកាន់ជនជាប់ចោទ ឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ តាមរយៈសហឧក្រិដ្ឋកម្មរួម ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងក៏បានរក្សាទុកសាលក្រមដែលផ្អែកលើភាពអាចអនុវត្តបាននៃទម្រង់សហឧក្រិដ្ឋកម្មទី៣ នេះដើម្បីយកទៅអនុវត្តនាពេលអនាគត ហើយនឹងវិភាគលើកម្រិតនៃភាពជាប់ពាក់ព័ន្ធនៃទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទី៣ នៅឯសាលាក្តីខ្មែរក្រហមជាទូទៅ និងភាពអាចអនុវត្តបាននៃទម្រង់នេះលើបទចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍នៅក្នុងសំណុំរឿង០០២ ។

### ឃ) ភាពចម្រូងចម្រាស់នៃសហឧក្រិដ្ឋកម្មរួមលើបទចោទប្រកាន់អំពើប្រល័យពូជសាសន៍

ក្នុងចំណោមទម្រង់សហឧក្រិដ្ឋកម្មរួមទាំងបីដែលបានពិភាក្សាលើទម្រង់សហឧក្រិដ្ឋកម្មរួមមានភាពចម្រូងចម្រាស់ជាងគេ ហើយជាញឹកញាប់ទទួលរងការរិះគន់ដោយសារតែទម្រង់នេះអាចជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវនៃ "ការប្រព្រឹត្តឧក្រិដ្ឋកម្ម" សម្រាប់ការមិនរារាំងហានិភ័យរបស់ជនជាប់ចោទ ។ បទដ្ឋាននៃធាតុផ្សំសត្យានុម័តកម្រិតទាបនេះទំនងជាមិនស៊ីសង្វាក់គ្នានឹងឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ដែលតម្រូវឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ជាក់លាក់ដូចជាអំពើឃាតកម្ម ឬការបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងដោយ "ចេតនាពិសេសដើម្បីបំផ្លិចបំផ្លាញក្រុមជាតិ ជនជាតិ ជាតិពន្ធុ និងក្រុមសាសនា ដោយផ្អែកឬទាំងស្រុង" ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនៅក្នុងរឿងក្តី ស្តាគីក បានបកស្រាយថាអំពើប្រល័យពូជសាសន៍ "ជាការពិតត្រូវបានកំណត់លក្ខណៈ និងបែងចែកជាចេតនាច្រើន" ។ បើទោះបីជាមានភាពមិនស៊ីសង្វាក់គ្នានេះក៏ដោយក៏តុលាការអន្តរជាតិបានកំណត់ថាការចោទប្រកាន់ពីឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍តាមទម្រង់សហឧក្រិដ្ឋកម្មទី៣អាចធ្វើទៅបាន ប៉ុន្តែមិនទាន់មានការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ណាមួយដែលអនុវត្តតាមទម្រង់សហឧក្រិដ្ឋកម្មទី៣នេះនៅឡើយទេ ។

### ង) អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ក្រោមទម្រង់នៃ ការទទួលខុសត្រូវផ្សេងៗទៀត

តុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ចូលបទចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ក្រោមទម្រង់នៃការទទួលខុសត្រូវផ្សេងៗជាជាងទម្រង់សហឧក្រិដ្ឋកម្មទី៣ដែលទំនងជាខ្វះខាតនូវលក្ខណៈវិនិច្ឆ័យលើចេតនាជាក់លាក់មួយដូចជាការទទួលខុសត្រូវរបស់មេដឹកនាំ និងការជួយ និងការជំរុញ ។ យ៉ាងណាមិញ ទម្រង់នៃការទទួលខុសត្រូវបែបនោះតំណាងឲ្យកម្រិតពិរុទ្ធភាពរបស់ជនជាប់ចោទដែលទាបជាងបទចោទប្រកាន់ដែលទាញចេញពីសហឧក្រិដ្ឋកម្មរួម ពីព្រោះសហឧក្រិដ្ឋកម្មរួមត្រូវបានចាត់ទុកជាទម្រង់មួយនៃ "ការប្រព្រឹត្តឧក្រិដ្ឋកម្ម" ផ្ទុយពីគោលការណ៍ការទទួលខុសត្រូវរបស់មេដឹកនាំ និងការជួយ និងការជំរុញ ដែលជាទម្រង់នៃការទទួលខុសត្រូវកម្រិតទាប និងប្រយោល ។ ដូច្នេះ ការវិភាគដ៏ស៊ីជម្រៅលើបទចោទប្រកាន់ខាងលើនេះមិនអាចចូលទៅក្នុងរចនាសម្ព័ន្ធរបស់ទម្រង់សហឧក្រិដ្ឋកម្មទី៣បានឡើយ ។ ប៉ុន្តែ ហេតុផលដែលគាំទ្របទចោទប្រកាន់ទាំងនេះអាចជួយផ្តល់ជាសេចក្តីវិភាគលើកត្តា

ដែលចៅក្រមបានពិចារណានៅពេលចេញសេចក្តីសម្រេចថាតើការទទួលខុសត្រូវជាលក្ខណៈបុគ្គលពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍មានលក្ខណៈត្រឹមត្រូវសមហេតុផលឬយ៉ាងណា ។

### ១) ការទទួលខុសត្រូវរបស់មេដឹកនាំ

យោងតាមគោលការណ៍នៃការទទួលខុសត្រូវរបស់មេដឹកនាំ (ស៊ីវិល ឬយោធា) នៃស្ថាប័នមួយគឺមានការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មដែលអ្នកនៅក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្តក្នុងករណីដែលធាតុផ្សំខាងក្រោមនេះត្រូវបានបង្ហាញឲ្យឃើញៈ

១) ការកើតមាននូវទំនាក់ទំនងរវាងមេដឹកនាំ និងអ្នកនៅក្រោមបង្គប់ ។

២) មេដឹកនាំបានដឹង ឬមានហេតុផលក្នុងការដឹងថាអ្នកនៅក្រោមបង្គាប់ទំនងនឹងប្រព្រឹត្ត ឬបាន ប្រព្រឹត្តអំពើឧក្រិដ្ឋ ។

៣) មេដឹកនាំមិនបានចាត់វិធានការចាំបាច់ និងសមហេតុផលណាមួយដើម្បីទប់ស្កាត់អំពើឧក្រិដ្ឋ ឬស៊ើបអង្កេត និងដាក់ទណ្ឌកម្មលើអ្នកនៅក្រោមបង្គាប់សម្រាប់ការប្រព្រឹត្តអំពើឧក្រិដ្ឋនោះឡើយ ។ ធាតុផ្សំអត្តនោម័តនៃការទទួលខុសត្រូវរបស់មេដឹកនាំគឺជាការបានដឹងយ៉ាងច្បាស់ ឬមានហេតុផលក្នុងការដឹង ។ ប៉ុន្តែការដឹងយ៉ាងច្បាស់នេះអាចនឹងសម្រេចបានតាមរយៈភស្តុតាងមានលក្ខណ្ឌ ។ "ហេតុផលក្នុងការដឹង" តម្រូវថាមេដឹកនាំទទួលបាន "ព័ត៌មានទូទៅខ្លះៗក្នុងមុខតំណែងរបស់ខ្លួនដែលអាចឲ្យមេដឹកនាំរូបនោះបានដឹងពីទង្វើល្មើសច្បាប់ដែលអាចប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន" ។

នៅពេលអនុវត្តក្នុងករណីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ការទទួលខុសត្រូវរបស់មេដឹកនាំមិនតម្រូវឲ្យរកឃើញនូវចេតនាជាក់លាក់ណាមួយពីជនជាប់ចោទឡើយ ។ ប៉ុន្តែ ជនសង្ស័យដែលជាជនដៃដល់ផ្ទាល់នៃអំពើប្រល័យពូជសាសន៍ដែលជាអ្នកនៅក្រោមបង្គាប់ អាចនឹងប្រព្រឹត្តឧក្រិដ្ឋកម្មឡើងដោយមានចេតនា ។ ដូច្នេះ ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ក្រោមគោលការណ៍ការទទួលខុសត្រូវរបស់មេដឹកនាំមិនបានគេចផុតពីចេតនាជាក់លាក់ដែលមាននៅក្នុងលក្ខណ្ឌវិនិច្ឆ័យឡើយ ប៉ុន្តែវាដាក់កំហិតលើលក្ខណ្ឌវិនិច្ឆ័យនេះមកត្រឹមជនដៃដល់ផ្ទាល់ ។ លក្ខណ្ឌបែបនេះគឺឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងធាតុផ្សំនៃគោលការណ៍នៃការទទួលខុសត្រូវរបស់មេដឹកនាំដែលបណ្តាលឲ្យមានបទចោទប្រកាន់មួយពីបទមិនទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើអំពើប្រល័យពូជសាសន៍របស់អ្នកនៅក្រោមបង្គាប់ ជាជាងការប្រព្រឹត្តអំពើ ប្រល័យពូជសាសន៍ពិតប្រាកដរបស់ជនជាប់ចោទ ។

### ២) គោលការណ៍នៃការជួយ និងការជំរុញ

ការជួយ និងការជំរុញគឺជាប្រភេទនៃការចូលរួមដែលជាទម្រង់នៃការទទួលខុសត្រូវដែលមានកម្រិតស្រាលជាងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយសារតែតួនាទីកំហិតរបស់អ្នកជួយ និងអ្នកជំរុញ និងដោយសារតែធាតុផ្សំអត្តនោម័តកម្រិតទាបដែលតម្រូវឲ្យមាន ។ ក្នុងកាលៈទេសៈនេះ ការទទួលខុសត្រូវចំពោះការជួយ និងការជំរុញគឺមានលក្ខណៈស្រដៀងគ្នានឹងការទទួលខុសត្រូវរបស់មេដឹកនាំ ហេតុដូច្នេះតុលាការមិនរុញរាក្នុងការរកទោសកំហុសរបស់ជនជាប់ចោទសម្រាប់ការជួយ និងការជំរុញឲ្យមានអំពើប្រល័យពូជសាសន៍ឡើយ ។ ការទទួលខុសត្រូវចំពោះការជួយ និងការជំរុញតម្រូវឲ្យជនជាប់ចោទផ្តល់ជំនួយដល់ជនដៃដល់នៃបទឧក្រិដ្ឋបានប្រព្រឹត្តឧក្រិដ្ឋកម្ម ហេតុដូច្នេះជំនួយនេះបានជះឥទ្ធិពលដ៏ធំធេងមួយមកលើការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ ។ ជនជាប់ចោទមិនចាំបាច់មានចេតនារួមគ្នានឹងជនដៃដល់ផ្ទាល់ទេ ប៉ុន្តែសកម្មភាពផ្តល់ជំនួយរបស់ជនជាប់ចោទត្រូវតែមានចេតនាជួយទំនុកបម្រុងដល់ជនដៃដល់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ធាតុផ្សំសត្យានុម័តនេះទំនងជាមានលក្ខណៈស្រដៀងគ្នានឹងការមិនរារាំងពីហានិភ័យដែលមានចែងនៅក្នុងទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ ប៉ុន្តែសំខាន់ជាងនេះគោលការណ៍នៃការជួយនិងការជំរុញដែលមានលក្ខណៈខុសប្លែកពីទម្រង់សហឧក្រិដ្ឋកម្មរួមទី៣គឺមិនមែនជាទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មទេ ។ លក្ខណៈខុសគ្នានេះត្រូវបានបកស្រាយនៅក្នុងរឿងក្តីដែលអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានច្រានចោលការចោទប្រកាន់របស់អង្គជំនុំជម្រះសាលាដំបូងពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួមទី១ ហើយបានកាត់បន្ថយការទទួលខុសត្រូវរបស់ជនជាប់ចោទ គ្រីស៊ីក មកត្រឹមការចូលរួមនៅក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍តាមគោល

ការណ៍នៃការជួយ និងការជំរុញដោយផ្អែកលើកម្រិតនៃការទទួលខុសត្រូវកម្រិតទាបបើប្រៀបធៀបទៅនឹងការទទួលខុសត្រូវរបស់អ្នករៀបចំផែនការដើមនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅ ស្រ៊ីប្រ៊ីនីកា មានដូចជា ជនជាប់ចោទ ស្លូបូដាន់ មីឡូសេវិក ប្រ៉ាត់កូ ម៉្លាឌីក ជាដើម ។

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក៏បានចោទប្រកាន់ជនផ្សេងៗទៀតតាមគោលការណ៍ការជួយ និងការជំរុញដែរ ។ ជាឧទាហរណ៍ នៅក្នុងរឿងក្តីរបស់អេលីហ្សាហ្វាន ណតាគីរ៉ូទីម៉ាណា អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានវិភាគលើគំរូរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា និងអតីតប្រទេសយូហ្គោស្លាវី ក្នុងការវាយតម្លៃលើគោលការណ៍ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ណតាគីរ៉ូទីម៉ាណា សមាជិកនៃព្រះវិហារមួយនៅទីក្រុង ង៉ូមា គីប៊ូយេ *(Ngoma Kibuye)* ដែលជាអ្នកដឹកនាំយោធាជនជាតិហ៊ូទូទៅជាក្រុមទុតស៊ីឲ្យលាក់ខ្លួន ។ ជនជាប់ចោទ ណតាគីរ៉ូទីម៉ាណា ត្រូវបានចោទប្រកាន់ពីការជួយ និងជំរុញឲ្យមានអំពើប្រល័យពូជសាសន៍ ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អ្នកជួយនិងអ្នកជំរុញឲ្យមានអំពើប្រល័យពូជសាសន៍ត្រូវតែមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ នៅក្នុងបណ្តឹងសាទុក្ខអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានគូសបញ្ជាក់លើបទចោទប្រកាន់នោះហើយ ប៉ុន្តែបានកត់សម្គាល់ថា ជនជាប់ចោទចាំបាច់ត្រូវតែដឹងពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ជនដែលផ្ទាល់ ។

**ឋ) ទម្រង់សហឧក្រិដ្ឋកម្មទី៣ និងឧក្រិដ្ឋកម្មដោយចេតនាជាក់លាក់ជាលក្ខណៈទូទៅ**

បើទោះបីជាទម្រង់សហឧក្រិដ្ឋកម្មរួមទី៣មិនធ្លាប់បានយកមកអនុវត្តចំពោះបទចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ដោយជោគជ័យក៏ដោយ ក៏ទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដានិងសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបែងពីការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មដោយចេតនាជាក់លាក់ផ្សេងៗគ្នាដូចជា ការកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ ។ ការកាត់ទោសពីបទឧក្រិដ្ឋនេះមានលក្ខណៈស្រដៀងគ្នានឹងឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ត្រង់ថា ជនជាប់ចោទមិនត្រឹមតែចាំបាច់មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប៉ុណ្ណោះទេ តែថែមទាំងត្រូវតែមានចេតនារើសអើងជនរងគ្រោះដោយមូលហេតុពូជសាសន៍ សាសនា ឬនយោបាយ ។ សម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍វិញ ចេតនាជាក់លាក់ក្នុងការធ្វើទុក្ខបុកម្នេញគឺជាលក្ខណៈវិនិច្ឆ័យនៃបទឧក្រិដ្ឋកម្មនោះ ។ ប៉ុន្តែ ធាតុផ្សំសត្យានុម័តដែលទាមទារឲ្យមានការកាត់ទោសគឺនៅតែចាត់ទុកមិនសូវកំហិតដូចចេតនាជាក់លាក់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ ។

នៅក្នុងរឿងក្តីរបស់ ប៊ូប៊ូរីក និងជនផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានចោទប្រកាន់មន្ត្រី ស៊ីបៀ ជាច្រើនពីបទប្រព្រឹត្តបទល្មើសមកលើជនជាតិម៉ូស្លីម ប៊ូស្នៀ ដោយមានជាប់ពាក់ព័ន្ធនឹងការសម្លាប់រង្គាលនៅ ស្រ៊ីប្រ៊ីនីកា តាមរយៈទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ ។ ការចោទប្រកាន់ទាំងនោះមានភាពត្រឹមត្រូវដោយសារតែការរកឃើញរបស់អង្គជំនុំជម្រះដែលថាសហឧក្រិដ្ឋកម្មរួមក្នុងការសម្លាប់បុរសជនជាតិម៉ូស្លីម ប៊ូស្នៀ នៅឯ ស្រ៊ីប្រ៊ីនីកា បានកើតមានឡើង ។ ដូច្នេះការសម្លាប់ និងការធ្វើបាបដោយរើសអើងបន្ថែមទៀតមកលើជនជាតិម៉ូស្លីមនៅក្នុងតំបន់ដែលដឹងទុកមុនបានពីជនជាប់ចោទ ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមទម្រង់សហឧក្រិដ្ឋកម្មរួមទីបីសម្រាប់ឧក្រិដ្ឋកម្មដោយចេតនាជាក់លាក់ណាមួយនោះ ព្រះរាជអាជ្ញាត្រូវតែអះអាងឲ្យឃើញថា ជនជាប់ចោទអាចដឹងជាមុនថាឧក្រិដ្ឋកម្មដែលត្រូវបានពង្រីកនោះអាចនឹងកើតមានឡើង ហើយឧក្រិដ្ឋកម្មនេះនឹងប្រព្រឹត្តឡើងដោយចេតនាជាក់លាក់មួយ" ។ ដូច្នេះ សាលក្រមសម្រាប់រឿងក្តី ប៊ូប៊ូរីក និងជនផ្សេងទៀតទំនងជាផ្តល់ជាមូលដ្ឋានគ្រឹះដល់ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ខាងមុខក្រោមទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ ។

**ឌ) ទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ និងបទចោទប្រកាន់ពីឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ នាពេលបច្ចុប្បន្ននេះ**

អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសម្រេចយ៉ាង

ច្បាស់នៅក្នុងរឿងក្តីរបស់ ព្រីចានីន ថាទម្រង់សហឧក្រិដ្ឋកម្មរួមទី៣គឺដូចគ្នានឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត អាស្រ័យហេតុនេះ គ្មានហេតុផលណាមួយដែលរារាំងមិនឲ្យមានការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ និងចេតនាឧក្រិដ្ឋជាក់លាក់ផ្សេងទៀតក្រោមគោលការណ៍ ការទទួលខុសត្រូវរបស់មេដឹកនាំ និងគោលការណ៍ការជួយ និងការជំរុញ ក្រៅពីគោលការណ៍របស់ទម្រង់សហឧក្រិដ្ឋកម្មរួមទី៣នេះបានឡើយ ។ សេចក្តីសម្រេចនេះត្រូវបានទទួលស្គាល់ បើទោះបីជាមានកត្តាប្រឈមជាច្រើនដែលកើតមាននៅក្នុងរឿងក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសម្រាប់រ៉្វាន់ដា ដូចជារឿងក្តី មីឡូសេវិក, រ៉ាម៉ាគូបា និង ការ៉ាត់ហ្សិក ។ ដូច្នេះ តាមទ្រឹស្តីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសម្រាប់រ៉្វាន់ដា បញ្ហាចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍គឺជាបញ្ហាដែលត្រូវបានទុកចោលមិនទាន់ដោះស្រាយ ។

យ៉ាងណាមិញ តុលាការអន្តរជាតិទំនងជាស្ទាក់ស្ទើរនឹងដោះស្រាយបញ្ហាថាតើជនជាប់ចោទអាច "ប្រព្រឹត្ត" អំពើប្រល័យពូជសាសន៍តាមទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ ហើយជាញឹកញាប់តុលាការអន្តរជាតិទាំងអស់តែងតែពឹងផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី ព្រីចានីន ទាក់ទងនឹងបញ្ហានេះដោយគ្មានការពិភាក្សាបន្ថែម នៅពេលដែលបញ្ហានេះកើតឡើង ។ បន្ថែមលើនេះ អ្នកប្រាជ្ញជាច្រើនជារឿយៗតែងតែរិះគន់គោលការណ៍នៃទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ចំពោះភាពអាចអនុវត្តបានជាទូទៅ និងជាក់លាក់របស់ទម្រង់នេះសម្រាប់ករណីបទចោទប្រកាន់ឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ ដោយអះអាងថាទម្រង់សហឧក្រិដ្ឋកម្មរួមទី៣គឺជាមធ្យោបាយមួយសម្រាប់ការផ្តល់ជាភ័ស្តុតាងសំខាន់លើចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

### ឋ) សេចក្តីសន្និដ្ឋាន

ខណៈដែលសំណុំរឿង០០២ចាប់ផ្តើមដំណើរការ យើងបានយល់ឃើញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តីខ្មែរក្រហមអាចនឹងផ្តល់សេចក្តីលម្អិតបន្ថែមលើភាពអាចអនុវត្តបាននៃទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ក្នុងករណីបទចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ បើទោះបីជាវិធីសាស្ត្រនេះអាចនឹងកែលម្អមតិរិះគន់លើទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ក៏ដោយ ក៏វិធីសាស្ត្រនេះអាចនឹងធ្វើឲ្យសេចក្តីសម្រេចរបស់សាលាក្តីខ្មែរក្រហមមានលក្ខណៈខុសប្លែកពីសេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសម្រាប់ប្រទេសរ៉្វាន់ដា ទាក់ទងនឹងបញ្ហាទម្រង់សហឧក្រិដ្ឋកម្មរួមទី៣នេះ ។ អង្គជំនុំជម្រះសាលាដំបូងអាចនឹងដើរតាមវិធីសាស្ត្រនៅក្នុងរឿងក្តី ប៉ូប៉ូវីក និងជនផ្សេងទៀត ហើយប្រើប្រាស់ទម្រង់នៃការទទួលខុសត្រូវរបស់មេដឹកនាំក្នុងករណីដែលទម្រង់សហឧក្រិដ្ឋកម្មរួមទី៣អាចអនុវត្តបានក្នុងបទចោទប្រកាន់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ប៉ុន្តែ ប្រសិនបើប្រឈមមុខនឹងបញ្ហាការទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមទម្រង់សហឧក្រិដ្ឋកម្មរួមទី៣ នោះជម្រើសដោះស្រាយបញ្ហានេះប្រហែលជាគ្មានឡើយ ហើយជាលទ្ធផលសាលាក្តីខ្មែរក្រហមអាចនឹងបង្ខំចិត្តពិភាក្សាស្វែងរកដំណោះស្រាយ ប្រសិនបើព្រះរាជអាជ្ញា ដឹកកកាយបញ្ហានោះជ្រុលហួសហេតុពេក ។ នៅក្នុងករណីនេះ សាលាក្តីខ្មែរក្រហមអាចនឹងធ្វើដូចតាមតុលាការផ្សេងទៀតដោយគេចវេះពីបញ្ហានេះ ហើយងាកមកប្រឈមមុខនឹងកត្តាប្រឈម និងភាពស្មុគស្មាញនៃភាពជាប់ពាក់ព័ន្ធរបស់ទម្រង់សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ក្នុងករណីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

**រ៉ែនដល ដឺហ្វាល់ក្វ**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩" និង "សៀវភៅណែនាំគ្រូបង្រៀន" ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# ការពិនិត្យមើលសារឡើងវិញលើការចរចារឆ្ពោះទៅរកការបង្កើតយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

***(តពីលេខមុន)***

## *ប្រតិកម្មរបស់កម្ពុជានិងការតាមដានកិច្ចការរបស់អង្គការសហប្រជាជាតិ*

*ក្នុងការឆ្លើយតបពីដំបូងទៅនឹងរបាយការណ៍ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរទៅ កូហ្វី អាណាន់ នៅថ្ងៃទី៣ ខែមិនា ឆ្នាំ១៩៩៩ ដែលហាក់បីដូចជាគាំទ្រចំពោះការដែលនាំយកត្រឹមតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ទៀតថា ការប្តេជ្ញាចិត្តរបស់គាត់ក្នុងការនាំទៅរកការទទួលខុសត្រូវចំពោះមេដឹកនាំ ហើយគាត់ក៏បានបញ្ជាក់ថា គាត់មិនគ្រោងកាត់ទោសកម្មាភិបាលខ្មែរក្រហមដែលមានឋានៈតូចតាចទេ ។ រដ្ឋមន្ត្រីការបរទេសកម្ពុជា ហោ ណាំហុង បានបញ្ជាក់ថា ក្នុងចំណោមអ្នកដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន អះអាងចំពោះមេដឹកនាំនោះគឺ នួន ជា, តាម៉ុក និង ខៀវ សំផន ។*

*តែនៅក្នុងចំណារមួយដែលបានចេញផ្សាយក្នុងប្រព័ន្ធសារព័ត៌មានកាលពីថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៩ អង្គការសហប្រជាជាតិហាក់បីដូចជាគាំទ្រចំពោះទស្សនៈរបស់ក្រុមអ្នកជំនាញដែលចង់ឲ្យមានការកាត់ទោសមេដឹកនាំច្រើននាក់ ហើយចំណារនោះបានបញ្ជាក់ថា គ្រប់មេដឹកនាំខ្មែរក្រហមទាំងអស់ដែលមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋ និងជាគោលដៅក្នុងការនាំទៅកាន់តុលាការ ។ ទោះបីជាអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានបញ្ជាក់នៅក្នុងជំនួបប្រជុំនៅថ្ងៃនោះថា ចំនួនមេដឹកនាំខ្មែរក្រហមនិងជនដែលត្រូវសង្ស័យមានចំនួនតិចណាស់ ហើយលោកក៏បានទទូចថា ខ្មែរក្រហមបានគំរាមកំហែងផ្នែកយោធាអស់រយៈពេលយ៉ាងយូរ ហើយស្ថេរភាពប្រទេសនឹងមិនជាធ្ងន់ធ្ងរទេប្រសិនបើមិនមានការគំរាមកំហែងពីសំណាក់ខ្មែរក្រហម ។ ការគូសចំណាំពីការទូតនេះ គឺជាអ្វីដែលអង្គការសហប្រជាជាតិយល់ព្រមចំពោះទស្សនៈនេះដែលសហរដ្ឋអាមេរិកចង់បានកាលពីខែកុម្ភៈ ក្នុងការពង្រីកចំនួនជនសង្ស័យដើម្បីជាគោលដៅក្នុងការស៊ើបអង្កេត ដោយផ្អែកទៅលើការគិតគូរទុកជាមុនថា ការកាត់ទោសរាប់ចាប់ពីមេដឹកនាំសំខាន់ៗជាមុនតែជំហានដំបូងអាចនឹងស៊ីពេលច្រើនដើម្បីអនុវត្តវិសាលភាពនៃចំនួនអ្នកត្រូវកាត់ទោសនិងពង្រីងពីដំណាក់កាលមួយទៅដំណាក់កាលមួយ ។*

*ម្យ៉ាងវិញទៀត សេចក្តីថ្លែងការណ៍ផ្សេងទៀតរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ហាក់បីដូចជាមិនបញ្ចេញនូវគោលការណ៍ណាមួយទេ ហើយគាត់បានប្រកាសថា «ក្នុងការដែលចោទប្រកាន់ទៅលើមេដឹកនាំផ្សេងទៀតក្រៅពី តាម៉ុក គឺជាយុត្តាធិការរបស់តុលាការក្នុងការធ្វើការចោទប្រកាន់អ្វីមួយ ។ ខ្លួនខ្ញុំផ្ទាល់ និងអ្នកផ្សេងទៀតមិនមានសិទ្ធិអ្វីទាំងអស់ក្នុងការចោទប្រកាន់អ្នកនេះឬអ្នកនោះទេ ឬក៏មិនអាចធ្វើការវិនិច្ឆ័យមុនអំពីចំនួនមេដឹកនាំដែលនិងត្រូវយកទៅកាត់ទោសដែរ ។ ខ្លួនខ្ញុំផ្ទាល់មិនដែលផ្តល់ការធានាណាមួយថានរណានិងត្រូវឬមិនត្រូវកាត់ទោសពីការចោទប្រកាន់ដែលចេញដោយតុលាការទេ» ។ ជំហររបស់អង្គការសហប្រជាជាតិត្រូវបានបកស្រាយនៅក្នុងលិខិតរបស់ កូហ្វី អាណាន់ កាលពីថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ ដែលបង្ហាញអំពីរបាយការណ៍របស់ក្រុមអ្នកជំនាញដែលបានផ្ញើទៅកាន់សភាអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខដោយប្រកាសថា «តាមទស្សនៈខ្ញុំ មេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរគួរតែត្រូវបាននាំយកទៅរកភាពយុត្តិធម៌» ។ លោក កូហ្វី អាណាន់ បានបញ្ជាក់ទៀតថា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់ទៅក្រុម*

អ្នកជំនាញថា រដ្ឋាភិបាលកម្ពុជាមានឆន្ទៈនិងត្រៀមរួចជាស្រេចក្នុងការឈានទៅរកការចោទប្រកាន់នរណាមួយដែលនឹងទទួលខុសត្រូវតែនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏មានក្តីបារម្ភដែរថា តុលាការនេះអាចបង្កឲ្យមានភាពជ្រួលច្របល់ក្នុងបណ្តាអតីតកម្មាភិបាលខ្មែរក្រហម និងកម្មាភិបាលតូចតាច បើសិនជារដ្ឋាភិបាលកម្ពុជាមិនបានធ្វើឲ្យត្រឹមត្រូវ ។ កូហ្វី អាណាន់ បានបញ្ជាក់ជាថ្មីទៀតអំពីទស្សនៈរបស់គាត់នៅក្នុងលិខិតឆ្លើយឆ្លងកាលពីថ្ងៃទី២៨ ខែមិនា ទៅកាន់សមាជិករបស់ក្រុមអ្នកជំនាញដោយបានសរសេររបាយការណ៍នោះថា មានលក្ខណៈវិភាគជ្រៅជ្រះផ្នែកច្បាប់ ហើយគាត់បានអះអាងច្បាស់ថាមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរគួរតែត្រូវនាំខ្លួនទៅតុលាការ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរលិខិតមួយទៅកាន់ កូហ្វី អាណាន់ នៅថ្ងៃដដែលនោះដោយនិយាយថា បើនិយាយពីបញ្ហាត្រង់ថាមេដឹកនាំខ្មែរក្រហមមួយណានិងត្រូវយកមកកាត់ទោសគឺអាស្រ័យទៅលើដែនសមត្ថកិច្ចរបស់តុលាការទាំងស្រុង ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ពីជំហររបស់ខ្លួនភ្លាមចំពោះភាពត្រៀមទុករួចជាស្រេចដើម្បីដើរតាមវិធីដែលនាំទៅរកការពង្រីកវិសាលភាពនៃការកាត់ទោស ដោយនិយាយនៅក្នុងជំនួបមួយជាមួយព្រឹទ្ធសមាជិក ចន ឃែរី ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់ទៅ ឃែរី ថា គាត់មិនចង់ចាប់ផ្តើមស៊ើបអង្កេតដោយយកសំណាញ់ធំទេ តែត្រូវស៊ើបអង្កេតដោយស្របច្បាប់មួយដែលផ្តល់ដោយភ័ស្តុតាងគ្រប់គ្រាន់ ពេលនោះបុគ្គលច្រើននាក់នឹងត្រូវកាត់ទោស ។

នៅក្នុងការរាយការណ៍ទៅអង្គការសហប្រជាជាតិ ឃែរី បានអះអាងថា ប្រសិនបើសញ្ញាណនេះត្រូវបង្កើតឡើងថា ការស៊ើបអង្កេតអាចធ្វើបែបនេះ នោះដំណើរការនឹងអាចចាប់ផ្តើមភ្លាមដោយផ្តល់ឲ្យដែនសមត្ថភាពដល់សហគមន៍អន្តរជាតិក្នុងការពង្រីកសំណាញ់ដើម្បីវិនិច្ឆ័យជនសង្ស័យបន្ថែមទៀត ។ សេចក្តីថ្លែងការណ៍ជាសាធារណៈមួយដោយគណៈរដ្ឋមន្ត្រីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ទាក់ទងនឹងការពិភាក្សាជាមួយព្រឹទ្ធសមាជិក ចន ឃែរី បានបកស្រាយថា ការជាប់ពិរុទ្ធនិងការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្សេងទៀតគឺជាដែនសមត្ថកិច្ចរបស់តុលាការ ។ រាជរដ្ឋាភិបាលកម្ពុជាមិនមានសិទ្ធិ និងបញ្ជាឲ្យតុលាការធ្វើនេះឬធ្វើនោះទេ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់ស្រដៀងគ្នានេះដែរទៅកាន់ ថូម៉ាស់ ហាំម៉ាប៊ើក ថា សេចក្តីសម្រេចចិត្តក្នុងការចាត់នរណាម្នាក់ជាពិរុទ្ធជនគឺជាសិទ្ធិរបស់តុលាការ ។ ជំហរនេះត្រូវបានគាំទ្រដោយមន្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជាដូចជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង ដែលបានប្រាប់អង្គការសហប្រជាជាតិនៅទីក្រុងភ្នំពេញថា ឌុច ដែលកំពុងតែជាប់ឃុំបានឆ្លើយដាក់អ្នកផ្សេងទៀតអំឡុងពេលនៃការសួរចម្លើយ ហើយ ស ខេង បញ្ជាក់ទៀតថា អ្នកដែលត្រូវយកមកកាត់ទោសមិនមែនត្រឹមតែ នួន ជា និង ខៀវ សំផន ប៉ុណ្ណោះទេ តែក៏រាប់ទាំង អៀង សារី និងមេដឹកនាំខ្មែរក្រហមដទៃទៀតដែរដោយអាស្រ័យទៅលើថាតើអ្នកនោះមានការជាប់ពាក់ព័ន្ធ និងការសម្លាប់ដែរឬអត់ ។

នៅក្នុងការធ្វើបទបង្ហាញកាលពីខែមេសា ឆ្នាំ១៩៩៩ ទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ថូម៉ាស់ ហាំម៉ាប៊ើក បានគាំទ្រចំពោះអនុសាសន៍របស់ក្រុមអ្នកជំនាញថា ការកាត់ទោសគឺសំដៅទៅលើអ្នកណាដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងការរំលោភធ្ងន់ធ្ងរដោយរាប់បញ្ចូលមិនត្រឹមតែមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវនៅក្នុងការរំលោភធ្ងន់ធ្ងរនេះប៉ុណ្ណោះទេ តែក៏រាប់ដល់កម្មាភិបាលថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើឃោរឃៅនោះផ្ទាល់ផងដែរ ។ របាយការណ៍ផ្ទាល់ខ្លួនរបស់ កូហ្វី អាណាន់ ផ្ញើទៅគណៈកម្មាធិការសិទ្ធិមនុស្សបានអំពាវនាវឲ្យដាក់សម្ពាធផ្លូវច្បាប់ប្រឆាំង និងមេដឹកនាំខ្មែរក្រហម ។ លោក កូហ្វី អាណាន់ បានប្រើប្រាស់ភាសារបស់របាយការណ៍អ្នកជំនាញដោយធ្វើការពន្យល់ចំពោះអនុសាសន៍របស់ក្រុមអ្នកជំនាញថា ៈ

> តាមគោលការណ៍តុលាការ ព្រះរាជអាជ្ញាកំហិតការស៊ើបអង្កេតរបស់ខ្លួនចំពោះនរណាដែលបានទទួលខុសត្រូវបំផុតចំពោះការរំលោភសិទ្ធិដ៏ធ្ងន់ធ្ងរបំផុតចំពោះច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ការកាត់ទោសរួមបញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវចំពោះអ្នកដែលប្រព្រឹត្តបទល្មើស និងអ្នកដែលនៅក្រោមបង្គាប់ដែលជាអ្នកប្រព្រឹត្តអំពើឃោរឃៅបំផុត ។ ក្រុមអ្នកជំនាញបាន

គូសបញ្ជាក់ថា បញ្ជីឈ្មោះរបស់កម្មាភិបាលបក្ស និង រដ្ឋាភិបាល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមិន ទាក់ទងជាមួយនឹងបញ្ជីឈ្មោះមនុស្សដែលទទួលខុសត្រូវ ខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតត្រង់ ថាថ្នាក់ដឹកនាំរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នដែលមិនធ្លាប់ជា បុគ្គលដែលអាចធ្វើការសម្រេចចិត្តនៅក្នុងច្រវាក់នៃការ បញ្ជា ឬថ្នាក់ដឹកនាំនោះមិនត្រូវបានឲ្យដឹងអ្វីឡើយ ។ ចំណែកឯ មេដឹកនាំផ្សេងទៀតដែលមិនមានឈ្មោះនៅក្នុង តារាងនៃមេដឹកនាំជាន់ខ្ពស់អាចនឹងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងអំពើឃោរឃៅ ។ ក្រុមអ្នកជំនាញក៏បានបញ្ជាក់ថា ចំណុចនេះក៏អាចត្រូវខ្វះដែរចំពោះមេដឹកនាំតាមភូមិភាគ និងកម្មាភិបាលដែលបានធ្វើទារុណកម្ម និងសួរចម្លើយ ដូចជានៅគុកទួលស្លែងជាដើម ។

ដោយសារកាលៈទេសៈនោះ គណៈកម្មាធិការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិក្រោយមកបានព្រមព្រៀងទៅនិង សេចក្តីសម្រេចមួយដោយផ្តល់រូបមន្តឲ្យធ្វើការពិគ្រោះជាមួយ និងរាជរដ្ឋាភិបាលកម្ពុជាដោយបានអំពាវនាវយ៉ាងទទូចម្តងទៀត ទៅកាន់រដ្ឋាភិបាល ដើម្បីចាត់វិធានការណ៍ចាំបាច់ទាំងអស់ដើម្បី ធានាថា ជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើរំលោភបំពាន សិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ បំផុតគួរត្រូវបាននាំទៅរកការកាត់ទោស ។ ពេលនោះដែរ រដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ដែលដើរតួជាអ្នក តំណាងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់ដំណឹងទៅការិយា ល័យរបស់អង្គការសហប្រជាជាតិនៅកម្ពុជាថា ព្រះរាជអាជ្ញា និង ចៅក្រមរបស់តុលាការ និងមានសេរីភាពពេញបរិបូរណ៍ក្នុងការធ្វើ សេចក្តីសម្រេចចំពោះភស្តុតាងដែលជននោះបានប្រព្រឹត្ត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្ទាល់បានសរសេរលិខិតមួយទៅ កូហ្វី អាណាន់ នៅថ្ងៃទី២៨ ខែមេសា ដោយអះអាងដូចកាលលើក មុនថា ដែនកំណត់សម្រាប់ការចោទប្រកាន់និងការកាត់ទោស មេដឹកនាំខ្មែរក្រហមគឺជាភារកិច្ចរបស់តុលាការក្នុងការសម្រេចចិត្ត ។ នៅថ្ងៃដដែលនោះដែរ លោក ថូម៉ាស់ ហាំម៉ាប៊ើក បានធ្វើពង្រាង លិខិតមួយច្បាប់ទៅកាន់ កូហ្វី អាណាន់ ដែលនៅក្នុងលិខិតនោះ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងអំពីដំណើរការដើម្បីកាត់ទោស អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតពីបទអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មដទៃទៀតដែលរំលោភបំពានមនុស្សជាតិ ដោយ អំពាវនាវឲ្យប្រើរូបមន្តដែលអគ្គលេខាអង្គការសហប្រជាជាតិក្នុង ការបញ្ជូនរបាយការណ៍របស់ក្រុមអ្នកជំនាញទៅកាន់ក្រុមប្រឹក្សា សន្តិសុខ និង អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ពេលនោះ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរថា មេដឹកនាំខ្មែរក្រហម ដែលទទួលខុសត្រូវខ្ពស់បំផុតពីបទឧក្រិដ្ឋគួរតែត្រូវនាំយកទៅរក ភាពយុត្តិធម៌ ។

ទោះបីជាមានទស្សនៈស្រដៀងគ្នាក៏ដោយ អង្គការសហ ប្រជាជាតិមានក្តីបារម្ភថា រាជរដ្ឋាភិបាលអាចនឹងមិនធ្វើតាមការ តាំងចិត្តរបស់ខ្លួននិងបារម្ភទៀតថា ភាសាដែលបានប្រើប្រាស់ ដើម្បីរៀបរាប់អំពីវិសាលភាពនៃការកាត់ទោសគឺមានភាពមិន ច្បាស់លាស់ទេ ។ នៅក្នុងកំណត់ត្រាមួយថ្លែងទៅកាន់ព្រឹទ្ធសមាជិក ចន ឃែរី នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ កូហ្វី អាណាន់ បាន សម្តែងនូវការព្រួយបារម្ភថា រាជរដ្ឋាភិបាលកម្ពុជាអាចនិងចាប់ ផ្តើមដោយបង្កើតសវនាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ជាក់លាក់ណាមួយ ហើយអាចនិងទុកឲ្យមេដឹកនាំសំខាន់ៗផ្សេង ទៀតរួចទោសទណ្ឌ ។ កំណត់ត្រានោះដែរបានបញ្ជាក់បន្ថែមទៀត ថា បើសិនជាដូច្នេះមែននោះនឹងមិនបម្រើភាពយុត្តិធម៌ និងការ ទទួលខុសត្រូវទេ ។ អង្គការសហប្រជាជាតិចង់ឲ្យរដ្ឋាភិបាលកម្ពុជា ធានាអះអាងថា សេចក្តីសម្រេចផ្លូវច្បាប់និងអាជ្ញាយុកាលគឺថា មេដឹកនាំខ្មែរក្រហមណាដែលត្រូវចោទប្រកាន់ដោយតុលាការគួរ តែត្រូវបានចាប់ខ្លួន និងដោយសម្អាងលើភស្តុតាងដែលមានស្រាប់ ។ ជំហររបស់អង្គការសហប្រជាជាតិគឺថា តុលាការដែលត្រូវកាត់ ទោសមេដឹកនាំខ្មែរក្រហមដែលជ្រើសរើសដោយរាជរដ្ឋាភិបាល កម្ពុជាដែលរារាំងមេដឹកនាំផ្សេងទៀតដែលរស់នៅប្រទេសកម្ពុជា ពីដំណើរការច្បាប់ គឺទម្រង់មិនអាចទទួលយកបាននូវភាពយុត្តិធម៌ ។ អង្គការសហប្រជាជាតិបានជំទាស់ទៅនិងសំណើណាមួយត្រង់ថា ដំណើរការតុលាការដោយកាត់ទោសមេដឹកនាំដោយជ្រើសរើស ដោយរាជរដ្ឋាភិបាលណាមួយនិងមិនអាចទទួលយកបានទេ ។

**ស្វីខ ហេះឌី**

***(នៅមានត)***



# ទីបញ្ចប់នៃសមមិត្ត ឌុច

នៅពេលដែលខ្ញុំបានឃើញសមមិត្ត ឌុច ត្រូវបានកាត់ទោសឲ្យជាប់ពន្ធធនាគារអស់មួយជីវិតនៅឯសាលាក្តីខ្មែរក្រហមកាលពីដើមខែនេះ វាហាក់បីដូចជាទីបញ្ចប់នៃរឿងរ៉ាវដ៏វែងឆ្ងាយដែលបានចាប់ផ្តើមឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៩ ក្នុងអំឡុងពេលដែលខ្ញុំបានធ្វើជាអ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានបរទេសចំនួនប្រាំមួយនាក់ត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញសម្រាប់រយៈពេលមួយថ្ងៃក្រោយថ្ងៃរំដោះរបស់កងទ័ពវៀតណាមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

ខ្ញុំហាក់បីដូចជាបានរស់នៅជាមួយ ឌុច នេះជាឈ្មោះបដិវត្តន៍សម្រាប់អតីតគ្រូគណិតវិទ្យាឈ្មោះ កាំង ហ្គេកអ៊ាវ ចាប់តាំងពីសាមសិបបីឆ្នាំមុននៅពេលដែលខ្ញុំបានឃើញរូបថតរបស់គាត់នៅលើឥដ្ឋការ៉ូក្នុងអតីតសាលារៀនទួលស្លែងដែលបានប្រែក្លាយជាមន្ទីរស-២១ ជាមន្ទីរសួរចម្លើយនិងធ្វើទារុណកម្មដ៏សាហាវព្រៃផ្សៃបំផុតនៅក្នុងប្រទេសកម្ពុជា ។ នាពេលនោះមន្ទីរស-២១ នេះពោរពេញទៅដោយឈាមក្នុងអគារនីមួយៗ ហើយអារម្មណ៍នៃសម្រែកដង្ហើយហៅជាលើកចុងក្រោយ ហាក់បីដូចជាមាននៅក្នុងបន្ទប់អគារទាំងនោះនៅឡើយ ។ ទីកន្លែងដ៏សាហាវនេះគឺពោរពេញទៅដោយការសម្លាប់ភាពភ័យខ្លាចនិងការបោះបង់ចោល ។

រូបថតនោះគឺជារូបថតរបស់ ឌុច ដែលមានត្រចៀកដូចសត្វប្រចៀវជាមួយប្រពន្ធនិងកូនពីរនាក់ទៀតរបស់ ឌុច រួមជាមួយអ្នកធ្វើទារុណកម្មនៅគុកទួលស្លែង ផ្សេងៗទៀតដែលកំពុងតែឈរជាក្រុមដើម្បីថតរូប ។ ការថតរូបនេះគឺប្រៀបបីដូចជាការថតរូបជាក្រុមពេលបញ្ចប់វគ្គសិក្សាដូច្នោះដែរ ។ ក្រោយមកទៀតខ្ញុំបានដឹងថា គ្រួសាររបស់ ឌុច មានទីលំនៅនៅស្រុកស្ទោងភាគខាងជើងនៃបឹងទន្លេសាប ។ ខ្ញុំក៏បានឃើញឯកសារដែរចុះហត្ថលេខាដោយ ឌុច រួមមានឯកសារដែលសរសេរឈ្មោះ និងអាយុរបស់ក្រុមយោធាខ្មែរក្រហមមួយមានចំនួនប្រាំបួននាក់មកដល់មន្ទីរ

ស-២១ ។ ក្នុងនោះអាយុក្មេងជាងគេបង្អស់គឺអាយុប្រាំបួនឆ្នាំ ។ ឌុច បានសរសេរជាភាសាខ្មែរថា "សម្ងាប់កុំឲ្យសល់ម្នាក់" ។

នៅទីក្រុងភ្នំពេញឆ្នាំ១៩៧៩ក្នុងថ្ងៃនោះ ខ្ញុំបានចូលរួមក្នុងពិធីទទួលស្វាគមន៍ជាផ្លូវការនិងការថ្លែងសុន្ទរកថារបស់របបគ្រប់គ្រងថ្មីដែលគាំទ្រដោយវៀតណាម បានចូលរួមក្នុងការប្រជុំនៅឯទីស្នាក់ការអាណានិគមបារាំងចាស់ នៅក្បែរទន្លេសាបដែលប្រសព្វគ្នាជាមួយនឹងទន្លេមេគង្គ ហើយខ្ញុំបានឃើញប្រជាជនកម្ពុជាក្នុងសភាពក្រខ្សត់កំពុងតែលូនក្រាបលើដីដើម្បីទទួលយករបបអង្ករបស់ខ្លួន ។ ក្រុមមនុស្សស្គមស្គាំងដ៏គួរឲ្យអាណិតទាំងនេះបានញញឹមដោយភាពអៀនខ្មាស់មកកាន់ជនជាតិបរទេសពីរនាក់មុននឹងប្រឹងងើបឡើងហើយដើរទ្រេតទ្រោតចេញទៅទំនងជាមិនចង់ឲ្យការរងទុក្ខលំបាកវេទនាស្គមស្គាំងរបស់គេធ្វើឲ្យទើសភ្នែកយើង ហើយក៏មិនចង់ឲ្យយើងមានប្រតិកម្មមកលើទិដ្ឋភាពនៃការរងទុក្ខវេទនារបស់គេឡើយ ។ សព្វថ្ងៃនេះ ទីក្រុងភ្នំពេញបានក្លាយជាទីក្រុងគួរឲ្យទាក់ទាញដោយសារស្រាទំពាំងបាយជូរល្អៗ និងភោជនីយដ្ឋានទំនើបៗ រួមទាំងអ្នកសុំទានផងដែរ ។

កងយោធាវៀតណាមកំពុងតែចាកចេញពីសង្គ្រាមក្នុងរថយន្តផលិតនៅសហភាពសូវៀតដោយមានដឹកជញ្ជូនសព្វាវុធជាបន្តបន្ទាប់ ។ យោធាទាំងនេះបានលើកដៃបាំងមុខដើម្បីកុំឲ្យខ្ញុំថតរូប ប៉ុន្តែវាមិនមានអ្វីធ្ងន់ធ្ងរទេ ។ តាមពិតយោធាទាំងនេះចង់ឲ្យមនុស្សទូទៅចងចាំខ្លួន (រូបថតទាំងអស់នេះត្រូវបានចុះផ្សាយនៅក្នុងកាសែត Newsweek ជាក្រុមហ៊ុនកាសែតដែលខ្ញុំបានធ្វើការឲ្យនាអំឡុងពេលនោះ) ។ រយៈពេលប៉ុន្មានខែក្រោយមក មន្ត្រីរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានផ្តល់ទិដ្ឋាការសម្រាប់ការស្នាក់នៅរយៈពេលយូរមកដល់ខ្ញុំ ហើយខ្ញុំបានធ្វើដំណើរតាមរថយន្តម៉ាកឡាដាពណ៌ក្រហមរបស់សូវៀតរួមជាមួយអ្នកសារព័ត៌មាន និងអង្គរក្សរដ្ឋាភិបាលជុំវិញបឹងទន្លេសាប ។ យើងបានសម្រាកមួយយប់នៅសណ្ឋាគារស្ងាត់ជ្រងំដ៏ល្បីឈ្មោះមួយនៅខេត្តសៀមរាបដែលមានពាក្យចចាមអារ៉ាមថាមានខ្មោចលងពីព្រោះសណ្ឋាគារនេះធ្លាប់ជាមន្ទីរធ្វើទារុណកម្មរបស់ខ្មែរក្រហម ។ ខ្ញុំបានទៅទស្សនាប្រាសាទអង្គរវត្តដែលមានការយាមកាមដោយកងប្រដាប់អាវុធជាកងទ័ពរបស់សមមិត្ត "ហេង សំរិន" ។

សមមិត្ត ហេង សំរិន គឺជាមេបញ្ជាការដ៏ស្គមម្នាក់ និងជាអតីតកម្មាភិបាលខ្មែរក្រហមដែលបានចូលរួមជាមួយនឹងកងទ័ពវៀតណាមក្នុងការវាយចូលប្រទេសកម្ពុជានៅខែធ្នូ ឆ្នាំ១៩៧៨ ហើយទម្លាក់ ប៉ុល ពត និងរបបដ៏សាហាវរបស់ខ្មែរក្រហមចេញពីអំណាច ។ តាមអ្វីដែលខ្ញុំបានដឹងនៅគុកទួលស្លែង សមមិត្ត ឌុច គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សចុងក្រោយបង្អស់ដែលរត់គេចខ្លួនចេញពីទីក្រុងដែលបានឃើញអ្នករស់រានមានជីវិតពីមន្ទីរស-២១ពីរនាក់ក្នុងចំណោមប្រាំពីរនាក់ផ្សេងទៀតនៃអ្នកទោសចំនួន១៤,០០០នាក់ដែលរួចរស់មានជីវិតដោយសារតែជំនាញគូររូប ប៉ុល ពត ឬជួសជុលឡាននិងម៉ាស៊ីនផ្សេងៗ ។

នៅស្រុកស្ទោង ខ្ញុំបានជួបជាមួយនឹងគ្រួសាររបស់ ឌុច ហើយបាននិយាយជាមួយម្តាយរបស់គាត់ ដែលមានមុខមាត់ស្រដៀងគ្នា និងកូនប្រុសរបស់គាត់ដែរ ។ គាត់មិនបានដឹងថា ឌុច មានគ្រួសារនោះទេ រហូតដល់ពេលគាត់បានឃើញរូបថតចៅរបស់គាត់នៅគុកទួលស្លែង ។

គាត់បានរៀបរាប់ថា នៅក្នុងរបបខ្មែរក្រហមកូនប្រុសដ៏មានវិន័យរបស់គាត់បានបញ្ជូនឡានមួយមកទទួលគាត់ទៅភ្នំពេញដើម្បីសួរសុខទុក្ខរយៈពេលខ្លី ។ គាត់បាននិយាយប្រាប់ខ្ញុំថា "ខ្ញុំមិនដឹងថាហេតុអ្វីបានជាទីក្រុងមានសភាពស្ងាត់ជ្រងំ ហើយគ្មានចរន្តអគ្គិសនីនាពេលយប់ទេ" ។

រហូតមកដល់ឆ្នាំ២០០៦ ទើបសាលាក្តីខ្មែរក្រហមត្រូវបានបង្កើតឡើង ហើយខ្ញុំក៏បានឃើញ ឌុច នៅក្នុងតុលាការ ។ ឌុច បានរស់នៅលាក់ខ្លួនអស់រយៈពេលម្ភៃឆ្នាំ រហូតដល់ពេលដែលគាត់ត្រូវបានរកឃើញដោយអ្នកថតរូបជនជាតិអៀរឡង់ ឈ្មោះនីក ឌុនឡុប ។ កាលនោះ ឌុច ធ្វើការឲ្យភ្នាក់ងារជំនួយសាសនាគ្រិស្តនៅព្រំប្រទល់កម្ពុជា-ថៃ ។ ក្រោយមក ឌុច ត្រូវបានចាប់ខ្លួន និងឃុំឃាំងដោយរបបគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។

សព្វថ្ងៃនេះ ភ្ញៀវទេសចរណ៍អាចមើលឃើញរូបថតសម្តេច ហ៊ុន សែន ជាមួយនឹងប្រធានរដ្ឋសភា ហេង សំរិន និងប្រធានព្រឹទ្ធសភា ជា ស៊ីម ដែលអ្នកទាំងបីជាអតីតខ្មែរក្រហម ។ នៅក្នុងរូបថតនោះ សម្តេច ហ៊ុន សែន នៅចំកណ្តាល ។ រូបថតរបស់អ្នកទាំងបីត្រូវបានដាក់បង្ហាញនៅតាមទីក្រុង ភូមិ និងតំបន់

នានាក្នុងន័យផ្សព្វផ្សាយពីគណបក្ស ។

នៅចុងខែកក្កដា ឆ្នាំ២០១០ ខ្ញុំបានឃើញអតីតមេបញ្ជាការមន្ទីរស-២១ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ៣៥ឆ្នាំសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ដោយសារតែរាប់បញ្ចូលថេរវេលាដែល ឌុច បានជាប់ឃុំឃាំងនិងកត្តាផ្សេងទៀតនោះ ឌុច ទំនងជាជាប់ពន្ធនាគារត្រឹមរយៈពេល១៩ឆ្នាំតែប៉ុណ្ណោះ នេះអាចផ្តល់លទ្ធភាពមួយថា ឌុច អាចនឹងនៅរស់មានសេរីភាពម្តងទៀតបាន ។ លទ្ធភាពនេះបានបណ្តាលឲ្យមានការខឹងសម្បា ភាពភ័យខ្លាច និងភាពអាប់អួរដល់ប្រជាជនកម្ពុជាជាច្រើននាក់ ។

មនុស្សទូទៅបានកត់សម្គាល់ទោសនេះទំនងជាមានទម្ងន់ស្រាលពេកសម្រាប់បុរសម្នាក់ដែលបានប្រឡាក់ទៅដោយឈាម ដូចសាក្សីម្នាក់បានធ្វើសក្ខីកម្មពីសកម្មភាពរបស់ ឌុច ។ ឌុច បានសារភាពថាខ្លួនបានបង្ហូរឈាមមនុស្សជាច្រើននិងសម្លាប់មនុស្សតាមវិធីនេះ ។ ការធ្វើទារុណកម្មនៅគុកទួលស្លែងរួមមានការបង្ខំឲ្យអ្នកទោសស៊ីលាមក ការវាយនឹងខ្សែតី ការឆក់ខ្សែភ្លើង ការចាក់ម្ជុលចូលក្នុងក្រចកនិងការជ្រមុជទឹកគឺជាវិធីសាស្ត្រធ្វើទារុណកម្មដែល ឌុច បានបង្រៀនអ្នកសួរចម្លើយ និងបានរក្សាទុកសៀវភៅកត់ត្រាពីវិធីសាស្ត្រធ្វើទារុណកម្មនេះទៀតផង ។ ក្រោយមកទៀតនៅក្នុងទសវត្សរ៍៩០ ឌុច បានអះអាងថា ខ្លួនបាន "ចាប់ជាតិម្តងទៀត" ហើយបានកាន់សៀវភៅព្រះគម្ពីរតូចមួយក្បាលដែល ឌុច បានកាន់ចូលក្នុងបន្ទប់សវនាការ កាលពីថ្ងៃសុក្រមុននេះ ។

ក្រោមបញ្ជារបស់ ឌុច ប្រជាជនកម្ពុជាសាមញ្ញនិងជនបរទេសដែលបានធ្វើដំណើរតាមកប៉ាល់បានធ្លាក់ក្នុងកណ្តាប់ដៃរបស់ ឌុច ហើយត្រូវបានចោទប្រកាន់ថាបម្រើឲ្យ សេ.អ៊ី.អា កា.ហ្សេ.បេ និងគិញរបស់វៀតណាម ។ ក្មេងតូចៗដែលបាននាំទៅដល់វាលពិឃាតជើងឯកត្រូវបានបោកក្បាលនឹងគល់ឈើលៀនខួរចេញមកក្រៅ ចំណែកឯអ្នកទោសវ័យកណ្តាលវិញ ត្រូវបានបង្ខំឲ្យជីករណ្តៅ ហើយពេជ្ឈឃាតបានវាយក្បាលអ្នកទោសនោះនឹងដងចប ។ ចំណែកជនបរទេសសេសសល់ត្រូវបានដុតសម្លាប់ទាំងរស់ ។

ក្រោយមកទៀតនៅថ្ងៃទី៣ ខែកុម្ភៈជាថ្ងៃបណ្តឹងឧទ្ធរណ៍ ឌុច បានទទួលទោសឲ្យជាប់ពន្ធធនាគារអស់មួយជីវិតហើយក៏ជាលទ្ធផលនៅថ្ងៃចុងសប្តាហ៍នោះ ប្រទេសកម្ពុជាបានអបអរសាទរចំពោះកាលដែល ឌុច នឹងមិនអាចចេញពីគុកទាំងនៅមានជីវិតបានឡើយ ។

ឌុច ធ្វើឲ្យខ្ញុំនឹកឃើញដល់ឧទាហរណ៍សាមញ្ញមួយនៃទង្វើអាក្រក់ ។ ទស្សនៈនៃទង្វើអាក្រក់នេះមានប្រភពដើមចេញពីសៀវភៅរបស់ ហាណា អារ៉ែន ដែលបានបោះពុម្ពក្នុងឆ្នាំ១៩៦៣ ដែលមានចំណងជើងថា "អ៊ិចម៉ែននៅក្នុងទីក្រុងយេរូសាឡឹម" ដែលស្តីពីឧក្រិដ្ឋជនសង្គ្រាមរបស់របបណាហ្ស៊ី ។ និក្ខេបបទរបស់លោកស្រី ហាណា អារ៉ែន គឺជាគោលការណ៍នៃកំហុសក្នុងប្រវត្តិសាស្ត្រជាទូទៅមិនត្រូវបានអនុវត្តដោយពួកជ្រុលនិយមឬពួកវិកលចរិកទេ ប៉ុន្តែដោយមនុស្សធម្មតា ហើយ ឌុច នេះគឺជាមនុស្សធម្មតាយ៉ាងពិតប្រាកដណាស់ ។

បើទោះបីជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបីនាក់កំពុងតែត្រូវបានកាត់ទោសក៏ដោយ វាទំនងជាភាពព្រឺខ្លាចរបស់កម្ពុជាដែលបានកើតមានឡើងចាប់តាំងពីរដ្ឋប្រហារក្នុងខែមីនាឆ្នាំ១៩៧០ ដែលបានទម្លាក់សម្តេច នរោត្តម សីហនុ នោះនឹងមានឱកាសឈានទៅដល់ទីបញ្ចប់ហើយ ។

ខ្មែរក្រហមបានសម្លាប់ជនទាំងឡាយណាដែលនិយាយភាសាបរទេសទាំងដឹងថាខ្មែរក្រហមខ្លួនឯងក៏បានទៅសិក្សានៅទីក្រុងប៉ារីសដែរ ។ បដិវត្តន៍របស់ខ្មែរក្រហមគឺជាការផ្សំនៃគោលនយោបាយដែលថា "មនុស្សបានកើតមកដោយសេរីភាព ប៉ុន្តែមានជាប់ពាក់ព័ន្ធគ្នាជាខ្សែបណ្តាញ" គោលនយោបាយរបស់ម៉ៅ និងបដិវត្តន៍ផ្តាច់ការរបស់ ចាកូប៊ីន ការសម្លាប់រង្គាលប្រជាជនកូឡាក់ (kulak) នៅប្រទេសអ៊ុយក្រែននៃគោលនយោបាយរបស់ស្តាលីននិងការធ្វើទុកបុកម្នេញរបស់ហ៊ីត្លែរលើជនជាតិជ្វីហ្វ និងជនជាតិជីពី

ក្នុងករណីខ្មែរក្រហមវិញ ជនជាតិភាគតិចចាម និងជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាត្រូវបានចាត់ទុកជាមុខសញ្ញាខុសពី "ប្រជាជនក្រុង" ភ្នំពេញដែលត្រូវបានជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នេះគឺជាទង្វើដ៏សាហាវឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រ ។

លោក គង់ ស្រ៊ីម ប្រធានចៅក្រមនៃអង្គជំនុំជម្រះសាលាកំពូល បាននិយាយថា “ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយ កាំង ហ្កេកអ៊ាវ គឺមានភាពសាហាវឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សដែលបានកត់ត្រាទុក” ។ លោកប្រធាន គង់ ស្រ៊ីម បានព្រមានថា ប្រជាជនកម្ពុជាបានប្រឈមមុខនឹងបញ្ហាដែលមិនមានពីមុនមកដើម្បីងើបចេញពីសោកនាដកម្មដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ កាំង ហ្កេកអ៊ាវ ។

នៅពេលដែលខ្ញុំបានមកប្រទេសកម្ពុជាជាលើកដំបូង គឺក្នុងអំឡុងពេលនៃ “ការឈ្លានពាន” របស់អាមេរិកនៅខែឧសភា ឆ្នាំ១៩៧០ ។ កាលនោះខ្ញុំបានធ្វើដំណើរតាមឧទ្ធម្ភាគចក្រដ៏ចាស់មួយរបស់វៀតណាមខាងត្បូងមកកាន់ប្រទេសកម្ពុជា ហើយពេលនោះ ឧទ្ធម្ភាគចក្ររបស់យើងត្រូវបានបាញ់រះ ។ ខ្ញុំបានឃើញទិដ្ឋភាពនៃរណ្តៅធំៗបណ្តាលមកពីការទម្លាក់គ្រាប់បែកដែលបញ្ជាដោយប្រធានាធិបតី រីឆាត នីកស៊ុន និងទីប្រឹក្សាសន្តិសុខជាតិគឺលោក ហែនរី ឃីសីងជឺ កាលពីឆ្នាំ១៩៦៩ ។ អ្នកវិភាគខ្លះបានជឿជាក់ថា តើគ្រាប់បែកជាច្រើនរបស់អាមេរិកដែលបានសម្លាប់ប្រជាជនកម្ពុជារាប់ពាន់នាក់មុនពេលត្រូវបានបញ្ឈប់ដោយសមាជឆ្នាំ១៩៧៣ នោះមានជាប់ពាក់ព័ន្ធយ៉ាងដូចម្តេចខ្លះនឹងភាពសាហាវឃោរឃៅនៃរបបខ្មែរក្រហមដែលប្រជាជនកម្ពុជាចំនួនប្រមាណ១,៧លាននាក់ត្រូវបានសម្លាប់និងស្លាប់ដោយសារការអត់ឃ្លាន ឬការធ្វើការហួសកម្លាំង ។


ឌុច នៅថ្ងៃប្រកាសសាលដីកាលបណ្តឹងឧទ្ធរណ៍ក្នុងករណី០០១ (អ.វ.ត.ក)

ក្នុងថ្ងៃទស្សនៈកិច្ចទីពីររបស់ខ្ញុំនៅតាមតំបន់ជនបទខ្ញុំបានឃើញឧទ្ធម្ភាគចក្ររបស់រុស្ស៊ីហោះកាត់ខេត្តបាត់ដំបង និងបានឃើញគោដ៏ស្គមស្គាំងប្រឹងអូសរទេះតាមផ្លូវដែលរងការទម្លាក់គ្រាប់បែក និងគ្រាប់មីន ។ ក្នុងសភាពបែបនេះវាហាក់បីដូចជា ប្រទេសកម្ពុជាបានដើរត្រឡប់ទៅកាន់សតវត្សរ៍ទី១៨វិញ ។ ទិដ្ឋភាពនេះ គឺហាក់បីដូចជានៅក្នុងមជ្ឈិមសម័យអឺរ៉ុបដូច្នេះដែរ ។ នៅទីក្រុងភ្នំពេញ ទោចក្រយានយន្តខ្មោចខ្មៅជាច្រើនគរលើគ្នាដូចភ្នំរួមទាំងទូទឹកកកចាស់ៗជាច្រើនផ្សេងទៀត ។ ខ្ញុំបានឃើញក្រដាស់ប្រាក់គ្មានតម្លៃនៅរាយពាសពេញបរិវេណខាងក្រៅធនាគារជាតិដែលរងការទម្លាក់គ្រាប់បែក ។ នៅដើមខែកុម្ភៈនេះ អ្នកសារព័ត៌មានរបស់សហរដ្ឋអាមេរិក អ្នកស្រី អេលីហ្សាប៊ែត ប៊េកឃើ ជាអ្នករាយការណ៍បរទេសម្នាក់ដែលបានធ្វើបទសម្ភាសន៍ជាមួយនឹង ប៉ុល ពត ក្នុងអំឡុងរបបខ្មែរក្រហមនាចុងឆ្នាំ១៩៧៨ នោះបាននិយាយក្រោយពីការដាក់ទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិតថា តុលាការកាត់ទោសអំពើសាហាវឃោរឃៅរបស់ខ្មែរក្រហមនៅកម្ពុជាបានចាប់ផ្តើមធ្វើកិច្ចការមួយដែលអ្នកស្រីបានយល់ថាជា “ការបង្កើតកម្ពុជាថ្មី” ។

អ្នកស្រីបាននិយាយទៅកាន់និស្សិតនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រថា ៖ “នៅចំពោះមុខតុលាការ ប្រវត្តិសាស្ត្រហាក់ដូចជាមានការនិយាយច្រើន ប៉ុន្តែនាពេលបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាកំពុងតែស្វែងរកសំឡេងរបស់ខ្លួនដោយយល់ឃើញថាខ្លួនអាចចាប់ផ្តើមនិយាយពីបញ្ហាប្រវត្តិសាស្ត្រនេះបាន ។ ភាពទុក្ខសោក និងជំងឺប៉ះទង្គិចផ្លូវចិត្តនៃរបបខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ហើយប្រជាជនកម្ពុជាបាននាំគ្នានិយាយពីរឿងរ៉ាវរបស់ខ្លួនបានឆ្លងកាត់កាលពីសាមសិបឆ្នាំមុន ។ ដោយសារតែតុលាការ “ឧក្រិដ្ឋកម្មទាំងអស់ត្រូវបានទទួលស្គាល់” ។

អ្នកស្រីបាននិយាយថា ប្រជាជនអាល្លឺម៉ង់និងជប៉ុនបានចំណាយពេលដូចគ្នានឹងប្រជាជនកម្ពុជាដែរដើម្បីប្រឈមមុខនឹងសង្គ្រាមលោកលើកទី២និងភាពព្រឺខ្លាចដោយសារតែសង្គ្រាមនេះ ។ ប៉ុន្តែយើងនឹងរង់ចាំមើល “ការកកើតកម្ពុជាថ្មី” ដោយការគ្រប់គ្រងនយោបាយបច្ចុប្បន្ននេះ យើងនឹងចាំមើលថាតើតុលាការនឹងសម្រេចបានជោគជ័យដែរឬយ៉ាងណា?

រយៈពេលប៉ុន្មានម៉ោងក្រោយពីធ្វើបទសម្ភាសន៍ជាមួយនឹង ប៉ុល ពត នៅឯទីស្នាក់ការរបស់អាណានិគមបារាំងដែលបានលើកឡើងខាងលើ ក្រុមមនុស្សបីនាក់ដែលរួមមានអ្នកសារព័ត៌មានអាមេរិក អែលីហ្សាបេត ប៊ែកឃឺ? រីឆាត ដូម៉ាន់ របស់កាសែត St Louis Post Dispatch និងអ្នកស្រាវជ្រាវជនជាតិអង់គ្លេស ម៉ាលកូម កាល់វែល ដែលជាអ្នកគាំទ្ររបប ប៉ុល ពត បានថយចុះមកត្រឹមគ្នាពីរនាក់ ដោយសារតែ កាល់វែល ត្រូវបានបាញ់សម្លាប់នៅក្នុងបន្ទប់សណ្ឋាគារដែលលោកបានស្នាក់នៅដោយសារតែ កាល់វែល បានបង្ហាញពីភាពជឿងឆ្ងល់មួយចំនួនលើបណ្តាញគ្រប់គ្រងរបស់ខ្មែរក្រហម ក្រោយពីបានឃើញស្ថានភាពជាក់ស្តែងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខណៈពេលនេះ អង្គជំនុំជម្រះក្តីរបស់មេដឹកនាំជាន់ខ្ពស់ដែលគួរឲ្យកត់សម្គាល់ជាងគេគឺបងធំទី២ នួន ជា ដែលមានអាយុ ៨៥ឆ្នាំ ។ ខុសពី ឌុច ដែលបានបង្ហាញវិប្បដិសារី ខ្លះសម្រាប់ឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងរបស់ខ្លួន អតីតមេដឹកនាំខ្មែរក្រហមទាំងនេះមិនបានបង្ហាញពីការទទួលស្គាល់កំហុសរបស់ខ្លួនទាល់តែសោះហើយទំនងជាមានបំណងដាក់កំហុសសម្រាប់ការសម្លាប់ទ្រង់ទ្រាយធំនេះលើកងទ័ពវៀតណាមដែលបានបញ្ចប់របប ប៉ុល ពត ហើយក្នុងរយៈពេលខ្លីប៉ុណ្ណោះកងទ័ពវៀតណាម បានជួយសង្គ្រោះប្រជាជនកម្ពុជាដែលអត់ឃ្លាន និងមានជំងឺ ។

មេធាវីការពារក្តីរបស់ នួន ជា បានដកស្រង់ខ្លឹមសារអត្ថបទដែលមានការចោទប្រកាន់ថា ប្រធានរដ្ឋសភាជាតិ ហេង សំរិន និងប្រធានព្រឹទ្ធសភា ជា ស៊ីម ជាមេដឹកនាំបក្សមានអំណាចខ្ពស់ក្នុងប្រទេសនាពេលបច្ចុប្បន្ននេះបានប្រព្រឹត្តឧក្រិដ្ឋកម្មជាទម្ងន់នៅក្នុងរបបខ្មែរក្រហម ។ មេធាវី ចាស្ទី ប៉ាវ បានដក់ស្រង់យកការចោទប្រកាន់ចេញពីអត្ថបទឆ្នាំ២០០៥ ដែលសរសេរដោយអ្នកស្រាវជ្រាវអាមេរិក ស្ទីវ ហេឌើ ដែលជាអ្នកប្រវត្តិសាស្ត្រខ្មែរក្រហមដ៏ល្បីល្បាញម្នាក់ ។ លោកបាននិយាយដោយផ្អែកលើរបាយការណ៍ឆ្នាំ២០០៥របស់លោក ហេឌើ ថា "ភ័ស្តុតាងផ្សេងៗជាច្រើនមានជាប់ពាក់ព័ន្ធនឹង ហេង សំរិន ពីឧក្រិដ្ឋកម្មសង្គ្រាមជាពិសេសគឺការសម្លាប់ប្រជាជនស៊ីវិល វៀតណាមដែលប្រព្រឹត្តឡើងដោយកងទ័ពខ្មែរក្រហមក្រោយការគ្រប់គ្រងរបស់ ហេង សំរិន នៅក្នុងអំឡុងការវាតត្បាតតាមព្រំប្រទល់នៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៧" ។

បន្ទាប់មកទៀត លោកបាននិយាយម្តងហើយម្តងទៀតពីការចោទប្រកាន់ដែលមាននៅក្នុងអត្ថបទរបស់លោក ហេឌើ ថា ហេង សំរិន មានការទទួលខុសត្រូវសម្រាប់ការសម្លាប់ជនភៀសខ្លួន និងប្រជាជនផ្សេងទៀតដែលត្រូវបានរាយការណ៍នៅក្នុងបទសម្ភាសរបស់លោក ហេឌើ ជាមួយនឹងប្រជាជនក្នុងតំបន់នោះ.. ។ នួន ជា ដែលបានបង្ហាញឲ្យឃើញពីភាពស្ទាត់ជំនាញនៅចំពោះមុខតុលាការ បានលើកឡើងព្រឹត្តិការណ៍មិនទំនងខ្លះៗដោយរៀបរាប់ពីការជួបពិភាក្សាគ្នាជាមួយនឹង ហេង សំរិន និង ជា ស៊ីម ហើយបាននិយាយរៀបរាប់ពីរឿងរ៉ាវរបស់អ្នកទាំងពីរនេះដូចជាតួសម្តែង ។ នួន ជា បាននិយាយថា "ហេង សំរិន គឺជាកសិករក្រីក្រម្នាក់នាពេលនោះ ។ សូម្បីតែគោមួយក្បាលក៏ ហេង សំរិន គ្មានដើម្បីភ្ជួររាស់ស្រែឡើយ ។ ហេង សំរិន មានតែខោខ្លីមួយប៉ុណ្ណោះ" ។ នួន ជា បានបងចាំថា ជា ស៊ីម គឺជា "កសិករថ្នាក់កណ្តាលដែលត្រូវការខ្ចីលុយរហូត" ។ ឥឡូវនេះអ្នកទាំងពីរនេះបានជួយដឹកនាំប្រទេសកម្ពុជាជាមួយនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ការចោទប្រកាន់ដែលប៉ះពាល់ដល់មន្ត្រីជាន់ខ្ពស់នៃរបស់គ្រប់គ្រងរបស់សម្តេច ហ៊ុន សែន ។ សម្តេច ហ៊ុន សែន អាចនឹងមានការខឹងសម្បាខ្លាំងចំពោះការវាយប្រហារនេះមកលើដៃគូរបស់ខ្លួនហើយអាចនឹងធ្វើការមាក់ងាយដល់មេធាវីការពារក្តីរបស់ នួន ជា ដែលបានប្រមាថលើតម្លៃរបស់ខ្លួន ។

បើទោះបីជាតុលាការបានចំណាយប្រាក់លើសពី១៥០លានដុល្លារក៏ដោយ ក៏បុគ្គលិកកម្ពុជាប្រមាណ៣០០នាក់មិនទាន់បានទទួលប្រាក់បៀវត្សរ៍របស់ខ្លួនចាប់តាំងពីខែតុលាមកម្ល៉េះ ទោះបីជាតុលាការទទួលបានមូលនិធិបន្ថែមពីប្រទេសអាល្លឺម៉ង់សម្រាប់ការទូទាត់ប្រាក់បៀវត្សរ៍មួយផ្នែកក្នុងសប្តាហ៍នេះក្តី ។

ចំណែកឯចៅក្រមជនជាតិស្វីសដែលតែងតាំងដោយអង្គការសហប្រជាជាតិ លោក ឡូរ៉ង់ កាស្ពឺ អាន់សឺម៉េត ត្រូវបានរារាំងមិនឲ្យអនុវត្តការងារជាផ្លូវការដោយចោទប្រកាន់ថាជ្រៀតជ្រែកក្នុងសំណុំរឿង០០៣និង០០៤ដែលរដ្ឋាភិបាលមិនចង់ឲ្យដំណើរការដោយសារតែខ្លាចថាមានការចោទប្រកាន់បន្ថែមទៀតមកលើសមាជិករដ្ឋាភិបាល ។

ភាពជាប់គាំងនៃការតែងតាំងលោក កាស្ពឺ អានសឺម៉េត បានជំរុញឲ្យមានការរំពឹងទុកថា អង្គការសហប្រជាជាតិអាចនឹងដកខ្លួនចេញពីអង្គជំនុំជម្រះនេះមុនពេលអង្គជំនុំជម្រះក្តីរបស់មេដឹកនាំជាន់ខ្ពស់ត្រូវបានបញ្ចប់ជាស្ថាពរ ។ សហរដ្ឋអាមេរិកមានបំណងចង់ឲ្យលោកចៅក្រមជនជាតិស៊ុីសរូបនេះបន្តការកាត់ទោសបន្ថែមទៀតដែលរួមមានមេបញ្ជាការជើងទឹករបស់ខ្មែរក្រហម មាស មុត និងអគ្គកងពលជើងអាកាស ស៊ូ ម៉េត ដែលត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវចំពោះការស្លាប់របស់ពលករនិងទាសកររាប់ពាន់នាក់ក្នុងអំឡុងរបបគ្រប់គ្រងរបស់ខ្មែរក្រហមជាពិសេសគឺការប្រើពលករសាងសង់វាលយន្តហោះសម្ងាត់ដ៏ធំមួយនៅខេត្តកំពង់ឆ្នាំងដែលចិនបានចាប់អារម្មណ៍លើការសាងសង់នោះ(សូមមើលអត្ថបទនៅក្នុងកាសែត Asia Sentinel) ។

លោក កាស្ពឺ អានសឺម៉េត មិនអាចទទួលតំណែងជាផ្លូវការនៅក្នុងតុលាការបានទេ បើទោះបីជាលោកបានទៅចូលរួមតាមដានដំណើរការរបស់តុលាការជារៀងរាល់ថ្ងៃក៏ដោយ ។ នាពេលបច្ចុប្បន្ននេះ លោកបាននិយាយទៅកាន់អ្នកសារព័ត៌មានថា ពេលវេលារបស់លោកនៅឯតុលាការគឺហាក់បីដូចជា «ការដើរចូលក្នុងតុលាការទាំងខ្នោះដៃ» ។ យ៉ាងណាមិញ ក្នុងការលើកឡើងពីបញ្ហារបស់តុលាការនៅលើគេហទំព័រ Twitter លោកមិនបានពិភាក្សាពីបញ្ហាកាត់ទោសបន្ថែមទៀតឡើយ ។ ទាក់ទងនឹងបញ្ហារបស់លោកមេធាវីវិញ សម្តេច ហ៊ុន សែន បានទាមទារមិនឲ្យតុលាការធ្វើការកាត់ទោសថ្មីទៀតឡើយដោយព្រមានថានឹងអាចមានសង្គ្រាមស៊ីវិលម្តងទៀត ប្រសិនបើមានការចេញដីកាចោទប្រកាន់បន្ថែមទៀត ។ សង្គ្រាមអាចនឹងផ្ទុះឡើងម្តងទៀតដោយបក្សសម្ព័ន្ធរបស់អតីតខ្មែរក្រហម ។

ប៉ុន្តែអតីតខ្មែរក្រហមជាច្រើននាក់បានចូលបម្រើក្នុងកងទ័ពកម្ពុជាដោយសេចក្តីអំពាវនាវរបស់សម្តេច ហ៊ុន សែន ។ ដូច្នេះហើយបានជាមានឧត្តមសេនីយរហូតដល់ទៅ២,០០០នាក់ក្នុងជួរកងទ័ពសព្វថ្ងៃនេះ ។ ចំណែកឯអតីតមេដឹកនាំខ្មែរក្រហមផ្សេងទៀតបានងាកមកធ្វើជំនួញអាជីវកម្មលក់ឈើ និងព្រៃឈើ ត្បូងទទឹមនិងត្បូងកណ្តៀងដែលជិតបាត់បង់ទៅឲ្យប្រទេសថៃ ។ ដូច្នេះវាមិនទំនងទាល់តែសោះដែលថាអតីតមេដឹកនាំខ្មែរក្រហមទាំងនេះមានបំណងចង់ធ្វើសង្គ្រាមម្តងទៀត ។ ភាគច្រើន អ្នកទាំងនោះទំនងជាចាំមើលកម្មវិធីបាល់ទាត់តាមទូរទស្សន៍វិញប្រសើរជាង ។ បុគ្គលិករបស់តុលាការម្នាក់បាននិយាយដោយមិនឲ្យបញ្ចេញឈ្មោះថា «តុលាការកំពុងតែប្រឈមមុខនឹងបញ្ហាច្របូកច្របល់មួយដ៏ធំ ។ វាពិបាកនឹងរំពឹងទុកថាតើភាពជាប់គាំងនេះនឹងត្រូវដោះស្រាយបានដោយរបៀបណា» ។

ដូច្នេះ «ការបង្កើតកម្ពុជាថ្មី» ដែលអ្នកស្រី អេលីហ្សាប៊ែត ប៊េកឃើ បានដាក់ឈ្មោះឲ្យនេះអាចនឹងនៅវែងឆ្ងាយទៀតពីព្រោះការបោះឆ្នោតដោយសេរីពិតប្រាកដមិនទាន់នឹងកើតមានឡើងផង ហើយការកាត់ទោសជនដៃដល់ខ្មែរក្រហមបន្តបន្ទាប់ទៀតនេះកំពុងតែជួបបញ្ហានៅឡើយ ។ សម្រាប់អ្នកសារព័ត៌មានវិញ រឿងរ៉ាវរបស់ ឌុច គឺជារឿងរ៉ាវដែលមានរយៈពេលសាមសិបបីឆ្នាំហើយក៏បានបញ្ចប់សព្វគ្រប់ដែរ ។

នាពេលបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាកំពុងតែសប្បាយរីករាយដែលបានឃើញសមមិត្ត ឌុច ដ៏សាហាវម្នាក់នេះត្រូវបានជាប់ពន្ធនាគារអស់មួយជីវិត ។ ខ្លឹមសាររបស់អត្ថបទនេះភាគច្រើនត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែតហុងកុងតាមប្រព័ន្ធអ៊ិនធើណែតរបស់ក្រុមហ៊ុន Asia Sentinel ។

**ចេម ត្រីងហ្គល**


ការ សាវុត្ថ (ឆ្វេង) និង កង ឬទ្ធារី សហមេធាវីរបស់ ឌុច (រូបថត៖ អ.វ.ត.ក)

# អ្វីដែលខ្ញុំចង់បានគឺយុត្តិធម៌សម្រាប់កូនខ្ញុំ



ម៉ាន សូត

ខ្ញុំឈ្មោះ ម៉ាន សូត អាយុ៧៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងស្រុកបារាយ ខេត្តកំពង់ធំ ។ ខ្ញុំជាកសិករម្នាក់ ។ កាលពីខែមីនា ឆ្នាំ២០១១ ឌុច បាននិយាយថា «មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតគឺអ្នកផ្សេង មិនមែនខ្ញុំទេ ។ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាគឺបុគ្គលទាំងឡាយណាដែលមានសិទ្ធិសម្រេចកម្មចខ្លាំង ហើយនោះក៏គេ មិនមែនខ្ញុំទេ ។ ខ្ញុំដែលរស់រានមានជីវិតរហូតថ្ងៃនេះគឺដោយសារតែខ្ញុំគោរពគោលការណ៍នេះយ៉ាងម៉ឺងម៉ាត់តាំងពីថ្ងៃ២០ ខែកក្កដា ឆ្នាំ១៩៧១មក ។ អ្វីដែលបក្សប្រគល់ឲ្យត្រូវតែធ្វើ មិនធ្វើមិនបានទេ ។ អ្វីដែលបានកើតឡើងគឺជាបទឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបងទី១ ប៉ុល ពត ជាលេខា បងទី២ នួន ជា ជាអនុលេខា និងបងទី៣ អ៊ុង ជឿន ហៅ ម៉ុក ជាអនុលេខា» ។ សម្តីរបស់ ឌុច ធ្វើឲ្យខ្ញុំឈឺក្បាលយ៉ាងខ្លាំង ។ ខ្ញុំមិនអាចទទួលយកបានទេ ចំពោះការទទួចសុំថាខ្លួនគ្មានកំហុសនោះ ។ ការលើកឡើងរបស់ ឌុច គឺដូចជាចង់បញ្ជាក់ថាខ្លួនគ្រាន់តែធ្វើតាមបញ្ជាតែប៉ុណ្ណោះ ។ ឌុច ចេះតែនិយាយអ្វីក៏ដោយឲ្យខ្លួនអាចរួចផុតពីការចោទប្រកាន់ ។ ចំពោះទស្សនរបស់ខ្ញុំ ឌុច គឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់និងដោយប្រយោលចំពោះការស្លាប់របស់ប្រជាជនជាច្រើននាក់នៅក្នុងប្រទេសកម្ពុជា ។ ឌុច គឺជាប្រធានមន្ទីរស-២១(គុកទួលស្លែង) ហើយនៅក្នុងចំណោមជនរងគ្រោះដែលស្លាប់ជាង១៤,០០០នាក់នៅទីនោះគឺមានម្នាក់ជាកូនរបស់ខ្ញុំ ។ កូនខ្ញុំខិតខំប្រឹងប្រែងបូជាលះបង់ដើម្បីការពារប្រទេសជាតិតែហេតុអ្វីបានជាកូនខ្ញុំត្រូវបានចាប់ខ្លួននិងសម្លាប់ដោយអយុត្តិធម៌បែបនេះ? តើនរណាជាអ្នកទទួលខុសត្រូវ? ប៉ុល ពត? តាម៉ុក? ឌុច?

កូនច្បងរបស់ខ្ញុំឈ្មោះ ម៉ាន ស៊ឹម ត្រូវបានសម្លាប់នៅទួលស្លែងនៅក្នុងឆ្នាំ១៩៧៦ ។ កូន ស៊ឹម គឺជាកូនកត្តញ្ញូម្នាក់និងចេះជួយយកអាសារគេណាស់ ។ ពេលអាយុបាន១៥ឆ្នាំ កូន ស៊ឹម ត្រូវបានជ្រើសតាំងឲ្យចូលរួមក្នុងក្រុមសំដែងសិល្បៈក្នុងភូមិអស់រយៈពេលមួយឆ្នាំ ។ បន្ទាប់មក ប្រហែលជាក្នុងឆ្នាំ១៩៧៣ កូនស៊ឹម ត្រូវបានមេឃុំឈ្មោះ រឿង និង ហំ ណែនាំឲ្យចូលធ្វើយោធាខ្មែរក្រហម ។ ក្នុងនាមជាឪពុកម្តាយគេ យើងពិតជាមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការសម្រេចចិត្តដ៏គ្រោះថ្នាក់នេះ ប៉ុន្តែយើងមិនអាចធ្វើអ្វីបានទាំងអស់ក្រៅពីខិតខំធ្វើការយ៉ាងលំបាកវេទនាដើម្បីផ្គត់ផ្គង់ខ្លួនឯង ។ ពេលនោះទៀត គឺយើងកំពុងត្រូវបានបង្ខំឲ្យរត់គេចពីការទម្លាក់គ្រាប់បែកក្នុងភូមិ ។

កូន ស៊ឹម បានមកលេងផ្ទះប៉ុន្មានដងដែរ ហើយបានប្រាប់ថា វាមិនអាចអត់ទ្រាំទៅនឹងការស៊ីអត់ស៊ីឃ្លាន និងការរស់នៅយ៉ាងវេទនានៅសមរភូមិបានទេ ។ ប្រពន្ធរបស់ខ្ញុំពេលឮដំណឹងបែបនេះគឺគិតតែយំរហូត ។ តែទោះបីជាមិនសប្បាយចិត្តយ៉ាងនេះក្តី កូន ស៊ឹម នៅតែបន្តធ្វើទ័ពហ្នឹងរហូតនៅខេត្តកំពង់ធំ ។ ប៉ុន្មានថ្ងៃ បន្ទាប់ពីថ្ងៃរំដោះទីក្រុងភ្នំពេញនៅខែមេសាឆ្នាំ១៩៧៥កូន ស៊ឹម បានមកលេងផ្ទះម្តងទៀត ។ កាលនោះ ខ្ញុំគ្រុនក្តៅខ្លាំងហើយកូន ស៊ឹម ហ្នឹងបានយកថ្នាំមួយកញ្ចប់ធំមកជាមួយ ។ កូន ស៊ឹម បានចាក់ថ្នាំឲ្យខ្ញុំមួយម្ជុលហើយខ្ញុំក៏ជាសះស្បើយ ។ ពួកកម្មាភិបាលខ្មែរក្រហមផ្សេងទៀតតែងតែហៅកូន ស៊ឹម ថា ពេទ្យ រៀម ព្រោះកូនខ្ញុំចេះព្យាបាលជំងឺដោយប្រើថ្នាំ ។ ពេលខ្លះអ្នកភូមិៗតែងតែហៅកូនខ្ញុំ

ហ្នឹងឲ្យជួយមើលជំងឺដែរ ។ នៅផ្ទះបានតែប៉ុន្មានថ្ងៃ កូន ស៊ីម ត្រូវដល់ពេលត្រឡប់ទៅភ្នំពេញវិញ ។ កូន ស៊ីម ធ្វើទ័ពនៅកងពល ៣១០ ។ ប្រហែលប៉ុន្មានខែក្រោយមក កូន ស៊ីម បានសរសេរសំបុត្រផ្ដាំផ្ញើឲ្យខ្ញុំទៅលេងនៅភ្នំពេញ ។ បន្ទាប់មកខ្ញុំបានទៅស្នើសុំការអនុញ្ញាតពីប្រធានកងរបស់ខ្ញុំដើម្បីទៅភ្នំពេញ ។ ប្រធានកងរបស់ខ្ញុំបានចេញលិខិតធ្វើដំណើរឲ្យខ្ញុំហើយខ្ញុំក៏ជិះកង់ទៅជាមួយក្មួយរបស់ខ្ញុំឈ្មោះ ហឹន ដែលធ្វើទ័ពដែរ ។ យើងធ្វើដំណើរអស់ជិតបីថ្ងៃទើបទៅដល់ទីក្រុងភ្នំពេញ ។ នៅតាមផ្លូវ ខ្ញុំឃើញមានយោធាតែមិនសូវមានអ្នកភូមិដើរហើរទេ ។ ខ្ញុំជិះស្រឡាងនៅព្រែកក្ដាម ។ ពេលនោះគេអត់មានគិតលុយកាក់អីទេ ព្រោះជំនាន់នោះមិនមានការចាយវាយរូបិយវត្ថុអ្វីនោះទេ ។ ខ្ញុំស្នាក់នៅប្រាំងចំរះមួយយប់ទៀត មុនពេលធ្វើដំណើរមកកាន់កន្លែងដែលកូនខ្ញុំនៅ ។ ពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះភាពស្ងាត់ជ្រងំនៅទីក្រុងភ្នំពេញ ។ ផ្ទះស្ទើរតែទាំងអស់គឺទទេស្អាតគ្មានមនុស្សរស់នៅទេ ។ មានមនុស្សដើរតាមផ្លូវដែរតែតិចតួចណាស់ ។ ខ្ញុំឃើញមានតែឡានដឹកទ័ពជាច្រើន ។ ទីក្រុងភ្នំពេញមើលទៅដូចជាកំពុងលង់លក់អីចឹង ។ នៅជិតគល់ស្ពានជ្រោយចង្វារដែលបាក់នោះមានស្មៅដុះឡើងពេញ ។ បន្ទាប់ពីស្នាក់នៅជាមួយកូន ស៊ីម បានមួយថ្ងៃ ខ្ញុំក៏ធ្វើដំណើរត្រឡប់មកភូមិវិញ ។ ពេលរៀបចេញមកកូនខ្ញុំបានឲ្យឆ្នាំងដាំបាយធំមួយទុកឲ្យខ្ញុំប្រើសព្វថ្ងៃនេះ (ខ្ញុំក៏នៅប្រើឆ្នាំងហ្នឹងដែរ) ។ នៅក្នុងភូមិ ខ្ញុំត្រូវបានចាត់ចែងឲ្យធ្វើការខាងក្រុមភ្ជួររាស់និងលើកទំនប់ ។ ប្រពន្ធខ្ញុំវិញ នៅតែធ្វើនៅកងស្ទូងស្រូវដដែរ ។ ប្ដីប្រពន្ធយើងធ្វើការបែកគ្នា ហើយមិនមានពេលបានជួបគ្នាញឹកញាប់ទេ ។ ពេលនោះខ្ញុំស្គមស្គាំងណាស់ដោយសារតែអាហារដែលខ្ញុំបានហូបនោះគឺមានតែទឹកបបរតែប៉ុណ្ណោះ ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ក្មួយខ្ញុំឈ្មោះ រឿន បានមកប្រាប់ខ្ញុំថា កូនស៊ីម ត្រូវបានចាប់ខ្លួនដោយសារតែរត់គេចពីកន្លែងធ្វើការ ។ មុនពេលកើតហេតុនេះ រឿន និយាយថា កូន ស៊ីម ត្រូវបានគេផ្លាស់ពីកងពល៣១០ឲ្យទៅធ្វើស្រែនៅទំនប់កប់ស្រូវ ។ កូន ស៊ីម និងគ្នីគ្នាពីរនាក់ទៀតបានគេចមកលេងគ្រួសារនៅខេត្តកំពង់ធំ ។ ប៉ុន្តែ នៅពេលដែលមកដល់តាំងគោកអ្នកទាំងបីនាក់ត្រូវបានកម្មាភិបាលឃាត់ឲ្យហូបបាយនៅទីនោះ ។ មិនយូរប៉ុន្មានគេក៏ដកហូតកាំភ្លើងពីអ្នកទាំងបី ហើយត្រូវបានកម្មាភិបាលនៅទីនោះបង្ខំឲ្យនៅជួយកិនស្រូវ ។ ពីរថ្ងៃក្រោយមក មានឡានមួយមកដឹកកូន ស៊ីម ត្រឡប់ទៅភ្នំពេញវិញ ។ រឿន និយាយថា កូន ស៊ីម ហ្នឹងដឹងខ្លួនថានឹងមិនមានវាសនារស់មកវិញទេ ដូចនេះកូន ស៊ីម ក៏បានហុចនាឡិកាដៃនិងថ្នាំមួយចំនួនដើម្បីទុកឲ្យគេផ្ញើមកឲ្យខ្ញុំ ។ ប៉ុន្តែពេលនោះគ្មានរបស់អ្វីផ្ញើមកឲ្យខ្ញុំទេ ក្រោយពីដំណឹងចាប់ខ្លួនរបស់កូនខ្ញុំ ។ ប៉ុន្មានអាទិត្យក្រោយមក ខ្ញុំក៏បានស្នើសុំការអនុញ្ញាតពីប្រធានកងដើម្បីទៅមើលកូននៅភ្នំពេញ ។ តែប្រធានកងខ្ញុំក៏ទៅប្រាប់មេឃុំឈ្មោះ ចាន់ ហើយ ចាន់ ក៏មកជួបខ្ញុំ ហើយនិយាយថា “កុំទៅរវល់នឹងរឿងគេ គិតតែពីខ្លួនឯងទៅ” ។ ពាក្យសម្ដីដូច្នេះធ្វើឲ្យខ្ញុំដឹងខ្លួនថាខ្ញុំពិតជាមិនអាចទៅលេងកូនបានទេ ហើយច្បាស់ណាស់ថាមានរឿងអ្វីអាក្រក់កើតឡើងចំពោះកូនខ្ញុំហើយ ។ ទោះបីជាខ្ញុំមានអារម្មណ៍ទុក្ខព្រួយយ៉ាងណា ក៏ខ្ញុំមិនហ៊ានទៅសួរនាំម្ដងទៀតដែរ មានតែខិតខំធ្វើពលកម្មតែប៉ុណ្ណោះ ។ នៅពេលដែលប្រពន្ធរបស់ខ្ញុំបានឮដំណឹងនេះ គាត់ក៏ចាប់ផ្ដើមព្រួយរហូតដល់ឈឺ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងបញ្ចេញអារម្មណ៍អាណិតអាសូរចំពោះការបាត់បង់នរណាម្នាក់នោះទេ ទោះបីជាកូនរបស់យើងក្ដី ។ បើមិនអីចឹងទេ យើងក៏ត្រូវទទួលជោគវាសនាដូចគ្នាអីចឹងដែរ ។ ទោះជាយ៉ាងនេះក្ដី ប្រពន្ធខ្ញុំនៅតែលួចយំរហូត ។ កម្មាភិបាលខ្មែរក្រហមធ្វើបាបប្រជាជនដូចសត្វធាតុអីចឹង ។



ម៉ាន សូត នៅសាលាក្ដីខ្មែរក្រហម

ពេលនោះប្រពន្ធខ្ញុំ កំពុងពរពោះ៨ខែហើយ តែត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំងនៅវាលស្រែដោយគ្មានអាហារហូបចុកគ្រប់គ្រាន់ ។

តាំងពីពេលនោះមក ខ្ញុំមិនដែលបានឮដំណឹងអ្វីពីកូន ស៊ីម ម្តងទៀតនោះទេ ។ ទោះជាយ៉ាងនេះក្តី ខ្ញុំនៅតែមានចិត្តចង់ទៅស្វែងរកកូន ស៊ីម ទៀត ។ នៅដើមទសវត្សរ៍៨០ ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅ ខ្ញុំបានឮដំណឹងពីមិត្តភក្តិរបស់ ហឹន ថាកូន ស៊ីម របស់ខ្ញុំដែលគេតែងតែហៅថា ពេទ្យ រៀម នោះត្រូវបានចាប់ដាក់គុកតាំងពីពាក់កណ្តាលឆ្នាំ១៩៧៦ ពេលដែលគេចាប់ខ្លួនដំបូងមកម៉្លេះ ។ ចាប់ពីពេលនោះមក ខ្ញុំលែងមានសង្ឃឹមថាកូន ស៊ីម នៅរស់ទៀតហើយ ។ ខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េចទេក្រៅពីនៅស្ងៀមហើយព្យាយាមរស់តស៊ូក្នុងជីវិតជាមួយនឹងការរង់ចាំដ៏គួរឲ្យឈឺចាប់ទាំងអស់នេះ ។ ចំណែកប្រពន្ធខ្ញុំវិញ សុខភាពក៏ចាប់ផ្តើមធ្លាក់ចុះទន់ខ្សោយពីពេលនោះមក ។

នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅដល់ភូមិរបស់ខ្ញុំហើយបានបង្ហាញប្រពន្ធខ្ញុំនូវក្រដាសប្រវត្តិរូបអ្នកទោសមួយសន្លឹកដែលជារបស់កូនខ្ញុំ ។ ក្នុងក្រដាសថតចម្លងនោះមានព័ត៌មានផ្ទាល់ខ្លួននិងរូបថតរបស់កូនខ្ញុំដែលបញ្ជាក់យ៉ាងច្បាស់ថា នេះហើយជាកូនរបស់ខ្ញុំ ។ ប្រពន្ធខ្ញុំឃើញបែបនេះគិតតែពីយំយ៉ាងខ្លាំង ។ អស់ពេលជាងម្ភៃឆ្នាំហើយ ទើបយើងបានទទួលដំណឹងយ៉ាងច្បាស់ប្រាកដបែបនេះថា កូនខ្ញុំ ម៉ាន ស៊ីម ត្រូវបានយកទៅសម្លាប់នៅគុកទួលស្លែង ។ ខ្ញុំនិយាយមិនចេញទេ ។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៨ ខ្ញុំបានដាក់ពាក្យបណ្តឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការប្រកាសសាលក្រមនៅថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០នោះគឺជាថ្ងៃដែលមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំ ។ ខ្ញុំត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីជាផ្លូវការនៅចំពោះមុខតុលាការ ហើយ ឌុច ក៏បានកាត់ទោសឲ្យជាប់គុក៣៥ឆ្នាំដែរ ។ ប៉ុន្តែ ឌុច នៅតែបដិសេធចំពោះការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជាប្រធានមន្ទីរស-២១ទៀត ។ នៅក្នុងសវនាការតុលាការកំពូល ឌុច និងមេធាវីការពារក្តីបានលើកឡើងថា ឌុច គឺ គ្មានជម្រើសនោះទេ ក្រៅពីធ្វើតាមការបញ្ជាគ្រប់ពេលវេលា ។ ឌុច ក៏បានអះអាងថា ខ្លួនក៏មិនមែនជាអ្នកដឹកនាំខ្ពស់បំផុតដែរ ដែលដូចនេះហើយមិនគួរត្រូវបានយកមកកាត់ទោសនោះទេ ។ ខ្ញុំពិតជាតូចចិត្តណាស់នៅពេលស្តាប់ឮសម្តីបែបនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ កូនខ្ញុំត្រូវបានយកទៅសម្លាប់បាត់ទៅហើយ គ្មានមធ្យោបាយណាធ្វើឲ្យកូនខ្ញុំរស់ឡើងវិញបាននោះទេ ។ ខ្ញុំក៏ដឹងដែរថា វាមិនអាចទៅរួចទេក្នុងការទទួលបានយុត្តិធម៌ពេញលេញមួយ ។ ប៉ុន្តែ យ៉ាងហោចណាស់ តាមរយៈតុលាការនេះ និងតាមផ្លូវច្បាប់បែបនេះអាចធ្វើឲ្យខ្ញុំមានអារម្មណ៍ស្ងប់ចិត្តបាន ។ រីឯផ្ទាល់ខ្លួនខ្ញុំវិញ បន្ទាប់ពីដឹងឮរឿងរ៉ាវនៃការស្លាប់របស់កូនខ្ញុំមក ខ្ញុំតែងតែចង់ធ្វើបុណ្យធ្វើទានឧទ្ទិសកុសលឲ្យកូនដើម្បីឲ្យកូនបានទៅកាន់សុគតិភពនិងបានចាប់កំណើតថ្មី ។ ប៉ុន្តែ ដោយសារជីវភាពរស់នៅរបស់យើងជួបការលំបាក បំណងប្រាថ្នានេះមិនបានសម្រេចតាមចិត្តនោះទេរហូតដល់ខែកុម្ភៈឆ្នាំ២០១១ ទើបយើងមានថវិកាបន្តិចបន្តួចនាំគ្នាធ្វើបុណ្យឲ្យកូន ។ ខ្ញុំបានខិតខំសន្សំលុយកាក់ទាំងនេះអស់ជិតដប់ឆ្នាំហើយ ដោយបានលក់គោខ្លះទៀតដើម្បីយកលុយមកធ្វើបុណ្យ ។ ពិធីបុណ្យនេះ បានធ្វើឲ្យខ្ញុំមានអារម្មណ៍ជ្រះថ្លា ស្ងប់ចិត្ត សប្បាយរីករាយ និងមានក្តីសង្ឃឹមឡើង វិញ ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ គឺជាពេលវេលាដ៏សំខាន់មួយទៀតនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នេះរបស់ខ្ញុំ ។ នោះជាពេលដែលខ្ញុំបានរកឃើញរូបថតកូនរបស់ខ្ញុំនៅក្នុងបណ្ណសាររបស់សារៈមន្ទីរទួលស្លែង ។ បន្ទាប់ពីទទួលដំណឹងថាកូនខ្ញុំស្លាប់នៅទួលស្លែង ខ្ញុំបានមកទស្សនាសារៈមន្ទីរនេះជាច្រើនលើកច្រើនសារ តាមដែលអាចធ្វើទៅបានដោយមានបំណងតែមួយគត់គឺស្វែងរករូបថតកូន ។ ឥឡូវខ្ញុំបានសម្រេចបំណងនេះហើយ ហើយវាធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្បើយយ៉ាងខ្លាំង ។ រូបថតរបស់កូន ស៊ីម នៅតែឆ្លុះបញ្ចាំងពីការចងចាំមួយដ៏ល្អមួយរបស់រឿងរ៉ាវគ្រួសារខ្ញុំ ទោះបីជាការចងចាំនោះមានការឈឺចាប់យ៉ាងណាក្តី ។ យ៉ាងហោចណាស់ ការចូលរួមរបស់ខ្ញុំនៅក្នុងដំណើរការរបស់តុលាការនេះបានធ្វើឲ្យខ្ញុំអាចក្រោកឈរឡើងប្រឈមមុខដោយផ្ទាល់ទៅនឹងជំពូកដ៏ខ្មៅងងឹតមួយនៅក្នុងប្រវត្តិសាស្ត្រគ្រួសារខ្ញុំ ។ អ្វីដែលខ្ញុំចង់បានពីតុលាការគឺមានតែយុត្តិធម៌តែប៉ុណ្ណោះ ។

**ម៉ាន សូត**

# ខ្ញុំនៅតែចងចាំបងប្រុស សៀង គីមឡេង

ក្នុងឆ្នាំ១៩៧២ ខ្មែរក្រហមបានចូលមកកាន់កាប់ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ និងបានឃោសនាប្រមូលអ្នកភូមិដោយបំភ័យឲ្យចូលរួមនឹងចលនាបដិវត្តន៍ ។ នៅពេលនោះ ដោយសារតែបងប្រុសរបស់ខ្ញុំឈ្មោះ គីមឡេង មិនចង់ឲ្យអ្នកភូមិថាជាមនុស្សកំសាក គាត់ក៏បានចុះចូលធ្វើជាយោធាបដិវត្តន៍ខ្មែរក្រហម ។ គាត់ត្រូវបានអប់រំបំពាក់បំប៉នដោយមេឃុំលាយបូរឈ្មោះ ញឿន ។

ក្រោយពេលចូលបដិវត្តន៍ បងប្រុសរបស់ខ្ញុំមាននាទីធ្វើស្រែចម្ការនិងយាមក្នុងឃុំជាមួយយុវជនផ្សេងទៀត ។ គាត់តែងតែមកសួរសុខទុក្ខក្រុមគ្រួសារជារឿយ ប៉ុន្តែក្រោយមកទៀត គាត់ត្រូវបានខ្មែរក្រហមប្តូរឲ្យទៅរស់នៅកន្លែងផ្សេងទៀត ។ មានម្តងនោះពេលមកលេងផ្ទះ គាត់បាននិយាយថា គាត់នឹងត្រូវបញ្ជូនឲ្យទៅធ្វើការនៅកន្លែងឆ្ងាយមួយ ហើយគាត់ប្រហែលជាមិនមានឱកាសមកលេងផ្ទះទៀតនោះទេ ។ ពេលនោះខ្ញុំមិនចង់ឲ្យគាត់ចាកឆ្ងាយពីគ្រួសារទេ ប៉ុន្តែគាត់មិនអាចធ្វើបានព្រោះប្រសិនបើគាត់ល្មើសនឹងបញ្ជាខ្មែរក្រហម គាត់នឹងមានគ្រោះថ្នាក់ធំ ។ ពួកយើងគឺជាអ្នកដែលកើតក្នុងត្រកូលអ្នកក្រីក្រ ហើយខ្ញុំនៅចាំបានពេលដែលបងប្រុសរបស់ខ្ញុំធ្លាប់ដើររើសខ្យង ចាប់ក្តាម នឹងរកត្រីនៅតាមវាលស្រែដើម្បីយកទៅធ្វើម្ហូបឲ្យបងប្អូនដទៃទៀតហូប ។ ខ្ញុំបានបួងសួងសុំក្តីសុខសប្បាយ ដូច្នេះហើយបានជាម្តងនោះគាត់អាចត្រឡប់មកលេងផ្ទះ ហើយជូនខ្ញុំទៅមើលល្ខោនក្នុងពិធីបុណ្យនៅវត្តមួយ ។

នៅឆ្នាំ១៩៧៤ បងប្រុសខ្ញុំបានសរសេរសំបុត្រមួយច្បាប់ពីខេត្តបាត់ដំបងដែលក្នុងសំបុត្រនោះប្រាប់ថាគាត់គឺសុខសប្បាយធម្មតា ។ យើងក៏បានសរសេរសំបុត្រតបទៅគាត់វិញដោយសួរនូវសំណួរជាច្រើន ប៉ុន្តែយើងមិនដែលទទួលបានការឆ្លើយតបមកវិញអ្វីនោះទេ សូម្បីតែថាតើគាត់បានទទួលសំបុត្រដែលយើងបានផ្ញើតាមរយៈអ្នកនាំសាររបស់ខ្មែរក្រហមនោះក៏មិនដឹងផង ។ យើងបានសួរដំណឹងពីគាត់តាមរយៈអ្នកនាំសារនិងកម្មាភិបាលមួយចំនួនដែរ ប៉ុន្តែគ្មាននរណាម្នាក់ប្រាប់យើងទេ ។

បន្ទាប់មក ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានបំបែកសមាជិកគ្រួសារទាំងអស់ឲ្យនៅដាច់ដោយឡែកពីគ្នា ។ ឪពុកម្តាយខ្ញុំត្រូវបានចាត់ឲ្យទៅឃ្វាលគោនិងធ្វើកសិកម្ម ចំណែកឯខ្ញុំនឹងបងប្អូនផ្សេងទៀតត្រូវធ្វើការងារនៅក្នុងកងចល័តដូចជាត្រូវលើកទំនប់ ជីកប្រឡាយជាដើម ។ ខ្ញុំខិតខំធ្វើការងារដើម្បីរក្សាជីវិតដោយមិនដឹងថាតើមានរឿងអ្វីកើតឡើងចំពោះឪពុកម្តាយ បង គីមឡេង នឹងបងប្អូនឯទៀតនោះទេ ។ ខ្ញុំគឺជាសាក្សីដែលបានឃើញពីទង្វើដ៏កំណាចសាហាវយង់ឃ្នងរបស់ខ្មែរក្រហមជាច្រើន ។ ដូចជានៅក្នុងឆ្នាំ១៩៧៨ប្រធានកងនារីម្នាក់របស់ខ្ញុំត្រូវបានគេចោទថាក្បត់ ។ គាត់ត្រូវបានចាប់ខ្លួននឹងយកទៅវះពោះ ។ នៅក្នុងរបបនោះ ខ្ញុំតែងតែរំពឹងថារឿងដ៏អាក្រក់បែបនេះនឹងមិនអាច



ហ៊ីម មុំ មានអារម្មណ៍រំជួលចិត្តពេលឃើញរូបថតបងប្រុសនៅគុកទួលស្លែង

កើតមានឡើងទៅលើសមាជិកគ្រួសារខ្ញុំនោះទេ ។ ប៉ុន្តែបន្ទាប់ពីការដួលរលំនៃរបបនេះ ទើបក្រុមគ្រួសាររបស់ខ្ញុំដឹងថាបងប្រុសរបស់ខ្ញុំឈ្មោះ គីមឡេង ត្រូវបានជាប់ឃុំឃាំងនៅគុកទួលស្លែង ។ នៅឆ្នាំ១៩៨២បងស្រីខ្ញុំម្នាក់ដែលធ្វើការនៅកាកបាទក្រហមកម្ពុជាបានឃើញរូបថតរបស់បង គីមឡេងនៅគុកទួលស្លែង ។

ខ្ញុំបានដឹងពីគុកទួលស្លែងនិងសាលាក្តីខ្មែរក្រហមតាមរយៈបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែជួយជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹង ទាំងបណ្តឹងរដ្ឋប្បវេណីនិងអ្នកដាក់ពាក្យបណ្តឹងធម្មតា ។ ខ្ញុំមិនប្រាកដថាតើមានអ្វីកើតឡើងចំពោះបងប្រុសរបស់ខ្ញុំនៅគុកទួលស្លែងនោះទេ ។ ប៉ុន្តែដោយផ្អែកទៅលើចំណេះដឹងដែលខ្ញុំទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជាគួបផ្សំនឹងតួនាទីជាអ្នកតំណាងផ្នែកច្បាប់ដែលខ្ញុំបានដាក់ពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ នោះ ខ្ញុំពិតជាជឿជាក់ថា បងប្រុសខ្ញុំត្រូវបានសួរចម្លើយ និងធ្វើទារុណកម្មយ៉ាងឃោរឃៅដើម្បីបានចម្លើយ ។ ខ្ញុំពិតជាមានការឈឺចាប់ណាស់ដែលបងប្រុសរបស់ខ្ញុំត្រូវក្លាយជាអ្នកដែលទទួលរងការធ្វើទារុណកម្មយ៉ាងឃោរឃៅនៅក្នុងគុកទួលស្លែង ។

ខ្ញុំពិតជាពេញចិត្តណាស់នៅពេលដឹងថា ឌុច ដែលជាប្រធានមន្ទីរស-២១បញ្ជាក់ថា ការធ្វើទារុណកម្មដ៏សាហាវឃោរឃៅនោះគឺស្ថិតនៅក្រោមការបញ្ជារបស់គាត់ ។ ប៉ុន្តែខ្ញុំមិនអាចលើកលែងទោសឲ្យគាត់បាននោះទេ ។ ថ្វីបើខ្ញុំបានទទួលរងនូវការឈឺចាប់ខាងផ្លូវចិត្តដោយសារតែលទ្ធផលនៃរបបនោះក៏ដោយ ក៏ខ្ញុំមានអារម្មណ៍ធូរស្បើយខ្លះហើយដោយសារតែខ្ញុំបានចូលរួមក្នុងដំណើរការនៃការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៅ ទួលស្លែង ខ្ញុំបានជួយឲ្យខ្មែរជំនាន់ក្រោយបានយល់ដឹងពីមហន្តរាយនៃរបបនោះ និង គឺខ្ញុំធ្វើឲ្យខ្លួនឯងបានអស់ចិត្ត ។ **ហ៊ីម មុំ**

# ដំណឹងសួររកបងប្អូន

ខ្ញុំបាទឈ្មោះ ថាន់ ហ៊ីន ។ ភរិយារបស់ខ្ញុំឈ្មោះ អេងលី ពិដល ហៅ ឡែត ។ ប្អូនប្រុសរបស់ខ្ញុំឈ្មោះ ថាន់ យ៉ែម និងមានប្រពន្ធឈ្មោះ អេងលី ដល្លីន ។ ប្រពន្ធរបស់ ថាន់ យ៉ែម គឺជាប្អូនបង្កើតរបស់ភរិយាខ្ញុំ ។ ពេលនេះខ្ញុំបាទសូមប្រកាសសួរយកគ្រួសាររបស់ ថាន់ យ៉ែម ភរិយានិងកូនរបស់គាត់មានដូចជា, យ៉ែម សុរិយាទេវី ហៅស្រី ដា ភេទស្រី, យ៉ែម មរកតវត្តិ ហៅ ស្រីដួង ភេទស្រី, យ៉ែម សុវត្ថារ៉ា ហៅ ប្រុស ស ភេទប្រុស, យ៉ែម សាវរីយ៍ ហៅ ធីតា ភេទស្រី, យ៉ែម វិបុល ហៅ បុល ភេទប្រុស, យ៉ែម ចរិយា ហៅ អាប៉ុង ភេទស្រី ។ ក្រុមគ្រួសាររបស់ប្អូន ថាន់ យ៉ែម បានបែកគ្នារហូតដល់ពេលនេះ ។ ពេលនោះ ខ្ញុំបាទបានផ្ញើកូនរបស់ខ្ញុំពីរនាក់នៅជាមួយគ្រួសាររបស់ ថាន់ យ៉ែម ដែរ ។ កូនរបស់ខ្ញុំឈ្មោះ ថាន់ ជ័យ៉ារ៉ាត់ ហៅ ដុល ប្តុកតួល ភេទប្រុស និងម្នាក់ទៀតឈ្មោះ ថាន់ ចិន្តានិមល ហៅ អាស្រី ភេទស្រី ។ កូនរបស់ខ្ញុំពីរនាក់នេះដែលស្នាក់នៅជាមួយ ថាន់ យ៉ែម ក៏បាត់ដំណឹងមិនឃើញមកវិញដែររហូតដល់ពេលនេះ ។ ភរិយារបស់ខ្ញុំ (អេងលី ពិដល) បានបាត់ប្អូនប្រុសបង្កើតពីរនាក់ដែរគឺ អេងលី ជ័យមុនី ហៅ អានី និង អេងលី ដារ៉ាឫទ្ធិ ។ គ្រួសាររបស់លោក ថាន់ យ៉ែម បានបែកគ្នាពីគ្រួសារលោក ថាន់ ហ៊ីន និង កូនបង្កើត (ថាន់ ជ័យ៉ារ៉ាត់ និង ថាន់ ចិន្តានិមល) នៅឆ្នាំ១៩៧៥ នៅទីក្រុងភ្នំពេញ ។ អេងលី ដារ៉ាឫទ្ធី បានទៅលេងខេត្តកំពង់ស្ពឺក្នុងឆ្នាំ១៩៧៥ ហើយបានបាត់ខ្លួនរហូតដល់ពេលនេះ ។ ក្រុមគ្រួសាររបស់ ថាន់ យ៉ែម និង អេងលី ដល្លីន ត្រូវបានគេប្រទះឃើញចុងក្រោយនៅភូមិចំបក់ជាប់មែក ឃុំនាងទើត ស្រុកដំបែរ ខេត្តកំពង់ចាម ។ បើសិនជានរណាម្នាក់ដែលបានរៀបរាប់ខាងលើឮពីដំណឹងនៃការស្វែងរកនេះ សូមទាក់ទងទូរស័ព្ទលេខ ០១២ ៣៨៦ ១៧២, ០១៧ ៧២២ ៨៨៧ ឬ ០១៦ ៨៧៦ ៦៩២ ។







# តើមានរឿងអ្វីពិតប្រាកដកើតឡើងចំពោះខ្ញុំ?

*ប្រសិនបើខ្ញុំមិនធ្លាប់ដែលបានឃើញមន្ទីរស-២១ ដោយផ្ទាល់ភ្នែកខ្ញុំទេ ខ្ញុំប្រហែលជាមិនអាចស្រមើស្រមៃឃើញរូបភាពនៃទីកន្លែងនោះទេ*

នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៩ ខ្ញុំមានការរំភើបនិងភ័យខ្លាចដោយខ្ញុំមានឱកាសបានចូលធ្វើសក្ខីកម្មនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបានអង្គុយនៅក្នុងបន្ទប់សវនាការហើយរង់ចាំឆ្លើយនូវសំណួរទាំងឡាយដែលគ្រប់ភាគីទាំងអស់នឹងសួរមករូបខ្ញុំ ។ ខ្ញុំពិតជាចង់ចែករំលែកនូវរឿងរ៉ាវឈឺចាប់ទាំងឡាយដែលខ្ញុំបានទទួលរងដោយខ្ញុំបានរក្សានូវភាពស្ងៀមស្ងាត់អស់រយៈពេលជាច្រើនឆ្នាំ ទៅកាន់ពិភពលោកទាំងមូលឲ្យបានដឹង ។ ប៉ុន្តែ នៅចុងបញ្ចប់នៃដំណើរកាត់សេចក្តី ខ្ញុំបែរជាមានភាពតក់ស្លុត និងសោកស្តាយជាខ្លាំងនៅពេលដែលបានឮ ឌុច និយាយថា «សរុបមកវិញ្ញាណក្ខន្ធមិត្ត អ៊ា ហ៊ ស្លាប់ទៅ ខ្ញុំអត់បំពានវិញ្ញាណក្ខន្ធគេទេ គេស្លាប់ទៅហើយ ខ្ញុំទទួល ។ ឯចំណែក ទុក្ខវេទនារបស់លោក លី ហ៊ ក៏ខ្ញុំអត់បដិសេធដែរ ខ្ញុំសូមរំលែកទុក្ខ ។ សូមចប់ ។»



លី ហ៊

ជាការពិតណាស់ ឌុច បានបដិសេធក្នុងការទទួលស្គាល់ខ្ញុំថាបានជាប់ឃុំឃាំងនៅទួលស្លែង (មន្ទីរស-២១) ហើយបានរួចផុតពីសេចក្តីស្លាប់ដោយសារតែឈ្មោះរបស់ខ្ញុំមាននៅលើបញ្ជីកម្ទេចនៃស-២១ ។ ប៉ុន្តែ អ្វីដែលខ្ញុំបាននិយាយនៅថ្ងៃធ្វើសក្ខីកម្មនោះនិងអ្វីដែលខ្ញុំកំពុងតែប្រាប់អ្នកទាំងអស់គ្នានៅពេលនេះ គឺមិនមានអ្វីទាំងអស់ក្រៅតែអំពីការពិតអំពីជីវិតរបស់ខ្ញុំដែលទទួលរងគ្រោះនៅក្រោមរបបខ្មែរក្រហមដ៏សាហាវពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

ខ្ញុំបានចាប់កំណើតនៅភូមិព្រែកស្តី ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ។ កាលពីកុមារ ខ្ញុំរៀននៅសាលាព្រែកស្តី បានត្រឹមថ្នាក់ទី៩ ដោយសារតែមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅឆ្នាំ១៩៧០ ។ បន្ទាប់ពីនោះមក ខ្ញុំបានចំណាយពេលទាំងអស់ដើម្បីជួយឪពុកម្តាយខ្ញុំធ្វើស្រែចម្ការ ។

នៅឆ្នាំ១៩៧២ អ៊ុំ សឿន ដែលជាប្រធានភូមិបានរើសខ្ញុំឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហមដោយធ្វើជាឈ្លបខ្មែរក្រហមប្រចាំការនៅឃុំព្រែកស្តី ។ ក្នុងអំឡុងឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ ខ្ញុំធ្វើជាឈ្លបខ្មែរក្រហម ។ ដល់ក្រោយមកទៀត ខ្ញុំក៏ត្រូវបានចាប់ខ្លួននៅស្រុកកោះធំតំបន់២៥ នៅពេលដែលខ្ញុំកំពុងតែដើររកម្ហូបអាហារនៅតាមផ្ទះដោយសារតែពេលនោះខ្ញុំឃ្លានខ្លាំងពេក និងធ្វើការហត់នឿយពេក ។

ខ្ញុំត្រូវបានដាក់ឃុំឃាំង និងធ្វើទារុណកម្មនៅមន្ទីរ១៥ អស់រយៈពេលជាច្រើនថ្ងៃ ។ រហូតដល់ចុងឆ្នាំ១៩៧៦ ខ្ញុំ និងអ្នកទោសផ្សេងទៀតប្រហែលជាដប់នាក់ត្រូវបានបញ្ជូនខ្លួនទៅដាក់ឃុំឃាំងនៅគុកនៃមន្ទីរពេទ្យវិកលចរិតនៅតាខ្មៅ ។ ដំបូង យើង

ត្រូវបានខ្មែរក្រហមដឹកតាមទូក រួចហើយទើបយកទៅដាក់ឡាន មុនពេលធ្វើដំណើរទៅដល់តាខ្មៅ ។ ខ្ញុំត្រូវបានឃុំឃាំងនៅទីនោះ អស់រយៈពេលប្រហែលជាមួយខែ ។ នៅទីនោះ ខ្ញុំត្រូវបានខ្មែរក្រហមសួរចម្លើយចំនួនបីដង ។ រាល់ពេលសួរចម្លើយម្តងៗ ខ្មែរក្រហមតែងតែធ្វើទារុណកម្មមកលើរូបខ្ញុំ ។ ក្រោយមកទៀត ខ្ញុំត្រូវបានចងមុខរួចបញ្ជូនបន្តទៅមន្ទីរស-២១ ។ ខ្ញុំចាកចេញពីគុកនៅតាខ្មៅនៅពេលរសៀល ហើយទៅដល់មន្ទីរស-២១នៅពេលល្ងាច ។ នៅទីនោះ ខ្ញុំត្រូវបានដាក់ខ្នោះជើង ។ ខ្ញុំត្រូវបានដាក់ឲ្យនៅកន្លែងមួយក្បែរកន្លែងដែលខ្មែរក្រហមចម្អិនម្ហូបសម្រាប់កម្មាភិបាលនិងអ្នកទោស ។ ខ្ញុំដឹងថាទីនោះគឺជាមន្ទីរស-២១ ពីព្រោះសន្តិសុខដែលធ្វើការនៅទីនោះបាននិយាយប្រាប់ខ្ញុំថាវាជាមន្ទីរស-២១និងនៅពេលដែលខ្ញុំត្រូវបានឃុំខ្លួននៅព្រៃស សន្តិសុខនៅទីនោះបានប្រាប់ខ្ញុំថាកន្លែងដែលខ្ញុំបានជាប់ឃុំឃាំងពីមុននោះគឺជាមន្ទីរស-២១ ។ ខ្ញុំត្រូវបានដាក់ខ្នោះជើងជាមួយអ្នកទោសផ្សេងទៀតប្រហែលជាដប់ទៅដប់ប្រាំនាក់ជាមួយនឹងរនុកដែកដ៏វែងមួយ ។

យើងត្រូវបានដោះខ្នោះជើងនៅពេលដែលខ្មែរក្រហមសួរចម្លើយយើងប៉ុណ្ណោះ ។ ពួកយើងត្រូវបានអនុញ្ញាតឲ្យនោមនិងបន្ទោរបង់នៅក្នុងកេះគ្រាប់ដែលខ្មែរក្រហមបានផ្តល់ឲ្យនៅបន្ទប់ឃុំឃាំង ។ នៅក្នុងបន្ទប់នោះមានក្លិនស្អុយឆ្អេះឆ្អាបដែលស្ទើរតែមិនអាចទ្រាំបាន ។ រៀងរាល់បីថ្ងៃម្តងទើបគេយកលាមកចេញពីបន្ទប់ ។ ហើយប្រសិនបើខ្ញុំធ្វើឲ្យកំពប់ទឹកនោមនោះ ខ្ញុំនឹងត្រូវវាយដំ ។ អ្នកជាប់ឃុំឃាំងមិនត្រូវបានអនុញ្ញាតឲ្យនិយាយគ្នានោះទេ ។ ប្រសិនបើអ្នកយាមស្តាប់ឮអ្នកទោសនិយាយគ្នា អ្នកយាមទាំងនោះនឹងវាយនឹងដំបង ។ អ្នកទោសមួយចំនួនមានរបួសនៅនឹងកជើងជាហេតុធ្វើឲ្យមិនអាចដើរបាន ។ អ្នកខ្លះទៀតមានសភាពស្គមរីងរៃនិងអ្នកខ្លះទៀតដេកស្លាប់នៅនឹងកន្លែង ។ ជាញឹកញាប់ខ្ញុំតែងតែឮសម្រែកស្រែកនៅចន្លោះពីម៉ោង៧ទៅម៉ោង៨ល្ងាច ។

ពេលដែលខ្ញុំជាប់នៅមន្ទីរស-២១ ខ្ញុំត្រូវបានសួរចម្លើយបីដង ។ ការសួរចម្លើយម្តងៗមានរយៈពេលប្រហែលជាមួយម៉ោងទៅពីរម៉ោង ។ កម្មាភិបាលនោះបានសួរខ្ញុំអំពីមេរបស់ខ្ញុំ ។ ពេលនោះខ្ញុំត្រូវបានដាក់ខ្នោះហើយវាយខ្នង ទ្រូង និងដៃខាងឆ្វេង ។ មកដល់សព្វថ្ងៃ ដៃឆ្វេងខ្ញុំលែងប្រើប្រាស់បានប្រក្រតីដូចមុនទៀតហើយ ។ អ្នកសួរចម្លើយនោះបានប្រាប់ថា ខ្ញុំនេះរឹងក្បាលណាស់ ហើយគាត់បានសួរខ្ញុំថា តើខ្ញុំខ្លាចដំបង ឬក៏ខ្សែភ្លើងឬទេ ។ ខ្ញុំឆ្លើយថា "បាទខ្ញុំខ្លាចរបស់ទាំងអស់នោះណាស់ តែជីវិតខ្ញុំសម្រេចនៅលើបងហើយ ។ ប្រសិនបើបងចង់សម្លាប់ខ្ញុំ បងអាចសម្លាប់ខ្ញុំបាន ។" អ្នកសួរចម្លើយបែរជាគិតថា ខ្ញុំជាមនុស្សក្បាលរឹង ហើយខ្ញុំមិនខ្លាចដំបងឬក៏ខ្សែភ្លើង ។ អ្នកសួរចម្លើយនោះបានបោះកន្ទុយបារីនិងសំណល់កំណកទឹកដោះគោមកខ្ញុំ ហើយបញ្ជាខ្ញុំឲ្យស៊ី ។ បន្ទាប់មកខ្ញុំត្រូវអ្នកយាមបញ្ជូនត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ។ ខ្ញុំត្រូវបានខ្មែរក្រហមចងមុខម្តងទៀត បន្ទាប់មកទើបបញ្ជូនខ្ញុំមកកាន់មន្ទីរព្រៃស ។ នៅទីនោះ ខ្ញុំត្រូវបានដាក់ខ្នោះដៃគ្រប់ពេលវេលាលើកលែងតែពេលជីកប្រឡាយ ។ គ្រប់អ្នកទោសទាំងអស់មិនថាស្រីឬក៏ប្រុសត្រូវបានខ្មែរក្រហមដាក់ខ្នោះដៃបន្ទាប់ពីធ្វើការរួច ។ យើងតម្រូវឲ្យធ្វើការពីម៉ោង៤ព្រឹកដល់ម៉ោង១២ថ្ងៃត្រង់ ហើយពីម៉ោង១រសៀល



លី ហ៊ា ចូលរួមពិធីបង្សុកូលនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

ដល់ម៉ោង៥ល្ងាចនិងចុងក្រោយពីម៉ោង៥ល្ងាចដល់ម៉ោង៩យប់ ។

នៅមន្ទីរព្រៃសនោះបានជាងមួយខែ ខ្ញុំសម្រេចចិត្តរៀបផែនការគេចខ្លួនដើម្បីរំដោះជីវិតខ្ញុំ ។ ខ្ញុំបានលួចរត់នៅពេលល្ងាចពេលដែលកណ្តឹងអាហារបានបន្លឺឡើង ។ នៅក្នុងចិត្តរបស់ខ្ញុំ ខ្ញុំគិតថាវាជាឱកាសរស់តែមួយគត់របស់ខ្ញុំដោយរត់គេចចេញពីគុកនេះ ។ ខ្ញុំបានលួងលោមឲ្យអ្នកទោសម្នាក់ទៀត លួចរត់ជាមួយខ្ញុំ ។ ប៉ុន្តែ គាត់បានបដិសេធ ។ អ៊ីចឹងខ្ញុំក៏បានប្រាប់គាត់ថា ប្រសិនបើសន្តិសុខរកមុខខ្ញុំសូមប្រាប់ទៅសន្តិសុខនោះវិញថា ខ្ញុំទៅបន្ទោរបង់បាត់ហើយ ។ នៅពេលល្ងាចនោះ ខ្ញុំបានហែលឆ្លងទន្លេព្រែកហូរ ។ អ្នកយាមគុកដេញតាមខ្ញុំពីក្រោយ ប៉ុន្តែខ្ញុំអាចគេចខ្លួនរួចដោយសារតែមេឃងងឹតបាត់ទៅហើយ ។ ខ្ញុំបានបន្តដំណើរទៅទិសខាងត្បូងសំដៅទៅភ្នំជីសូរដោយសារតែភ័យខ្លាចថានឹងត្រូវខ្មែរក្រហមចាប់ខ្លួនបាន ខ្ញុំធ្វើដំណើរតែពេលយប់ប៉ុណ្ណោះ ហើយលាក់ខ្លួននៅក្នុងព្រៃនៅពេលថ្ងៃ ។ នៅតាមផ្លូវខ្ញុំបានបេះផ្លែឈើព្រៃដើម្បីចម្អែតក្រពះ ។

នៅពេលដែលខ្ញុំទៅដល់ភូមិកំណើតរបស់ខ្ញុំវិញ ខ្ញុំបានលាក់ខ្លួនក្នុងផ្ទះអស់រយៈពេលជាងមួយខែ ។ ខ្ញុំមានជំងឺជាទម្ងន់ ហើយជើងរបស់ខ្ញុំហើមជាខ្លាំង ។ ដោយសារតែភ័យខ្លាចខ្ញុំត្រូវខ្មែរក្រហមចាប់យកទៅវិញម្តងទៀត ឪពុករបស់ខ្ញុំបានរាយការណ៍ប្រាប់លេខាស្រុកដែលយើងស្គាល់ថា ខ្ញុំបានលួចរត់ហើយកំពុងតែរស់នៅក្នុងភូមិ ។ បន្ទាប់មក ខ្ញុំរស់នៅទីនោះជាមួយឪពុកម្តាយខ្ញុំរហូតដល់ពេលដែលកងទ័ពវៀតណាមបានចូលមករំដោះប្រទេសកម្ពុជា ។

ចាប់តាំងពីពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ខ្ញុំរស់នៅដោយភាពឈឺចាប់ព្រោះតែងតែនឹកឃើញនូវរឿងរ៉ាវដែលខ្មែរក្រហមបានធ្វើទារុណកម្មមកលើខ្ញុំកាលពីពេលដែលខ្ញុំនៅជាអ្នកទោស ។

នៅឆ្នាំ២០០៨ ខ្ញុំមានការសប្បាយរីករាយនៅពេលដែលខ្ញុំបានជួបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជម្រាបប្រាប់ខ្ញុំអំពីសិទ្ធិរបស់ខ្ញុំដែលជាជនរងគ្រោះក្រោមរបបខ្មែរក្រហមក្នុងការដាក់ពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទោះបីជាពេលខ្លះដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមហាក់ដូចជាស្មុគស្មាញពិបាកយល់ ប៉ុន្តែខ្ញុំនៅតែសប្បាយចិត្តនឹងចូលរួមនៅក្នុងដំណើរការនេះ ។ ពីព្រោះអ្វីដែលសំខាន់បំផុតនោះគឺខ្ញុំមានមោទកភាពដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបានខិតខំប្រឹងប្រែងធ្វើការជំនួសពួកយើងដើម្បីផលប្រយោជន៍របស់ជនរងគ្រោះ ។ ខ្ញុំពេញចិត្តដែល ឌុច ទទួលទោសជាប់គុកអស់មួយជីវិតពីព្រោះទង្វើដែលគាត់បានប្រព្រឹត្តគឺមិនអាចអត់ឱនឲ្យបានឡើយ ។ ខ្ញុំមានអារម្មណ៍ធូរស្បើយនៅពេលដែលខ្ញុំបានចែករំលែករាល់បទពិសោធន៍ទាំងអស់ដែលខ្ញុំបានជួបប្រទះកាលពីរបបខ្មែរក្រហមជាពិសេសនៅមន្ទីរទួលស្លែង ។ ប្រសិនបើខ្ញុំមិនធ្លាប់ដែលបានឃើញមន្ទីរទួលស្លែងដោយផ្ទាល់ភ្នែកខ្ញុំទេខ្ញុំប្រហែលជាមិនអាចស្រមើលស្រមៃឃើញរូបភាពនៃទីកន្លែងនោះទេ ។ ក្នុងនាមជាជនរងគ្រោះមួយរូបក្នុងចំណោមជនរងគ្រោះរាប់លាននាក់ផ្សេងទៀតដែលរួចរស់ជីវិតខ្ញុំមានមោទកភាពដែលបានឡើងធ្វើសក្ខីកម្មនៅពីមុខតុលាការ ។ កូនខ្មែរជំនាន់ក្រោយនិងពិភពលោកទាំងមូលនឹងបានដឹងឮអំពីភាពសាហាវឃោរឃៅទាំងឡាយដែលខ្មែរក្រហមបានប្រព្រឹត្ត ។ ការចូលរួមរបស់ខ្ញុំក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមបានជួយឲ្យខ្ញុំមានអារម្មណ៍ស្ងប់ ។

**លី ហ៊ា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: truthsocheat@dccam.org
Home page: www.dccam.org

# ខ្ញុំសុំឱ្យមានបូជនីយដ្ឋានសម្រាប់ព្រលឹងរបស់បងខ្ញុំ

ខ្ញុំចង់ចូលរួមក្នុងសំណុំរឿង០០១នៅសាលាក្តីខ្មែរក្រហមដោយសារតែខ្ញុំបានរងទុក្ខសោកដ៏ឈឺចាប់ពីការបាត់បង់បងប្រុសម្នាក់ដោយស្នាដៃខ្មែរក្រហម ។ ទុក្ខសោកនេះនៅតែដក់ជាប់ក្នុងចិត្តខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ហើយជាលទ្ធផលខ្ញុំបានកើតជំងឺដេកមិនលក់ ។

បងប្រុសខ្ញុំឈ្មោះ កែ កែងស៊ី ហៅ ដែន ត្រូវបានសម្លាប់នៅមន្ទីរស-២១ក្នុងរបបខ្មែរក្រហម ។ អស់រយៈពេលជាច្រើនឆ្នាំនេះ ខ្ញុំមិនដែលបានដឹងថាបងប្រុសខ្ញុំត្រូវបានសម្លាប់នៅទីណាទេ ប៉ុន្តែនៅឆ្នាំ២០០៨ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ព័ត៌មានលម្អិតស្តីពីការឃុំខ្លួនបងប្រុសខ្ញុំដែលបានបញ្ជាក់ថា គាត់ត្រូវបានសម្លាប់នៅគុកទួលស្លែង ។ ខ្ញុំនៅតែមិនយល់ថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់បងប្រុសខ្លួន ។

ខ្ញុំបានដឹងថា បងប្រុសខ្ញុំត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៧ ។ នៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៦ មុនការចាប់ខ្លួនរបស់គាត់ បងប្រុសខ្ញុំបានមកលេងក្រុមគ្រួសារម្តង ។ នៅអំឡុងពេលនោះ បងប្រុសខ្ញុំមិនបានចែករំលែករឿងរ៉ាវរបស់គាត់ជាមួយនឹងគ្រួសារប៉ុន្មានទេ ហើយគាត់គ្រាន់តែនិយាយថា គាត់ធ្វើការជាពេទ្យទាហាន ។ រយៈពេលពីរបីថ្ងៃក្រោយមក គាត់ក៏ធ្វើដំណើរត្រឡប់ទៅភ្នំពេញវិញ ។ ចាប់តាំងពីពេលនោះមក គាត់មិនដែលត្រឡប់មកម្តងទៀតឡើយ ហើយយើងក៏មិនដែលទទួលបានដំណឹងអ្វីពីគាត់ដែរ ។ ខ្ញុំមិនដឹងថាខ្មែរក្រហមនាំយកបងប្រុសខ្ញុំទៅណាទេ ។

ក្រោយមក ខ្ញុំបានដឹងថាគាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ តាមរយៈបងប្អូនជីដូនមួយរបស់ខ្ញុំគឺ កៀវ សាន ។ បច្ចុប្បន្ននេះ កៀវ សាន គឺជាគ្រូបង្រៀននៅអនុវិទ្យាល័យតាអូន ។ កៀវ សាន បានផ្តល់ព័ត៌មានជាច្រើនទាក់ទងនឹងការចាប់ខ្លួនរបស់បងប្រុសខ្ញុំ ។ ខ្ញុំជឿជាក់ថា ឌុច ដែលជាប្រធានមន្ទីរស-២១ គឺជាជនដែលទទួលខុសត្រូវលើការស្លាប់របស់បងប្រុសខ្ញុំ ។ ខ្ញុំបានចូលរួមនៅក្នុងសំណុំរឿង០០១របស់សាលាក្តីខ្មែរក្រហមពីព្រោះខ្ញុំបានរងទុក្ខសោកដ៏សែនវេទនាចាប់តាំងពីការស្លាប់របស់បងប្រុសខ្ញុំ ។ ការបាត់បង់នេះបានយាយីសតិអារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំងដែលធ្វើឲ្យខ្ញុំឈឺក្បាលហើយឆាប់ភ្លេចភ្លាំង ។ ខ្ញុំមិនដែលទៅពិគ្រោះជាមួយគ្រូពេទ្យ ឬទៅព្យាបាលនៅមន្ទីរពេទ្យឡើយ ពីព្រោះខ្ញុំមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ថ្លៃព្យាបាលទេ ។ ក្រុមគ្រួសារខ្ញុំមានជីវភាពលំបាកណាស់ ដោយសារតែបងប្រុសពីរនាក់របស់ខ្ញុំត្រូវបានសម្លាប់ដោយខ្មែរក្រហម ។ ក្នុងនោះរួមមានបង កែ កែងស៊ី ដែលត្រូវបានសម្លាប់នៅគុកទួលស្លែង ។ ដោយសារតែខ្ញុំគ្មានលទ្ធភាពក្នុងការបង់ថ្លៃព្យាបាល សុខភាពរបស់ខ្ញុំកាន់តែទ្រុឌទ្រោមទៅ ។


កែ សាម៉ូត ពេលទស្សនាសារមន្ទីរទួលស្លែង

ប្រសិនបើសាលាក្តីខ្មែរក្រហមផ្តល់សំណងឲ្យជនរងគ្រោះវិញខ្ញុំនឹងសូមស្នើសុំឲ្យមានការសាងសង់បូជនីយដ្ឋានរំឭកវិញ្ញាណក្ខន្ធក្នុងភូមិរបស់ខ្ញុំដើម្បីឲ្យអ្នកភូមិទាំងអស់អាចប្រារព្ធពិធីតាមបែបព្រះពុទ្ធសាសនា ឧទ្ទិសបុណ្យកុសលជូនដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ហើយខ្ញុំក៏សូមឧទ្ទិសបុណ្យកុសលនេះជូនដល់បងប្រុសទាំងពីរនាក់របស់ខ្ញុំដែលបានស្លាប់ដោយគ្មានហេតុផល ។

**កែ សាម៉ូត**

# យុត្តិធម៌ដែលបានបាត់បង់

*ប្រសិនជាប្ដីខ្ញុំនៅរស់ ក្រុមគ្រួសារខ្ញុំអាចនឹងមានសុភមង្គលជាងនេះ ហើយអាចមានជីវភាព រស់នៅដ៏សមរម្យមួយ ។ ផ្ទុយទៅវិញ ខ្ញុំមានតែម្នាក់ឯងដើម្បីចិញ្ចឹមបីបាច់កូនរបស់ខ្ញុំទាំងពីរ ។*

ប្ដីខ្ញុំឈ្មោះ ហេង ជឿន បានចូលបម្រើបដិវត្តន៍នៅឆ្នាំ ១៩៧៤ ។ ក្រោយមកទៀត គាត់បានចូលធ្វើជាយោធាក្នុងពេលសង្គ្រាមរវាងខ្មែរក្រហម និងកងទ័ព លន់ នល់ នៅទីក្រុងភ្នំពេញឆ្នាំ១៩៧៥ ។ ក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្ដីខ្ញុំត្រូវបានចាត់តាំងឲ្យទទួលបន្ទុកផ្នែកសេដ្ឋកិច្ចនៅក្បែរផ្សារថ្មី ។ នៅឆ្នាំ ១៩៧៨ជាពេលដែលប្រធានមន្ទីររបស់ខ្មែរក្រហមជាច្រើននាក់ត្រូវបានចាប់ខ្លួន ប្ដីខ្ញុំត្រូវបានឡើងតំណែងឲ្យធ្វើការនៅមន្ទីរ៨៧០ សារជាថ្មី ។ ជាអកុសល គាត់ធ្វើការនៅទីនោះបានមួយខែតែប៉ុណ្ណោះ ក៏ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅខាងជើងផ្សារថ្មី ។ ខណៈពេលនោះ ខ្ញុំឈរនៅមួយរយម៉ែត្រពីគាត់ហើយបានឃើញគាត់កំពុងតែនិយាយទូរស័ព្ទ ។ ក្រោយពេលដែលនិយាយចប់កម្មាភិបាលខ្មែរក្រហមបានបើកឡាន ហើយឈប់នៅមុខមន្ទីររបស់គាត់ ។ បន្ទាប់មក គាត់ក៏ចូលឡាននោះ ហើយក៏បើកចេញទៅ ។ ប៉ុន្តែខ្ញុំមិនដឹងថាកម្មាភិបាលទាំងនោះយកប្ដីខ្ញុំទៅណាទេ ។ មួយរយៈក្រោយមក ទើបខ្ញុំដឹងថាគាត់ត្រូវបានអង្គការចាប់ខ្លួនទាំងមិនដឹងមូលហេតុ ។

មួយម៉ោងក្រោយមក ខ្ញុំត្រូវជម្លៀសដោយឡានមួយគ្រឿងរួមដំណើរជាមួយនឹងស្ត្រីផ្សេងទៀតដែលប្ដីរបស់អ្នកទាំងនោះត្រូវបានចាប់ខ្លួន យើងទាំងអស់គ្នាត្រូវបានបញ្ជូនទៅកាន់វត្តជ័យឧត្តមនៅស្រុកអង្គស្នួលខេត្តកណ្ដាល ។ នៅទីនោះ យើងត្រូវបានបញ្ជាឲ្យដាំដំណាំ ។ ក្រោយមកទៀត យើងក៏ត្រូវបានបញ្ជូនទៅខេត្តបាត់ដំបងហើយនៅទីនោះហើយដែលខ្ញុំបានកើតកូនស្រីរបស់ខ្ញុំមួយ ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានរស់នៅភ្នំធិបតីក្នុងខេត្តបាត់ដំបងដែលនៅទីនោះខ្ញុំបានឃើញមនុស្សជាច្រើនត្រូវបានរងការធ្វើទារុណកម្មដោយខ្មែរក្រហមដោយសារតែការងាររហួសកម្លាំង ។ នៅពេលយប់ អ្នកដែលគ្មានកម្លាំងធ្វើការបន្តទៀតត្រូវបានបណ្ដើរទៅជើងភ្នំ ហើយសម្លាប់ចោល ។

នៅឆ្នាំ១៩៨០ មួយឆ្នាំក្រោយការដួលរលំរបបខ្មែរក្រហម ខ្ញុំបានវិលត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញដើម្បីស្វែងរកប្ដីខ្ញុំ ។ ខ្ញុំបានទៅគុកទួលស្លែងដើម្បីស៊ើបរកដំណឹងគាត់ ។ នៅទីនោះ ខ្ញុំបានឃើញរូបថតជាច្រើនសន្លឹក ប៉ុន្តែមិនឃើញរូបថតប្ដីខ្ញុំឡើយ ។ លើសពីនេះមានឧបករណ៍ធ្វើទារុណកម្មជាច្រើនប្រភេទក្នុងអគារនីមួយៗ ។ ក្នុងអំឡុងពេលទៅគុកទួលស្លែង ខ្ញុំបានធុំក្លិនសាកសពរលួយនិងឈាមមនុស្សនៅឡើយ ។

នៅឆ្នាំ១៩៨១ នៅពេលដែលខ្ញុំធ្វើដំណើរទៅកាន់ខេត្តសៀមរាប ខ្ញុំបានជួប វ៉ែត ជាអតីតកម្មាភិបាលខ្មែរក្រហមដែលធ្លាប់ធ្វើការជាមួយប្ដីខ្ញុំ ។ វ៉ែត បានប្រាប់ខ្ញុំថា ប្ដីខ្ញុំត្រូវបានចាប់ខ្លួនទៅព្រៃសដោយចោទថាក្បត់អង្គការ ។ តាមការពិត ប្ដីមិនដែលធ្វើអ្វីខុសឡើយ ។

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ ដោយនៅទទួលរងទុក្ខសោកចំពោះការស្លាប់របស់ប្ដីខ្ញុំ ខ្ញុំបានសម្រេចចិត្តដាក់ពាក្យស្នើសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅឯសាលាក្ដីខ្មែរក្រហមតាមរយៈការសម្របសម្រួលរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពាក្យស្នើសុំរបស់ខ្ញុំត្រូវបានបដិសេធ ហើយដោយសារតែតំណាងមេធាវីរបស់ខ្ញុំ ខ្ញុំបានសម្រេចចិត្តប្ដឹងឧទ្ធរណ៍ទាក់ទងនឹងពាក្យស្នើសុំរបស់ខ្ញុំ ។

**ខៀវ នាភ**

# ម្តាយដែលជាវីរៈនារីរបស់ខ្ញុំ

ពេលដែលខ្ញុំធំដឹងក្តីឡើងម្តាយខ្ញុំបានប្រាប់ខ្ញុំថា “មុនពេលដែលឪពុកឯងចាកចេញទៅ គាត់បានប្រាប់ម៉ែឲ្យដាក់ឈ្មោះកូនថា“សោភា” បើសិនម៉ែកើតបានកូនស្រី ។ បើសិនកូននោះជាកូនប្រុស គាត់និយាយថា ចាំគាត់ត្រឡប់មកវិញសិនទើបដាក់ឈ្មោះឲ្យកូននេះ ។ សំណាងហើយដែលកូនឯងគឺជាកូនស្រី បើមិនមែនកូនស្រីទេ ម៉ែនឹងចាំឪពុកឯងមកវិញដើម្បីដាក់ឈ្មោះកូននោះតាមពាក្យសន្យា ។ នោះគឺជាការសន្ទនារវាងម៉ែ និងពុកឯងនេះជាលើកចុងក្រោយបង្អស់ ។ ចាប់តាំងពីពេលនោះមក ពុកឯងមិនត្រឡប់មកវិញឡើយ ។

ជាអកុសល ម្តាយខ្ញុំបានទទួលមរណៈភាពភ្លាមៗក្រោយពេលដែល កាំង ហ្កេកអ៊ាវ ឌុច ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។



ហាវ សោភា

ដោយសារតែខ្ញុំធំដឹងក្តីឡើងដោយគ្មានឪពុក ខ្ញុំបានរំពឹងចង់ឃើញមុខពុក ទទួលបានការថ្នាក់ថ្នមពីពុក និងចង់ហៅគាត់ថា “ពុក” ។ ម្តាយខ្ញុំ និងខ្ញុំបានសង្ឃឹមថាពុកនៅរស់រានមានជីវិត ហើយគាត់នឹងត្រឡប់មកផ្ទះនៅថ្ងៃណាមួយមិនខាន ។ ប៉ុន្តែពុកបាត់ខ្លួនរហូត ហើយខ្ញុំបានត្រឹមតែដឹងពីរឿងរ៉ាវខ្លះៗ របស់ពុកតាមរយៈម្តាយខ្ញុំតែប៉ុណ្ណោះ ។ កាលពីខ្ញុំមានអាយុប្រហែលប្រាំមួយទៅប្រាំពីរឆ្នាំ ម្តាយខ្ញុំតែងតែនិយាយពីពុកនិងខ្សែជីវិតរបស់គាត់កាលពីរបបខ្មែរក្រហម ។ ម៉ែបានប្រាប់ថាពុកជាមនុស្សស្លូតបូតបេះដូងយកអាសារ រួសរាយរាក់ទាក់ និងខស្បាហ៍ព្យាយាម ។ អ្នកភូមិចូលចិត្តពុកគ្រប់គ្នា ។ រឿងរ៉ាវទាំងនេះបានធ្វើឲ្យខ្ញុំស្រឡាញ់ និងគោរពពុក បើទោះបីជាខ្ញុំមិនដែលឃើញមុខគាត់ក៏ដោយ ។ ខ្ញុំតែងតែសង្ឃឹមថានឹងបានជួយពុកនៅថ្ងៃណាមួយជាមិនខាន ។

ខ្ញុំបានកើតភ្លាមៗក្រោយពេលដែលឪពុកខ្ញុំបានបាត់ខ្លួន ។ ឪពុកបានចូលបម្រើចលនាខ្មែរក្រហមនៅចុងទសវត្សរ៍៤០ ហើយគាត់ត្រូវបានបញ្ជូនទៅប្រទេសវៀតណាម រួចត្រឡប់មកប្រទេសកម្ពុជាវិញនៅទសវត្សរ៍៦០ ។ ម៉ែនិយាយថា ពុកបានធ្វើការងារគ្រប់បែបយ៉ាងដើម្បីប្រទេសជាតិ ។ ពុកតែងតែនិយាយប្រាប់ម៉ែថាគាត់នឹងលាលែងឈប់ធ្វើយោធា ហើយនឹងត្រឡប់មករស់នៅជាមួយម៉ែក្នុងជីវភាពសាមញ្ញបំផុតនៅពេលដែលប្រទេសជាតិទទួលបានសន្តិភាព ។ ប៉ុន្តែ នៅពាក់កណ្តាលឆ្នាំ១៩៧៥ ពុកនិងម៉ែត្រូវបានបញ្ជូនទៅបឹងត្របែកនៅភ្នំពេញជាមួយនឹងយោធាជាច្រើននាក់ទៀតដែលទើបតែត្រឡប់មកពីប្រទេសវៀតណាម ។ នៅបឹងត្របែក ម៉ែបានធ្វើជាអ្នកថែទាំក្មេងនិងជាចុងភៅ ។ ចំណែកឯពុកវិញគាត់នៅតែធ្វើជាយោធាដដែលឪពុកជាមនុស្សដ៏ស្លូតបំផុត ហើយគាត់មិនដែលសំឡុតឬនិយាយដោយអាងអំណាចបើទោះបីជាម៉ែខឹងនឹងគាត់ក៏ដោយ ។ ម៉ែបាននិយាយថា ពុកជាមនុស្សមានហេតុផលនិងស្ងប់ស្ងាត់ ។ ដូច្នេះអ្នកទាំងពីរតែងតែគោរពគ្នាទៅវិញទៅមក ។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦គឺជាថ្ងៃដ៏ជូរចត់និងអាប់អួរបំផុតក្នុងជីវិតរបស់ម្ដាយខ្ញុំ ។ នៅថ្ងៃនោះ ពុកបានប្រាប់ម៉ែថាគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការ ប៉ុន្តែតាមពិតម៉ែមិនបានដឹងថាការចាត់តាំងនោះមានន័យថាពុកនឹងត្រូវយកទៅសម្លាប់ទេ ។ ម៉ែបានប្រាប់ខ្ញុំថា បើសិនជាម៉ែបានដឹងមុន នោះគាត់នឹងឃាត់ពុកឬតាមពុករហូត បើទោះបីជាម៉ែត្រូវស្លាប់ជាមួយពុកក៏ដោយ ។ ប៉ុន្តែ ម៉ែមិនបានគិតសង្ស័យថាពុកអាចនឹងមានគ្រោះថ្នាក់ឡើយ ។ ក្រោយពេលដែលពុកចាកចេញទៅ ម៉ែត្រូវបានបញ្ជូនទៅក្បាលជ្រោយ ។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ម៉ែកើតបានខ្ញុំ ។ ប៉ុន្មានសប្ដាហ៍ក្រោយមក ម៉ែត្រូវបានបង្ខំឲ្យដងទឹកពីទន្លេមកស្រោចដំណាំ ទោះបីជាសុខភាពគាត់នៅទន់ខ្សោយក៏ដោយ ។ រហូតដល់រយៈពេលប្រាំបួនខែក្រោយមកទៀតទើបកម្មាភិបាលខ្មែរក្រហមបានប្រាប់ម៉ែថាពុកត្រូវបានចាប់ខ្លួន ។ ឮដូច្នោះ ម៉ែមានអារម្មណ៍រន្ធត់ចិត្ត ហើយនិយាយមិនចេញទាល់តែសោះ ។ ទោះជាយ៉ាងណាក្ដី ម៉ែនៅតែមានជំនឿថា ពុកនៅរស់រានមានជីវិតពីព្រោះពុកគឺជាមនុស្សឆ្លាត ហើយអាចនឹងរស់គេចខ្លួនទៅវៀតណាមក៏ថាបាន ។ យ៉ាងណាមិញ ម៉ែមិនអនុញ្ញាតឲ្យយំទេ ហើយត្រូវតែនៅស្ងៀមគ្មានប្រតិកម្មអ្វីក្រៅពីបន្តធ្វើការងារដូចធម្មតា ។ ប៉ុន្តែ ម៉ែនៅតែគិតពីពុកក្នុងចិត្តរហូត ។

នៅក្នុងអំឡុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសម៉ែនិងខ្ញុំទៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ម៉ែត្រូវបានចាត់តាំងឲ្យជីករណ្ដៅចំនួន៦០ ក្នុងមួយថ្ងៃដើម្បីដាំដើមចេក ។ ចំណែកខ្ញុំវិញត្រូវបានចាត់តាំងឲ្យចូលក្នុងកងកុមារ ។ ម៉ែបានប្រាប់ខ្ញុំថា ម៉ែបានលួចបង្រៀនខ្ញុំឲ្យហៅគាត់ថា "ម៉ែ" មិនមែន "មីង" ដូចដែលអ្នកថែទាំក្មេងបានបង្គាប់ខ្ញុំទេ ។ ស្ថានភាពរស់នៅតាមតំបន់ភ្នំនៅស្រុកស្ទឹងត្រង់ គឺពិតជាលំបាក ហើយម៉ែបានប្រាប់ខ្ញុំថា ខ្ញុំគឺជាមូលហេតុតែមួយគត់ដែលគាត់ត្រូវតែតស៊ូរស់ ។

នៅពេលដែលកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា ខ្មែរក្រហមបានព្យាយាមជម្លៀស យើងទាំងពីរនាក់ តែម៉ែបានរត់គេចខ្លួនហើយបានធ្វើដំណើរត្រឡប់មកកាន់ភូមិកំណើតរបស់គាត់វិញ ។ នៅតាមផ្លូវ ខណៈពេលដែលយើងទាំងពីរនាក់កំពុងតែគេចគ្រាប់កាំភ្លើងនិងគ្រាប់បែក ម៉ែស្ទើរតែសន្លប់បាត់ស្មារតីនៅពេលដែលគាត់បានឮខ្ញុំសួរថា "ឯណាពុក?" នៅពេលដែលយើងមកដល់ភូមិវិញ គ្រួសារសាច់ញាតិរបស់ម៉ែនិងអ្នកភូមិផ្សេងទៀតភ្ញាក់ផ្អើលនៅពេលដែលឃើញម៉ែមានរូបរាងស្គមស្គាំងនិងសម្លៀកបំពាក់ដាច់រហែក ។ ម៉ែគ្មានបានយកអ្វីមកជាមួយទេ ក្រៅពីស្លាបព្រាមួយនិងរូបខ្ញុំតែប៉ុណ្ណោះ ។ ក្រោយមក ម៉ែបានសម្រេចចិត្តសង់ខ្ទមតូចមួយនៅដាច់ស្រយាលពីគេ ដែលម៉ែនិងខ្ញុំអាចរស់នៅដោយស្ងប់ស្ងាត់ ។ ម៉ែធ្វើការងារគ្រប់បែបយ៉ាងទាំងអស់ ហើយខ្ញុំបានជួយរែកដីនិងលក់បន្លែ ។ ខ្ញុំចាំថា ខ្ញុំពិតជាចង់ទៅរៀនខ្លាំងណាស់កាលពីនៅក្មេង ប៉ុន្តែម៉ែបានបដិសេធដោយសារតែគាត់បារម្ភពីសុវត្ថិភាពខ្ញុំ ។ ប៉ុន្តែគាត់បានបង្រៀនស្រៈ និងព្យញ្ជនៈដល់ខ្ញុំរាល់យប់ដើម្បីឲ្យខ្ញុំអាចចូលរៀនថ្នាក់ធំជាមួយនឹងមីងខ្ញុំបាន ។

នៅពាក់កណ្ដាលទសវត្សរ៍៨០ ម៉ែនៅតែជឿជាក់ថាពុកនៅរស់នៅឡើយ ។ រាល់ល្ងាច ម៉ែតែងតែនាំខ្ញុំទៅទំនប់១មករា ដើម្បីស៊ើបសួររកដំណឹងពុក ។ អ្នកខ្លះបាននិយាយថាធ្លាប់បានឃើញពុក ចំណែកឯអ្នកខ្លះទៀតនិយាយថាពុកត្រូវបានចាប់ខ្លួន ។


ហាវ សោភា ចូលរួមប្រារព្ធព្រះពុទ្ធសាសនានៅវាលពិឃាតជើងឯក

បើទោះបីជាមានសង្ឃឹមតិចតួចក៏ដោយ ក៏ម៉ែនៅតែព្យាយាមស៊ើបដំណឹងពីពុកបន្ថែមទៀត ។ រាល់ពេលដែលដឹងថាមានមនុស្សវិលត្រឡប់មកភូមិវិញ ម៉ែតែងតែនាំខ្ញុំទៅភូមិដោយសង្ឃឹមថាក្រុមគ្រួសារយើងនឹងបានជួបជុំគ្នាវិញ ។ យើងទាំងពីរនាក់ខកចិត្តម្តងហើយម្តងទៀតមិនចេះចប់ ។ នៅឆ្នាំ១៩៩២ បន្ទាប់ពីការព្យាយាមជាច្រើនលើកជាច្រើនសារ យើងមិនអាចបន្តស៊ើបរកដំណឹងពុកតទៅទៀតឡើយ ហេតុដូច្នេះ ម៉ែក៏សម្រេចចិត្តឈប់តាមរកពុក ។ ប៉ុន្តែ ម៉ែមិនដែលបំភ្លេចពុកឡើយ ។ របស់របបដែលធ្វើឲ្យម៉ែចងចាំពុករួមមានខ្សែក្រវ៉ាត់ដែលពុកឲ្យម៉ែពេលដែលអ្នកទាំងពីរទើបតែរៀបការថ្មីៗ ប្រអប់បាយរបស់ទាហាន (ដែលម៉ែបានយកមកប្រើ) ត្រីវិស័យបែកមួយ និងភ្លើងម៉ូតូដែលរបស់ទាំងនេះត្រូវបានរក្សាទុកយ៉ាងប្រយ័ត្ន ។ ដោយបានថែរក្សាវត្ថុតាងទាំងអស់នេះ ម៉ែមានអារម្មណ៍ថាការចងចាំរបស់គាត់ពីពុកនឹងមិនសាបសូន្យឡើយ ។

ដោយសារតែជីវភាពរស់នៅខ្វត់ខ្សោយខ្ញុំបានឈប់រៀន ហើយជួយម៉ែរកលុយ បើទោះបីជាខ្ញុំចង់រៀនបន្តក៏ដោយ ។ មូលហេតុដែលខ្ញុំចង់ឲ្យពុកត្រឡប់មកវិញគឺដើម្បីជួយឲ្យខ្ញុំបានទទួលការអប់រំល្អ ។ ខ្ញុំមានក្តីស្រមៃមួយគឺថា ខ្ញុំចង់ធ្វើជាមេធាវី ឬជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ។ ជាអកុសល ខ្ញុំមិនអាចសម្រេចក្តីស្រមៃរបស់ខ្ញុំបានឡើយ ។ ជីវិតយើងទាំងពីរនាក់ហាក់បីដូចជាមានតែកាយតែគ្មានវិញ្ញាណ ។ យើងរស់នៅដោយស្ងៀមស្ងាត់ឯកោនិងគ្មានសង្ឃឹម ។ នេះគឺជាលទ្ធផលដែលរបបខ្មែរក្រហមបានប្រែក្លាយជីវិតគ្រួសារខ្ញុំ ។

ខណៈពេលដែលពេលវេលាចេះតែកន្លងផុតទៅយើងនៅតែបន្តរង់ចាំដំណឹងពីពុកថាតើពុកនៅរស់ឬក៏ស្លាប់ដើម្បីឲ្យយើងបានសប់ចិត្តខ្លះ ។ ប៉ុន្តែ យើងមិនទទួលបានដំណឹងអ្វីទាល់តែសោះ ។ ការរង់ចាំដោយគ្មានក្តីសង្ឃឹមគឺឈឺចាប់ណាស់ ប៉ុន្តែម៉ែមិនដែលរអ៊ូឡើយ ។ ក្រៅពីរងទុក្ខផ្លូវចិត្តម៉ែត្រូវប្រឹងធ្វើការធ្ងន់ដើម្បីជីវភាព ហើយម៉ែមិនដែលបានដេកគ្រប់គ្រាន់ឡើយ ។ រាល់យប់ម៉ែតែងតែសម្លឹងមើលមេឃមើលផ្កាយតាមបង្អួច ។ គាត់គិតតែម្នាក់ឯង ហើយឈឺចាប់ក្នុងចិត្ត ។ ម៉ែមិនចូលចិត្តទៅណាហើយក៏មិនសូវដើរតាមភូមិដែរបើទោះបីជាខ្ញុំបានជំរុញលើកទឹកចិត្តគាត់ជាច្រើនលើកក៏ដោយ ។ រាល់លើកម៉ែតែងតែឆ្លើយថា “មិនថាកន្លែងណាដែលម៉ែទៅទេ កន្លែងនោះគឺគ្មានន័យអ្វីសម្រាប់ជីវិតម៉ែឡើយ ។ ម៉ែមិនដឹងជាប្រាប់ឯងយ៉ាងម៉េចទេ ។ ខ្លួនម៉ែដូចជាគ្មានវិញ្ញាណអ្វីទាំងអស់ចាប់តាំងពីការបាត់ខ្លួនរបស់ពុកឯង ។ វាបានបង្កជារបួសដ៏ធំមួយក្នុងជីវិតរបស់ម៉ែ ។ របួសនេះអាចព្យាបាលបាននៅពេលដែលម៉ែស្លាប់ទៅប៉ុណ្ណោះ” ។

ក្រោយពីបានចាំអស់រយៈពេលសាមសិបឆ្នាំជាចុងក្រោយយើងបានដឹងថាការរង់ចាំរបស់យើងគឺគ្មានអ្វីក្រៅពីដំណឹងនៃការស្លាប់របស់ពុកនៅគុកទួលស្លែងឡើយ ។ នៅចុងឆ្នាំ២០០៦ ខ្ញុំបានទៅសួរសុខទុក្ខបងប្អូនជីដូនមួយរបស់ខ្ញុំនៅទីក្រុងភ្នំពេញ ហើយនៅពេលនោះហើយដែលខ្ញុំបានទទួលដំណឹងពីការបាត់ខ្លួនរបស់ពុក ។ បងប្អូនជីដូនមួយរបស់ខ្ញុំបានប្រគល់ឯកសារពីរសន្លឹកដែលគាត់បានទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅចុងឆ្នាំ២០០៥ នៅខេត្តស្វាយរៀងមកឲ្យខ្ញុំ ។ ឯកសារនោះគឺជាប្រវត្តិរូបអ្នកទោសរបស់ពុក ។ ខ្ញុំមានអារម្មណ៍តានតឹងនៅពេលដែលដឹងថាពុកបានស្លាប់នៅក្នុងគុកដ៏សាហាវព្រៃផ្សៃនោះ ហើយភ្លាមៗនោះខ្ញុំក៏បានវិលត្រឡប់មកផ្ទះវិញដើម្បីប្រាប់ម៉ែពីដំណឹងដ៏អកុសលនេះ ។

ក្រោយពីសម្រួលអារម្មណ៍ ម្តាយខ្ញុំបានសម្រេចថាមកទស្សនាគុកទួលស្លែងនិងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសួររករូបថតរបស់ពុក ។ ម៉ែស្ទើរតែដួលសន្លប់បាត់ស្មារតីនៅពេលដែលបានឃើញរូបថតពុកនិងឃើញទីកន្លែងដែលពុកត្រូវបានឃុំខ្លួន ។ ម៉ែមិននិយាយមួយម៉ាត់សោះក្រៅពីយំ ។ ខ្ញុំអាចដឹងពីការឈឺចាប់របស់ម៉ែហើយដោយសារតែភាពឈឺចាប់នេះហើយដែលខ្ញុំត្រូវតែធ្វើអ្វីម្យ៉ាង ។ ក្រោយពីទទួលបានការសម្របសម្រួលពីមជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំបានសម្រេចចិត្តដាក់ពាក្យស្នើសុំធ្វើជាជនរងគ្រោះជូនដល់សាលាក្តីខ្មែរក្រហម ។ ខ្ញុំជឿជាក់ថាដំណើរការស្វែងរកយុត្តិធម៌អាចនឹងជួយព្យាបាលរបួសផ្លូវចិត្តរបស់ម៉ែបានមួយកម្រិត ។ ជាពិសេស ដំណើរការនេះនឹងផ្តល់កត្តិយសដល់ពុកនិងជនរងគ្រោះជាច្រើននាក់ទៀតសម្រាប់ការទទួលរងនូវអំពើសាហាវឃោរឃៅនោះ ។ ក្រោយពីការទទួលបាននិទ្ទណ្ឌភាពជាច្រើនឆ្នាំ វាដល់ពេលដែលមេដឹកនាំខ្មែរក្រហមត្រូវតែកាត់ទោសឲ្យទទួល

ខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន ។

ទោះបីជាម៉ែមានភាពស្ទាក់ស្ទើរយ៉ាងណាក្តី ក៏ខ្ញុំបានជំនុះចូលរួមក្នុងដំណើរការរបស់តុលាការ ។ ម៉ែចង់កប់ទុកការចងចាំរបស់គាត់នៅក្នុងចិត្តដើម្បីរំសាយភាពឈឺចាប់របស់គាត់ ។ ប៉ុន្តែខ្ញុំជឿថាម៉ែគួរតែទម្លាយភាពស្ងប់ស្ងាត់របស់គាត់ហើយប្រាប់រឿងរ៉ាវទាំងនោះទៅកាន់ពិភពលោក ។ ទីបំផុតខ្ញុំត្រូវបានចៅក្រមកោះហៅឲ្យផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការកាត់ទោស ឌុច ។ ខ្ញុំអាចនិយាយនូវអារម្មណ៍របស់ខ្ញុំនិងចោទសួរសំណួរទៅកាន់ជនជាប់ចោទ ។ នៅថ្ងៃនោះ ខ្ញុំមានជំនឿជឿជាក់ពីព្រោះខ្ញុំជឿថាពុក



ពិធីបុណ្យរបស់ម្តាយ ហាវ សោភា នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១២

នឹងផ្តល់កម្លាំងចិត្តឲ្យខ្ញុំ ។ មុនថ្ងៃឡើងធ្វើសក្ខីកម្មនៅតុលាការ ខ្ញុំបានយល់សប្តិឃើញពុកហើយពុកបានសុំឲ្យខ្ញុំផ្ញើសម្លៀកបំពាក់ទៅឲ្យគាត់ ។ នេះគឺជាលើកទីមួយហើយដែលខ្ញុំបានយល់សប្តិឃើញពុក ។

ឌុច បានទទួលស្គាល់ការស្លាប់របស់ពុកខ្ញុំ ប៉ុន្តែ ឌុច បានអះអាងថាការស្លាប់របស់ពុកមិនមែនជាបញ្ជាពីគណៈមជ្ឈិមទេ ។ ក្នុងអំឡុងដំណើរការនីតិវិធីនោះ ឌុច បានទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ខ្លួន ហើយតែងតែសុំការអត់ឱនទោសពីជនរងគ្រោះ ។ ប៉ុន្តែខ្ញុំបានភ្ញាក់ផ្អើលចំពោះសេចក្តីថ្លែងចុងក្រោយរបស់ ឌុច ដែល ឌុច បានសុំឲ្យតុលាការដោះលែង ។ តាមពិត ឌុច មិនមែនជាមនុស្សដែលគួរឲ្យទុកចិត្តឡើយ ។ យ៉ាងណាមិញ តាមរយៈការចូលរួមក្នុងដំណើរការផ្លូវច្បាប់របស់តុលាការខ្ញុំបានទទួលការស្ងប់ចិត្តខ្លះ ។ ទីបំផុត ម៉ែក៏បាននិយាយថា «ម៉ែមានអារម្មណ៍ថាធូរស្បើយបន្តិចនៅពេលដែលដឹងថាមានមនុស្សចង់ដឹងពីរឿងរ៉ាវរបស់យើង» ។ ប៉ុន្តែភាពឈឺចាប់ផ្លូវចិត្តរបស់ម៉ែនៅតែតាមយាយីគាត់ ហើយម៉ែនឹងមិនរួចផុតពីភាពឈឺចាប់នេះឡើយ ។

ចាប់តាំងពីយើងបានដឹងពីកាលបរិច្ឆេទនៃការស្លាប់របស់ពុកមកយើងតែងតែរៀបចំម្ហូបអាហារដើម្បីប្រគេនព្រះសង្ឃរាល់ថ្ងៃទី១៥ ខែឧសភា ។ យើងសង្ឃឹមថាការវេសបុណ្យកុសលតាមបែបព្រះពុទ្ធសាសនានឹងជួយឲ្យពុកទៅកាន់សុគតិភព ។

ពុក ថ្ងៃនេះគឺជាថ្ងៃចុងបញ្ចប់នៃអង្គសវនាការរបស់ ឌុច ។ ខ្ញុំសង្ឃឹមថា ពុកនឹងទទួលបានយុត្តិធម៌ ។ ខ្ញុំដឹងថា ឌុច សមនឹងទទួលបានជោគវាសនាអាក្រក់ជាងការដាក់ទោសនេះ ប៉ុន្តែយ៉ាងហោចណាស់ទណ្ឌកម្មដែល ឌុច បានទទួលនឹងជួយរារាំងសោកនាដកម្មនេះកុំឲ្យកើតឡើងម្តងទៀត ។ ខ្ញុំនឹងចងចាំពុកជារៀងរហូត ។ ពុកនឹងម៉ែ សូមឲ្យវិញ្ញាណខន្ធអ្នកទាំងពីរទៅកាន់សុគតិភព កុំបីឃ្លាងឃ្លាតឡើយ ។ **ហាវ សោភា**

# ខ្ញុំចង់ដឹងថា ឌុច មានអារម្មណ៍បែបណាបើសិនជា គាត់មានកូនជាប់នៅមន្ទីរស-២១?

នៅក្នុងរបប ប៉ុល ពត ខ្ញុំរស់នៅភូមិព្រែកប៉ែ ឃុំកោះធំ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ខ្ញុំបានបាត់បង់កូនប្រុសម្នាក់ឈ្មោះ មីន កន នៅពេលដែលខ្មែរក្រហមនាំកូនខ្ញុំយកទៅកាលពីឆ្នាំ១៩៧៥ ។

មីន កន បានចូលបម្រើកងទ័ពខ្មែរក្រហមនៅអាយុ១៦ឆ្នាំ ។ កូនខ្ញុំបានចេញពីផ្ទះទៅធ្វើសង្គ្រាមប្រដាប់ដោយអាវុធប្រឆាំងទាហាន លន់ នល់ ។ ខ្ញុំបានបន្តរស់នៅ និងធ្វើការក្នុងភូមិដដែល ហើយក៏មិនបានឮដំណឹងអ្វីសោះពីកូនខ្ញុំ ។ នៅឆ្នាំ១៩៧៥ មីន កន បានមកលេងផ្ទះម្តង ដោយស្លៀកពាក់ជាយោធាខ្មែរក្រហម ។ ក្រោយពេលដែលយើងនិយាយគ្នាបានមួយភ្លែត ប្រធានភូមិនិងឈ្លបក៏បានមកដល់ ហើយបានចាប់ខ្លួនកូនខ្ញុំយកទៅដោយនិយាយថា អង្គការចោទកូនខ្ញុំថាបានចាកចេញពីមូលដ្ឋានដោយគ្មានការអនុញ្ញាត ។ ក្រុមគ្រួសារខ្ញុំមិនអាចជួយអ្វីបានទេ ពីព្រោះកម្មាភិបាលថ្នាក់ឃុំគឺផ្តាច់ការណាស់ ។


ម៉ែន ឡាយ

កាលនោះ កូនខ្ញុំបានមកលេងផ្ទះជាមួយមិត្តរួមការងារចំនួនបីនាក់ទៀត ដែលជាអ្នកភូមិព្រែកប៉ែ ។ យ៉ាងណាមិញ ខ្ញុំមិនប្រាកដថាតើអ្នកទាំងបីនាក់នោះត្រូវបានចាប់ខ្លួនបញ្ជូនទៅមូលដ្ឋានវិញដែរឬយ៉ាងណានោះទេ ។ កូនប្រុសខ្ញុំមិនដឹងថាបាត់ខ្លួនទៅដល់ទីណាទេ ចាប់តាំងពីត្រូវបានចាប់ខ្លួនមក ។ ក្នុងរបបខ្មែរក្រហម បើទោះបីជាប្រជាជនគ្រប់គ្នាត្រូវបានបង្ខំឲ្យធ្វើការងារពេញមួយថ្ងៃដោយគ្មានពេលសម្រាកក៏ដោយ ក៏ក្រុមគ្រួសារខ្ញុំនៅតែព្យាយាមស្វែងរកដំណឹងកូនខ្ញុំ ។ ប៉ុន្តែយើងមិនបានទទួលព័ត៌មានអ្វីទាល់តែសោះ ដោយបានត្រឹមតែដឹងថាកូនខ្ញុំត្រូវបាននាំទៅមន្ទីរ១៥ប៉ុណ្ណោះ ។

នៅខែកញ្ញា ឆ្នាំ២០០៨ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគល់ប្រវត្តិរូបកូនប្រុសខ្ញុំដែលរក្សាទុកនៅមន្ទីរស-២១ មកឲ្យខ្ញុំ ។ ខ្ញុំមានអារម្មណ៍រន្ធត់នៅពេលដែលបានដឹងថាកូនប្រុសខ្ញុំត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែងដ៏សាហាវព្រៃផ្សៃដែលជាកន្លែងធ្វើទារុណកម្មលើអ្នកទោសដ៏សាហាវ មុនពេលដែលអ្នកទាំងនោះត្រូវបានសម្លាប់ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបរាប់ពីដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ ដូចជាការចាប់ខ្លួននិងសម្លាប់អ្នកទោសជាលក្ខណៈប្រព័ន្ធ ហើយក៏បានប្រាប់ខ្ញុំថា ឌុច ដែលជាប្រធានមន្ទីរស-២១នោះ ត្រូវបានកាត់ទោសក្នុងសំណុំរឿង០០១ ដោយសាលាក្តីខ្មែរក្រហម ។ មុននឹងទទួលបានការអះអាងពីការស្លាប់របស់កូនប្រុសខ្ញុំ ខ្ញុំតែងតែសង្ឃឹមថា កូនខ្ញុំនៅរស់ ហើយនឹងវិលត្រឡប់មកផ្ទះវិញនៅថ្ងៃណាមួយជាមិនខាន ។ ជាញឹកញាប់ ខ្ញុំដេកមិនលក់ហើយតែងតែឈឺក្បាលរាល់ពេលដែលខ្ញុំគិតពីកូនប្រុសខ្ញុំ ។ ការស្រមើស្រមៃពីការធ្វើទារុណកម្មនិងការសម្លាប់មកលើកូនប្រុសគាត់បានធ្វើឲ្យខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ។ ខ្ញុំចង់ដឹងថា ឌុច មានអារម្មណ៍បែបណា បើសិនជាកូនរបស់គាត់ជាប់នៅមន្ទីរស-២១?

ដើម្បីជាការគោរពវិញ្ញាណកូនប្រុសខ្ញុំ ខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់រឿងក្តី០០១នៅឯសាលាក្តីខ្មែរក្រហម ។ សេចក្តីសម្រេចនេះបានធ្វើឲ្យខ្ញុំធូរស្បើយខ្លះដោយសារតែខ្ញុំបានចូលរួមក្នុងសវនាការ ហើយមានឱកាសចែករំលែកការឈឺចាប់ជាមួយនឹងអ្នករស់រានមានជីវិតផ្សេងទៀត ។ ខ្ញុំក៏សង្ឃឹមថា ឌុច នឹងទទួលបានការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ **ម៉ែន ឡាយ**

# បងប្រុសខ្ញុំដែលបាត់ខ្លួន

មុននឹងខ្មែរក្រហមឡើងកាន់កាប់អំណាចក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំរស់នៅភូមិចាមលើ ឃុំព្រៃកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ។ ខ្ញុំមានបងប្អូនប្រាំពីរនាក់ ប្រុសពីរ ស្រីប្រាំ ។ ឪពុកម្ដាយខ្ញុំប្រកបមុខរបរជាអ្នកនេសាទ ។ ប៉ុន្តែនៅឆ្នាំ១៩៧៣ ភូមិខ្ញុំបានក្លាយជាតំបន់រំដោះរបស់ខ្មែរក្រហម ។

បងប្រុសខ្ញុំម្នាក់ឈ្មោះ រួន ម៉ាត់ បានស្លាប់ក្នុងរបបខ្មែរក្រហម ។ កាលនៅក្មេងគាត់បានជួយការងារនេសាទរបស់ឪពុកម្ដាយខ្ញុំបានរយៈពេលពីរឆ្នាំមុនពេលដែលចាកចេញពីផ្ទះនៅវ័យ១៥ឆ្នាំ ដើម្បីទៅជួយមុខរបររកស៊ីរបស់បងធំខ្ញុំនៅភូមិអណ្ដូងស្ដេច ខេត្តកំពង់ចាម ។ មួយឆ្នាំក្រោយមក គាត់ក៏បានសម្រេចចិត្តត្រឡប់មកផ្ទះវិញដើម្បីជួយការងារនេសាទនៅផ្ទះបានរយៈពេលបីឆ្នាំ ។

បងប្រុសខ្ញុំបានចូលបម្រើជាយោធាខ្មែរក្រហមនៅឆ្នាំ១៩៧៣ ដោយសារប្រធានភូមិចាមលើ ឈ្មោះ អ៊ីល ហ៊ីម អ្នកទោស ។ នៅឆ្នាំនោះហើយដែលគាត់បានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ ក្រោយមក គាត់បានគេចខ្លួនទៅភូមិពោធិ៍ទន្លេ ដោយមានប្រធានភូមិឈ្មោះ ហ៊ីម ឡេះ ជួយឲ្យគាត់លាក់ខ្លួនបានរយៈពេលបីខែ ពីព្រោះ បងប្រុសខ្ញុំចង់រត់ទៅវៀតណាមជាមួយហ៊ីម ឡេះ ។ គាត់ស្អប់ឈ្មោះ អ្នកដែលបានបង្ខំគាត់ឲ្យចូលធ្វើទ័ព ។ បងប្រុសខ្ញុំមិនបានធ្វើអ្វីខុសឡើយ ក្រៅពីចង់ភៀសខ្លួនទៅប្រទេសវៀតណាមប៉ុណ្ណោះ ។ លើសពីនេះ គាត់ក៏ស្អប់ខ្មែរក្រហមនិងភាពលំបាកវេទនាដែលកើតមានក្នុងជួរកងទ័ព ។

បងប្រុសខ្ញុំបានបាត់ខ្លួននៅឆ្នាំ១៩៧៥ ហើយយើងមិនបានដឹងថាមានរឿងអ្វីកើតឡើងចំពោះគាត់ឡើយ ។ រៀងរាល់ថ្ងៃយើងតែងតែស៊ើបរកដំណឹងពីគាត់ប៉ុន្តែគ្មានដំណឹងអ្វីសោះ ។ ខ្ញុំរំពឹងថាបងប្រុសខ្ញុំនឹងវិលត្រឡប់មកផ្ទះវិញ ក្រោយពេលដែលសង្គ្រាមបានរលត់ទៅនៅឆ្នាំ១៩៧៩ ។ យើងបានរង់ចាំអស់រយៈពេលសាមសិបឆ្នាំហើយ ។ យើងក៏បានគិតថាគាត់បានស្លាប់បាត់ហើយ ។

ទីបំផុតបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ពីជោគវាសនារបស់បងប្រុសខ្ញុំ ហើយក៏បានប្រគល់ឲ្យយើងនូវឯកសារដ៏ក្រាសមួយដុំដែលជាប្រវត្តិរូបនិងចម្លើយសារភាពរបស់គាត់ ។ រឿងរ៉ាវដែលយើងចង់ដឹងទាំងភ័យខ្លាចនោះគឺថាបងប្រុសខ្ញុំត្រូវបានឃុំខ្លួនធ្វើទារុណកម្មនិងសម្លាប់នៅគុកទួលស្លែង ។ ដោយសារតែភាពចាស់ជរារបស់ខ្ញុំ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅពីដាក់ពាក្យស្នើសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីរកយុត្តិធម៌ឲ្យគាត់ ។ ខ្ញុំបានផ្ដល់ព័ត៌មានសំខាន់ៗដល់តុលាការ ហើយសង្ឃឹមថាតុលាការនឹងជួយស្វែងរកយុត្តិធម៌ជូនបងប្រុសខ្ញុំ ។ ខ្ញុំនឹងគោរពរាល់សេចក្ដីសម្រេចរបស់ចៅក្រម ។ **រួន ស្រីណុប**

## ដំណឹងស្វែងរកសាច់ញាតិ

នាងខ្ញុំឈ្មោះ កង យិន អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិអន្លង់ជ្រៃ ឃុំអំពើន ស្រុកបន្ទាយមាស ខេត្តកំពត ។ សូមប្រកាសស្វែងរកកូននិងប្ដីដែលបាត់ខ្លួនកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ។ កូនរបស់ខ្ញុំឈ្មោះ ហួម ហើយប្ដីឈ្មោះ ពីន ។ អ្នកទាំងពីរត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើស្រែអំបិលនៅកែប ហើយមិនឃើញត្រឡប់មកវិញរហូតដល់សព្វថ្ងៃ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ**

# យុត្តិធម៌ជូនលោកពុក

ឪពុកខ្ញុំឈ្មោះ ថ្លុក លួន ។ គាត់បានចូលបម្រើចលនាខ្មែរក្រហមនៅដើមទសវត្សរ៍៧០ ដែលពេលនោះខ្ញុំមានអាយុប្រហែល៦ឆ្នាំប៉ុណ្ណោះ ។ ខ្ញុំបានដឹងថាពុកកំពុងតែប្រយុទ្ធប្រឆាំងនឹងទាហាន លន់ នល់ នៅសមរភូមិពីព្រោះគាត់មានកាំភ្លើង ។ ឪពុកខ្ញុំបានមកសួរសុខទុក្ខគ្រួសារពីរបីខែម្តង ។

កាលនោះខ្ញុំនៅ ក្មេងពេកមិនបានដឹងថាគាត់ប្រយុទ្ធនៅសមរភូមិណាទេ ហើយខ្ញុំក៏កម្រនឹងបានជួបនិងទទួលបានភាពថ្នាក់ថ្នមពីគាត់ដែរ ។ ម្តាយខ្ញុំបានប្រាប់ខ្ញុំថាយើងនឹងរស់នៅជុំគ្នាវិញនៅពេលដែលប្រទេសជាតិទទួលបានសន្តិភាព ។

ក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ក្រុមគ្រួសារខ្ញុំបានជួបជុំគ្នា ហើយរស់នៅប្រាំងចំរេះ ទីក្រុងភ្នំពេញ ។ ក្រុមគ្រួសារខ្ញុំបានមករស់នៅទីក្រុងដោយសារឪពុកខ្ញុំជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ម្នាក់ ។

ខ្ញុំបានចាំថា ឪពុកខ្ញុំមាននិរសារម្នាក់ វិទ្យុទាក់ទងមួយគ្រឿង និងឡានមួយគ្រឿងសម្រាប់បើកមកធ្វើការនៅទីក្រុងភ្នំពេញ ។

នៅឆ្នាំ១៩៧៦ ឪពុកខ្ញុំបានឲ្យខ្ញុំទៅនៅជាមួយបងប្រុសនិងបងប្អូនជីដូនមួយ នៅមន្ទីរពាណិជ្ជកម្មក្នុងទីក្រុងភ្នំពេញ ។ កិច្ចការដែលខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើ គឺបកសំបកផ្លែគរទុំ និងយាមការពារកប៉ាល់ពេលយប់ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួបមុខឪពុកម្តាយឬទទួលដំណឹងពីគាត់ទេ រហូតដល់ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ។

មកដល់ខែមីនា ឆ្នាំ២០០៥ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ប្រវត្តិរូបអ្នកទោសរបស់ឪពុកខ្ញុំឲ្យមកខ្ញុំ ។ ខ្ញុំភ្ញាក់ផ្អើលនិងរន្ធត់យ៉ាងខ្លាំងក្រោយពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអានប្រវត្តិរូបឪពុកខ្ញុំ ។ តាមការចងចាំរបស់ខ្ញុំឪពុកខ្ញុំគឺជាមនុស្សដែលហ៊ានពលីគ្រប់បែបយ៉ាងដើម្បីបម្រើដល់បដិវត្តន៍ ប៉ុន្តែចុងក្រោយ គាត់ត្រូវទទួលរងការធ្វើទារុណកម្មនិងសម្លាប់នៅមន្ទីរស-២១ទៅវិញ ។ ខ្ញុំទើបតែដឹងថា ប្រធានមន្ទីរស-២១ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលមានស្រុកកំណើតនៅខេត្តកំពង់ធំ ។

កាលពីឆ្នាំ១៩៨១ គា ដែលជានិរសាររបស់ឪពុកខ្ញុំបានមកប្រាប់ខ្ញុំថាឪពុកម្តាយខ្ញុំនិងបងប្អូនខ្ញុំចំនួនប្រាំមួយនាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន ប៉ុន្តែ គា មិនបានដឹងថាអ្នកទាំងអស់ត្រូវបាននាំទៅទីណាទេ ។ បច្ចុប្បន្ន គា គឺជាអ្នកបើកឡានឲ្យមេប៉ូលិសជាន់ខ្ពស់ម្នាក់នៅខេត្តកំពង់ធំ ។

ខ្ញុំបានបាត់បង់ឪពុកម្តាយនិងបងប្អូនចំនួនប្រាំមួយនាក់ក្រោមរបបខ្មែរក្រហម ។ រហូតមកដល់សព្វថ្ងៃមានតែខ្ញុំនិងបងប្អូនពីរនាក់ទៀតប៉ុណ្ណោះដែលនៅរស់រានមានជីវិត ព្រោះមុនការចាប់ខ្លួន ឪពុកខ្ញុំបានបញ្ជូនយើងទាំងអស់គ្នាឲ្យទៅរស់នៅកន្លែងផ្សេងៗ ។

ជារៀងរាល់ឆ្នាំ ជាពិសេស គឺក្នុងអំឡុងពេលបុណ្យទានបងប្អូនខ្ញុំតែងតែទៅវត្តនិងប្រគេនចង្ហាន់ដល់ព្រះសង្ឃដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធរបស់ឪពុកម្តាយ និងបងប្អូនខ្ញុំដែលបានស្លាប់ទៅ ។

ដោយសារតែខ្ញុំជាកូនប្រុសម្នាក់របស់ ថ្លុក លួន ខ្ញុំមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១នៅចំពោះមុខសាលាក្តីខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌ជូនក្រុមគ្រួសារខ្ញុំ ។

ខ្ញុំមិនអាចទទួលយកសំណូមពររបស់ ឌុច ដែលចង់ឲ្យចៅក្រមឲ្យដោះលែង ឌុច ឡើយ ។ ខ្ញុំចង់ឲ្យ ឌុច ជាប់គុកអស់មួយជីវិតដើម្បីឲ្យវិញ្ញាណក្ខន្ធរបស់ក្រុមគ្រួសារខ្ញុំទៅកាន់សុគតិភពដោយបិទភ្នែកជិត ។ **យឹម ឡេង**

# ឪពុករបស់ខ្ញុំ និងការប្រកាសសាលដីការបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច

ខ្ញុំកើតនៅឆ្នាំ១៩៩២ នៅស្រុកកោះធំ ខេត្តកណ្តាល ហើយមានបងប្អូនប្រាំបួននាក់ ។ ខ្ញុំជាកូនទីបួននៅក្នុងគ្រួសារ ។ ឪពុករបស់ខ្ញុំឈ្មោះ ហ៊ឹម ហ៊ុយ ដែលមនុស្សភាគច្រើនស្គាល់គាត់ថា ជាអតីតសន្តិសុខមួយរូបនៅមន្ទីរស-២១ ដែលមានកាំង ហ្គេកអ៊ាវ ឌុច ជាប្រធាន ។ នៅក្នុងរបបខ្មែរក្រហម មនុស្សជាច្រើនត្រូវបាន ចាប់ខ្លួនហើយដាក់ឃុំឃាំងនៅមន្ទីរស-២១ ដែលក្រោយមក អ្នកទោសភាគច្រើនត្រូវបានសម្លាប់ចោល ។ កាលពីមុន ខ្ញុំមិន សូវបានដឹងអំពីរឿងរ៉ាវទាំងអស់ដែលបានកើតឡើងពីសម័យ ខ្មែរក្រហមប៉ុន្មានទេ បើទោះបីជាឪពុកម្តាយខ្ញុំធ្លាប់ទទួលរងនូវ ភាពលំបាកវេទនាកាលពីសម័យនោះក៏ដោយ ។ រហូតដល់ពេល ដែលរឿងរ៉ាវនៃរបបខ្មែរក្រហមត្រូវបានមនុស្សជាច្រើននិយាយ ឡើងវិញ និងរហូតដល់ពេលដែលខ្ញុំបានចូលមកបម្រើការជា បុគ្គលិកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានចាប់ផ្តើម ស្វែងយល់ពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបនេះ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀស ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញឲ្យទៅនៅតាមជនបទដើម្បីធ្វើ ស្រែចម្ការ ហើយអ្នកទាំងនោះត្រូវបានបំបែកចេញពីឪពុកម្តាយ និងកូន ។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាពលរដ្ឋធ្វើការស្ទើរគ្មានពេល សម្រាកនិងពុំមានអាហារបរិភោគគ្រប់គ្រាន់ឡើយ ។ ប្រជាពលរដ្ឋ ទទួលបានតែបបររាវតែមួយប្លុពីរវែកប៉ុណ្ណោះក្នុងមួយពេល ។ កុមារមិនឲ្យទៅរៀនទេ ។ កុមារត្រូវបានចាត់តាំងឲ្យដើររើស អាចម៍គោនិងឃ្វាលគោក្របីទៅវិញ ។ ខ្ញុំបានរៀនសូត្រពីរឿងរ៉ាវ នៃរបបខ្មែរក្រហមពីឪពុករបស់ខ្ញុំនិងពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលខ្ញុំកំពុងធ្វើការទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងកាលពី របបខ្មែរក្រហម ។ ឪពុករបស់ខ្ញុំមានការសោកស្តាយជាខ្លាំងហើយ រឿងរ៉ាវទាំងនេះនៅតែដក់ជាប់ក្នុងចិត្តរបស់ឪពុកខ្ញុំជានិច្ច ។ គាត់ តែងតែនិយាយប្រាប់ខ្ញុំថា គាត់មិនដែលគិតថានឹងអាចមានជីវិត រស់ចេញពីរបបខ្មែរក្រហមទេ ។ វាជាការចងចាំដ៏ឈឺចាប់បំផុត សម្រាប់ពុកចំពោះអ្វីដែលបានកើតឡើង ។ ជាពិសេសគឺរឿងរ៉ាវ ដែលបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ ។ មន្ទីរស-២១ ពេលខ្លះពុកមានបំណងចង់ធ្វើអត្តឃាតខ្លួនឯងដោយសារតែ មិនអាចទ្រាំបាន ។ ប៉ុន្តែគាត់ក៏ដឹងដែរថាប្រសិនបើគាត់សម្រេច ចិត្តបែបនោះមែន នោះក្រុមគ្រួសាររបស់គាត់ក៏ នឹងមានជោគវាសនាដូចជាគាត់ដែរ ឪពុកនិង កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមផ្សេងទៀត គ្មានជម្រើសអ្វីទេនៅក្នុងរបបខ្មែរក្រហម ។ អ្នកទាំងអស់គ្នាត្រូវតែស្តាប់បញ្ជានិងគោរព តាមថ្នាក់លើជាដាច់ខាត ។ ឌុច គឺជាប្រធានរបស់ ពុក ។ ឌុច គឺជាមនុស្សតែម្នាក់ដែលគួរតែទទួល ខុសត្រូវចំពោះរឿងរ៉ាវដែលបានកើតឡើងនៅ មន្ទីរសន្តិសុខស-២១ ។


សេងហុល (ឆ្វេង) និង នង ចិនគីមទី កូនរបស់អ្នកទោសមន្ទីរស-២១ ឈ្មោះ នង ចាន់ផល កំពុងស្រង់ឈ្មោះអ្នកដែលបានស្លាប់និងបាត់ខ្លួនក្នុងរបបខ្មែរក្រហម

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅ ឆ្នាំ១៩៧៩ ពុកត្រូវបានគណៈកម្មាធិការស្រុក

កោះធំហើយយកទៅអប់រំរៀនសូត្រអស់រយៈពេលជាងមួយឆ្នាំពីបទជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។ ក្រោយមក គ្រួសាររបស់ខ្ញុំក៏បានជួបជុំគ្នាវិញបន្ទាប់ពីពុកត្រូវបានដោះលែងឲ្យចេញពីមន្ទីរឃុំឃាំងស្រុកកោះធំ ។ ជារឿយៗ ពុកនិយាយប្រាប់ខ្ញុំថា អ្វីដែលគាត់បានធ្វើកាលពីរបបខ្មែរក្រហមគឺដើម្បីនឹងរស់តែប៉ុណ្ណោះ ។ បើសិនជាគាត់មិនធ្វើ គាត់នឹងត្រូវស្លាប់ ។ បន្ទាប់ពីពុកត្រូវបានដោះលែង ខ្ញុំបានសង្កេតឃើញថាពុកនៅតែមានការសោកស្ដាយចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពុកនៅតែខិតខំប្រឹងប្រែងដើម្បីចិញ្ចឹមបីបាច់គ្រួសារតាមសមត្ថភាពដែលគាត់ធ្វើបាន ។ ពុកខ្ញុំគឺជាមនុស្សខស្សាហ៍ព្យាយាម ។ គាត់ធ្វើស្រែចម្ការដើម្បីចិញ្ចឹមបីបាច់ជីវភាពគ្រួសារក្រីក្រ ។ ឥឡូវដោយសារតែពុក ជីវភាពរបស់យើងហាក់ដូចជាប្រសើរជាងមុន ។ បងៗរបស់ខ្ញុំមួយចំនួនបានរៀបការ និងមានមុខរបបចិញ្ចឹមជីវិតរៀងៗខ្លួន ។ ខ្ញុំក៏បានរៀនបន្តនៅសកលវិទ្យាល័យនៅទីក្រុងភ្នំពេញ ។ ឪពុករបស់ខ្ញុំស្រឡាញ់កូនៗណាស់ ។ គាត់មិនដែលធ្វើបាបឬវាយដំកូនឡើយ ។ គាត់តែងតែនិយាយថា គាត់មិនចង់ឃើញកូនរបស់គាត់មានវាសនាដូចជារូបគាត់កាលពីរបបខ្មែរក្រហមនោះទេ ។ អ្នកជិតខាងស្រឡាញ់រាប់អានពុកគ្រប់ៗគ្នា ។ ពុកមិនដែលបង្កទំនាស់ជាមួយអ្នកដទៃឡើយ ហើយដោយសារតែដើរតាមគំរូរបស់ពុក កូនៗក៏មិនដែលនាំរឿងមិនល្អ ឬបង្កបញ្ហាអ្វីឲ្យពុកវិញផងដែរ ។

ខ្ញុំស្អប់ ឌុច ។ ខ្ញុំស្អប់នូវអ្វីដែលគាត់បានប្រព្រឹត្តកាលពីរបបខ្មែរក្រហម ។ ខ្ញុំចង់ឲ្យ ឌុច ជាប់ទោសអស់មួយជីវិត ហើយមិនគួរត្រូវបានបន្ធូរបន្ថយទោសនោះទេ ។ ខ្ញុំគិតថាប្រសិនបើរបបខ្មែរក្រហមមិនបានកើតឡើងនោះទេ ជីវភាពគ្រួសារខ្ញុំប្រហែលជាល្អប្រសើរជាងនេះ ពីព្រោះយើងមិនចាំបាច់ចាប់ផ្ដើមកសាងជីវិតសាជាថ្មីបន្ទាប់ពីរបបខ្មែរក្រហមនោះទេ ។ ឌុច មិនមែនត្រឹមជាប្រធានមន្ទីរស-២១ និងជាប្រធានរបស់ពុកខ្ញុំប៉ុណ្ណោះនោះទេ ឌុច ថែមទាំងជាអ្នកដែលមើលការខុសត្រូវបន្ថែមទៅលើមន្ទីរសន្តិសុខស-២៤ ឬគុកព្រៃស និងវាលពិឃាតជើងឯកដ៏គួរឲ្យរន្ធត់ ។ ឌុច គឺជាជនបដិវត្តន៍ដ៏កំណាចម្នាក់ ។ ឌុច ជាអ្នកទទួលខុសត្រូវនៃជីវិតមនុស្សប្រមាណជាងមួយម៉ឺនបួនពាន់នាក់ដែលក្នុងនោះរួមមានកុមារជាច្រើននាក់ផងដែលបានស្លាប់នៅក្រោមការគ្រប់គ្រងរបស់គាត់ ។

ថ្ងៃទី៣ ខែកុម្ភៈ ខ្ញុំបានធ្វើដំណើរទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយពុករបស់ខ្ញុំដើម្បីចូលរួមស្ដាប់ការប្រកាសសាលដីកាលើបណ្ដឹងឧទ្ធរណ៍លើសំណុំរឿង០០១ដែលមានជនជាប់ចោទឈ្មោះ ឌុច ។ ខ្ញុំមានបារម្ភក្នុងចិត្តប្រសិន បើ ឌុច មិនត្រូវបានតុលាការកំពូលដាក់ទោសអស់មួយជីវិត ។ ប៉ុន្តែនៅពេលដែលបានឮការប្រកាសរបស់តុលាការកំពូលថាដាក់ទោស ឌុច មួយជីវិត ខ្ញុំមានការសប្បាយចិត្តជាខ្លាំងព្រោះវាដូចទៅនឹងអ្វីដែលខ្ញុំបានរំពឹងទុក ។ ខ្ញុំពេញចិត្តនឹងការសម្រេចបែបនោះហើយ ឪពុករបស់ខ្ញុំដែលបានមកស្ដាប់ការប្រកាសសាលដីកាជាមួយខ្ញុំក៏មានការសប្បាយរីករាយដែរ ។ ទីបំផុត ឌុច ត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់គាត់ ។

**ហ៊ុយ សេងហ៊ុល**


សេងហ៊ុល និង គីមទី ធ្វើដំណើរជាមួយគ្នាមកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែដ និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 146, February 2012 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.